# ដំណក់ទឹកខ្មៅ



និពន្ធដោយ

ចិត្តរក្ខិតោ. សៅ-ចាន់ណា

# តំណក់ទឹកខ្មៅ



និពន្ធដោយ

ចិត្តរក្ខិតោ. សៅ_ចាន់ណា

➢ សៀវភៅឈ្មោះ : **តំណក់ទឹកខ្មៅ**

➢ និពន្ធដោយ : **ចិត្តរក្ខិតោ. សៅ~ចាន់ណា**

➢ វាយអត្ថបទ និង ចរនាដោយ : **ចិត្តរក្ខិតោ. សៅ~ចាន់ណា**

➢ ជួយពិនិត្យអក្ខរាវិរុទ្ធដោយ :

~ភិក្ខុ **សីលរក្ខិតោ. ម៉ោល~សារុន**

~សាមណេរ **ខេមបណ្ឌិតោ. ប៊ុន~ចាន់សុខេន**

➢ ទីកន្លែងធ្វើ : **វត្តតបោស្សសាន ហៅវត្តស្អាច់** ខេត្ត/ក្រុង កំពង់ឆ្នាំង

➢ កាលបរិច្ឆេទធ្វើចប់ : ថ្ងៃច័ន្ទ ១៤កើត ខែមាឃ ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ (០៧-០៣-២០១៦)

➢ បោះពុម្ពលើកទី១ : ចំនួន ១.០០០ ក្បាល

➢ អស់ទឹកប្រាក់ចំនួន : ............................

➢ ចែកផ្សាយជាធម្មទាន : **ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ**

➢ ធម្មទានដោយ : **ពុទ្ធបរិស័ទទូទៅ**

➢ លេខទូរស័ព្ទ : **071 55 777 28 / 061 68 777 8**

➢ **Facebook : Sao Channa**

# វាចារកថា

✍...រាត្រីស្ងប់ស្ងាត់ សព្វសត្វចូលនិទ្រានារាត្រីកាល សែនសុខមនោរម្យ ក្នុងស្បែសន្ធិយា ឥតគិតខ្វល់ខ្វាយពីទុក្ខលំបាកដែលមានតាំងពីថ្ងៃ ខំប្រឹងរកស៊ីទទួលទានដើម្បីជីវិត ទោះលំបាកតោកយ៉ាកគ្រាំគ្រាដួងចៃយ៉ាងណា ក៏ខំមាត់សង្កត់ចិត្ត មិនអាចបញ្ចេញវាចាមកបានឡើយ ។

ចំណែកខ្ញុំឯណេះវិញ ខំប្រឹងគិតជញ្ជឹងរំពឹងក្នុងចិត្ត រិះរកកម្រងអត្ថន័យផ្សេង១ ដែលទាក់ទងនឹងជីវិត ការរស់នៅបច្ចុប្បន្នសព្វថ្ងៃនេះ យកមកចងក្រង បានជាកម្រងអក្ខរា ដើម្បីសម្តែងថ្លែងពីសំនៀងកំណាព្យ ចែកជូនមហាធម្មមិត្តទាំងអស់គ្នា ដើម្បីបានជាមហាកុសល ផ្តល់ឱ្យរួចផុតពីអន្លង់ទុក្ខនេះ ។

សូមរីករាយជ្រះថ្លា អាននូវសៀវភៅ **តំណក់ទឹកខ្មៅ** (គឺជាកម្រងអក្ខរាដែលចារពីចិត្តខ្ញុំ) នឹងបានជាគតិជីវិតខ្លះ១ សម្រាប់អប់រំពិចារណា តាមបែបពាក្យកាព្យ, ទោះបីជាកំណាព្យកាព្យឃ្លោងក៏ពិតមែន ប៉ុន្តែមិនឱ្យឃ្លៀងឃ្លាតពីពាក្យអប់រំរបស់ព្រះមានព្រះភាគជាម្ចាស់ឡើយ ។

វត្តតបោស្សសាន ថ្ងៃច័ន្ទ ១៤កើត ខែមាឃ

ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ (០៧-០៣-២០១៦)

**បំណាងល្អពីខ្ញុំ ចិត្តរក្ខិតោ. សៅ-ចាន់ណា**

# កម្រងមាតិកា

**ចំណងជើងកំណាព្យ** **ទំព័រ**


១. ជិតភ្ជុំបិណ្ឌហើយ កូនអើយដឹងទេ? ........................................ ១

២.ករីតែងជូន ជំនូនមុនភ្ជុំ ........................................ ២

៣. ទៅបុណ្យភ្ជុំបិណ្ឌ ........................................ ៤

៤. កំណាព្យ ក-ខ ចូរកុំខឹងក្រោធ ........................................ ៥

៥. សម្ដីខុសការប្រហារអ្នកស្ដាប់ ........................................ ៦

៦. កូនសូមលាទោសដែលខុសលើម៉ែ ........................................ ៧

៧. ភ្លៀងធ្លាក់ត្រជាក់កាយ ........................................ ៨

៨. ធ្វើបុណ្យ បុណ្យជួយ ........................................ ១០

៩. ដើម្បីជីវិត ........................................ ១១

១០. សភាវៈពិតនៃរូបកាយ ........................................ ១២

១១. អាសូរពួកប្រេត ! ........................................ ១៣

១២. ប្រកបកិច្ចការដូចឧស្សាហ៍រៀន ........................................ ១៤

១៣. គុណលោកឪពុក ........................................ ១៦

១៤. បណ្ឌិត ........................................ ១៨

## តំណក់ទឹកខ្មៅ


១៥. ពាល ................................................................ ១៩

១៦. រាល់ថ្ងៃល្ងាចព្រឹកនឹកម៉ែគ្មានស្បើយ ........................................ ២០

១៧. ជួបជាគូនិងព្រាត់ ........................................................ ២២

១៨. ជីវិតកូនកំព្រា ........................................................... ២៣

១៩. ទឹកចិត្តមាតាស្នេហាកូនប្អូស ............................................... ២៥

២០. កឋិនវត្តយើង ............................................................ ២៧

២១. កឋិនឆ្នាំនេះញោតិទៅវត្តណា? ............................................... ២៨

២២. ទំនួញកូនពេលម៉ែស្លាប់ ...................................................... ២៩

២៣. ឈ្លក់នឹងសំឡេងវង្វេងផ្លូវចិត្ត ................................................ ៣៣

២៤. សំណាងស្រីណាស់ប៉ះប្ដីចិត្តធម៌ ............................................... ៣៤

២៥. សត្វខុសមនុស្ស .......................................................... ៣៥

២៦. តាតាចាស់ហើយទៅវត្តខ្លះផង ! ............................................... ៣៦

២៧. សប្បាយថ្ងៃនេះគង់ទុក្ខថ្ងៃក្រោយ ............................................. ៣៨

២៨. កំណាជីវិត ............................................................... ៤០

២៩. ផល៥ប្រការជ្រះថ្លាស្ដាប់ធម៌ ................................................. ៤២

៣០. អស្សុជ៥រោចកឋិនវត្តស្នាច់ ................................................ ៤៤

៣១. សិក្សា ................................................................ ៤៦

៣២. អន្លង់ជីវិត ........................................................................ ៤៨
៣៣. ជីវិតមានកម្ម ........................................................................ ៥០
៣៤. អារម្មណ៏បាត់មិត្រពិតជាឯកា ........................................................ ៥១
៣៥. យប់ស្ងាត់បាត់ម៉ែ ........................................................................ ៥២
៣៦. អាសូរពុកម៉ែ ........................................................................ ៥៣
៣៧. ស្រណោះម៉ែខ្ញុំ ........................................................................ ៥៥
៣៨. ព្រះធម៌ជួយបាន ........................................................................ ៥៦
៣៩. ជួយថែវប្បធម៌ ........................................................................ ៥៧
៤០. ប្រាសាទអង្គរ ........................................................................ ៥៩
៤១. ទឹកចិត្តបងស្រី ........................................................................ ៦០
៤២. កំណាព្យឥតន័យលៃសាយណ្ហះ ........................................................ ៦១
៤៣. កើត-ស្លាប់ ........................................................................ ៦២
៤៤. រតនៈទាំង៣លៃតាមកាព្យ ........................................................ ៦៣
៤៥. ត្រជាក់នឹកម៉ែថៃកូនពីតូច ........................................................ ៦៥
៤៦. បានបុណ្យស័ក្តិខ្ពស់ព្រោះតែព្រះគុណ ........................................................ ៦៧
៤៧. ប្រវត្តិកម្រិស្រីមានចិត្តស្មោះ ........................................................ ៦៨
៤៨. តំណក់ទឹកភ្នែកកូនស្រែករកម៉ែ ........................................................ ៦៩

៤៩. ពុក ........................................ ៧១
៥០. ម៉ែ ........................................ ៧២
៥១. កូន ........................................ ៧៤
៥២. ថ្ងៃបុណ្យណូអែលប្រហែលខ្មែរភ្លេច! ........................................ ៧៥
៥៣. កុំភ្លេចខោនដោន! ........................................ ៧៦
៥៤. ច្បាប់ប្រដៅកូនចៅប្រុសស្រី ........................................ ៧៨
៥៥. អ្វីៗសម្រេចលើចិត្ត ........................................ ៨១
៥៦. អំណាចឫស្យាប្រហារចិត្តស្ងប់ ........................................ ៨២
៥៧. អនុស្សាវរីយ៍ពីអតីត ........................................ ៨៣
៥៨. វាលវដ្តសង្សារមហាសាគរ ........................................ ៨៤
៥៩. ឃ្លាតមាតុភូមិព្រោះខ្ញុំក្រ ........................................ ៨៥
៦០. មេឃភ្លេចដីហើយ! ........................................ ៨៧
៦១. ជំនោរជីវិត ........................................ ៨៨
៦២. តម្លៃជីវិត ........................................ ៨៩
៦៣. ជីវិតឥតន័យ ........................................ ៨៩
៦៤. រលកជីវិត ........................................ ៩០
៦៥. សំនៀងឥតន័យ ........................................ ៩១

៦៦. ស្នេហាយុវវ័យ ........................................................ ៩២
៦៧. មាយបុណ្ណមី ........................................................ ៩៤

# កំណាព្យ សៅ ចាន់ណា

នាល្ងាចថ្ងៃសៅរ៍សំណៅសំណេរ តែងគិតរិះរេសរសេរកាព្យ
ជូនមិត្តប្រុសស្រីគ្រាន់អានគ្រប់គ្នា បាត់ទុក្ខវេទនាថ្ងៃចុងសប្ដាហ៍ ។
ត្រកូលនាមដើមម៉ែដាក់ឱ្យ**សៅ** ពីរោះឆ្អិនឆ្អៅស្របពេញចិន្ដា
ថែមឈ្មោះខ្លួនឯងតែងហៅ**ចាន់ណា** ពីរោះថ្លៃថ្លាខ្ញុំពេញចិត្តក្រៃ ។
កើតមកចំខេត្តអ្នកកំពង់ឆ្នាំង ជាខេត្តមួយបាំងភ្នំនាងកង្រី
ប្រវត្តិស្មោះស្នេហ៍រិទ្ធិសែនមានជ័យ រួមនិងស្រីថ្លៃកង្រីនេះណា ។
ឱ ! ស្រុកបរិបូណ៌ស្ងួរលាន់រងំ ស្រុកកំណើតខ្ញុំតាំងពីកុមារ
ធ្លាប់ផ្ដល់ក្ដីសុខនឹងអនុស្សាវរីយ៍ រស់ឆ្ងាយយ៉ាងណាខ្ញុំមិនភ្លេចឡើយ ។
ខ្ញុំឃ្លាតឆ្ងាយអ្នក៩ឆ្នាំបួយ ឃ្លាតតែរូបកាយចិត្តស្មោះត្រានត្រើយ
ទោះទៅជើងមេឃក៏ស្រែដង្ហោយ កន្លែងហ្នឹងហើយខ្ញុំរស់សុខសាន្ដ ។
ផ្ទះតូចចង្អៀតឃ្លាតគ្នាមិនរួច ក៏ចិត្តខ្ញុំលួចដង្ហួចក្សាន្តត្រាន

កក់ក្តៅឱរារួមផ្សំជាប់ប្រាណ ខ្ញុំប្រៀបនឹងឋានត្រៃត្រឹង្សសួគ៌ា ។
រឭកភូមិស្រុកនឹកពុកនឹកម៉ែ ធ្លាប់រស់ជុំក្បែរសើចស្រស់រកគ្នា
ប្រទាក់ក្រឡាបងប្អូនមីងមា រស់នៅសុខជាឬមួយដែរអី? ។
បានត្រឹមតែនឹករឭករកគ្នា មិនមានវេលាសាសងសម្តី
ខ្ញុំរស់នៅឆ្ងាយឃ្លាតពីទឹកដី ទ្រូងសែនអាល័យដួងចិត្តអាឡោះ ។
បញ្ចប់កាព្យឃ្លោងឃ្លាប៉ុណ្ណឹង រឿងទាំងអស់ហ្នឹងខ្ញុំពោលដោយស្មោះ
ឥតក្លែងបន្លំប្រឌិតឱ្យខុស សូមិត្តស្រីប្រុសសន្តោសឱ្យផង ។
ពន្លកកវីខ្ចីទាំងគំនិត សម្លឹងឆ្ងាយជិតមិនបានផ្តោះផ្តង
តែងឱ្យអស់ន័យជូនជាចំណង សូមចិត្តប្អូនបងមេត្តាករី ។

# ១~ ជិតភ្ជុំបិណ្ឌហើយ កូនអើយដឹងទេ?

រដូវភ្ជុំបិណ្ឌកៀកជិតមកដល់ កូនអើយកុំខ្វល់រូតរះម្នីម្នា
រៀបចំទុកដាក់ភោជននានា ត្រូវខំពុះពារធ្វើបុណ្យនឹងព្រះ ។
ទាន់មានជីវិតកុំគិតវែងឆ្ងាយ ពុកម៉ែពីរកាយកូនត្រូវសំពះ
បង្គំបាទាដាក់ចិត្តមានះ កូនក្រាបសំពះបានបុណ្យច្រើនក្រៃ ។
ងូតទឹកដុសកាយម្តាយហើយនិងពុក រាយជាទំនុកកូនភ្ជាប់និស្ស័យ
បានបុណ្យច្រើនណាស់គ្រប់ពេលយប់ថ្ងៃ ឱ ! មាសថ្លើមថ្លៃកូនមានដឹងទេ? ។
ស្តាប់ធម៌នៅវត្តឃាត់ចិត្តអប្រិយ ចូរកូនប្រុសស្រីស្តាប់តាមពុកម៉ែ
កុំឃើញគេល្អបាត់ការមើលថែ កូនអើយពុកម៉ែចាស់ៗណាស់ហើយ ។
ព្រះរស់នៅមានកូនកុំរំលង បើកូនខុសឆ្គងណាមាសត្រានត្រើយ
បញ្ចេញវាចាកូនកុំអៀនឡើយ ឱ ! ព្រះរស់អើយកូនសូមអត់ទោស ។
កុំឱ្យមានបាបដល់ជាតិខាងមុខ ព្រោះតែម៉ែពុកកូនភ្លេចសន្តោស
ធ្វើបាបចិត្តគាត់វាយជាកំហុស បើបានជាខុសត្រូវកែខ្លួនឡើង ។
ខុសមួយខុសពីររហូតខុសដប់ គ្មានទីបញ្ចប់ទេណាកូនអើយ
បើកូនកែខ្លួនពីនេះឱ្យហើយ ថ្លៃមាសត្រានត្រើយពិតស្រាលកំហុស ។
ជិតភ្ជុំបិណ្ឌហើយកូនអើយដឹងទេ? ពុកម៉ែនៅស្រែកូនដឹងមុនចុះ

គាត់មានសង្ឃឹមនឹងកូនស្រីប្រុស　　កូនដឹងមុនចុះស្រួលត្រៀមខ្លួនធ្វើ ។

# ២. កវីតែងជូន ជំនួនមុនឆ្នាំ

គំនិតនៅខ្ចីសម្តីពីរោះ　　គ្មានទេស័ក្តិយសតែចង់តែងជូន
បានចែករំលែកពាក្យកាព្យចុងជួន　　ដូចមានសំនួនតទៅនេះថា ។
កំណើតជាមនុស្សដ៏ល្អប្រពៃ　　ចូរជនប្រុសស្រីរិះគិតពិចារណ៏
នៅក្នុងដំណើរអាយុសង្ខារ　　ពិតប្តូរផ្លាប់ផ្លារជារៀងរាល់ថ្ងៃ ។
ពីក្មេងដល់ចាស់ផ្លាស់ឥតលើកលែង　　ទុក្ខសោកសង្រេងចេញពីដួងចៃ
ខំប្រឹងកែកុនតាមក្តីស្រមៃ　　តែដូចឥតន័យបានអ្វីមកសោះ ។
ច្រមុះនូវតូចខួចមិនសូវសម　　ពិតតែបន្ទំលាបផ្សំប៉ះចោះ
ឱ្យភ្នែកអ្នកផងឃើញល្អឥតខ្ចោះ　　អួតរាងសម្រស់អស់គេវង្វេង ។
មុខពងក្រពើមើលល្អឥតទាស់　　រូបរាងក៏ស្រស់រោមភ្នែកក៏វែង
គួរឱ្យចាប់ចិត្តគំនិតបែកឆ្វេង　　អ៊ោះអ៊ោ ! សំឡេងក៏ពីរោះដែរ ។
កូនចៅអ្នកណាសង្ហាអ្វីម្ល៉េះ !　　ខ្ញុំឃើញដូច្នេះចាប់ចិត្តរីតស្នេហ៏
បេះដូងខ្ចូលខ្ចាញ់ចង់នៅក្បៀកក្បែរ　　ចង់ថ្នាក់ថ្នមថែរហូតអវសាន្ត ។

ចិត្តសែនរីវក់ឈ្លក់នឹងសម្រស់ ឥតបានអ្វីសោះដូចឃ្លាតចាកឋាន
បញ្ចកាមគុណមានគ្រប់តែប្រាណ ចិត្តដូចស្រោកស្រាន្តព្រោះបានរកធម៌ ។
ការគិតស្រមៃប្រល័យដួងចិត្ត អាចកើតវិប្បរិតដូចស្វាជាប់ដ័រ
ដាក់អីជាប់ហ្នឹងឥតបាច់អង្វរ ទាបខ្ពស់ខ្មៅ.ស ស្លាប់ទាល់តែអស់ ។
ច្បាប់ពិចារណាវាសនាកំណត់ មានពិតប្រាកដឥតបាំងអ្វីសោះ
តែមនុស្សមិនឃើញដើរចូលប្រឡោះ ថ្ងៃក្រោយវិញនោះរងទុក្ខខ្លោចផ្សា ។
ដឹងពេលនេះហើយចូរស្បើយក្ដីទុក្ខ ថ្ងៃក្រោយថ្ងៃមុខសូមក្ដីប្រាថ្នា
ឱ្យបានសម្រេចគ្រប់រូបមនុស្សា បានដូចប្រាថ្នាដែលអ្នកបានប៉ង ។
កវីតែងជូនជំនូនមុនភ្ជុំ សូមរស់ជួបជុំថ្លៃថ្លាកន្លង
ឱ្យបានសម្រេចដូចក្ដីបំណង សូមឱ្យផុតឆ្លងដល់បរលោកនាយ ។
កំហុសខុសឆ្គងទំនងមិនសម ឥតក្លែងបន្លំសមតាមពណ្ណរាយ
សូមអធ្យាស្រ័យលោកតាលោកយាយ ដូចមានសេចក្ដីខាងលើនេះឯង ។
មុននឹងលាទៅសូមផ្លូវឱកាស ជូនបុណ្យចាស់ៗនិងសង្ឃគម្ដែង
សូមកើតឋានសួគ៌ទីសុខក្រៃលែង ទាំងចាស់ទាំងក្មេងរហូតនិព្វាន ។

# ៣~ ទៅបុណ្យភ្ជុំបិណ្ឌ

១រោចភទ្របទថ្ងៃសុទ្ធប្រពៃ សូមញាតិប្រុសស្រីរិះគិតគ្រប់គ្នា
ថ្ងៃឈប់សម្រាកពីមុខការងារ ទៅវត្តនានាសន្សំកុសល ។
វេលាធ្វើបុណ្យមាន១៥ថ្ងៃ ឆ្លៀតចូលបច្ច័យដូរយកមគ្គផល
ធ្វើបុណ្យនឹងលោកៗតែងជួយផ្តល់ បានបុណ្យកុសលត្រលប់ទៅផ្ទះ ។
ដាក់បិណ្ឌទី១រញ្ជួយវត្តវ៉ា ប្រេតញាតិការស្រេកឃ្លានក្រពះ
ឧទ្ទិសបុណ្យផងរួចសុំសំពះ សូមញាតិជាម្ចាស់អនុមោទនា ។
ធ្លាក់ទៅជាប្រេតហេតុតែអត់ឃ្លាន ទុក្ខសោកមែនទែនឈឺចាប់វេទនា
ព្រោះហេតុធ្វើបាបចូរដឹងគ្រប់គ្នា រស់រងកម្មពៀរទម្រាំអស់កម្ម ។
បើដឹងខ្លួនហើយចូរគេចឱ្យផុត ថ្ងៃក្រោយស្រយុតបាត់ការចងចាំ
ទម្រាំភ្ញាក់ខ្លួនរងទុក្ខប្រេះស្រាំ ណ្ហើយខ្ញុំផ្តាំប៉ុណ្ណឹងទៅចុះ ។

# ៤. កំណាព្យ ក.ខ ចូរកុំខឹងក្រោធ

ក កុំខឹងក្រោធនឹងបុគ្គលណា ខ ខំឧស្សាហ៍ព្យាយាមខន្តី
គ គិតរាល់ថ្ងៃមុនពេលស្រដី ឃ ឃើញអ្វីៗដាក់ចិត្តមេត្តា ។
ង ងំក្នុងប្រាណឥតបានអ្វីសោះ ច ចិត្តត្រង់ស្មោះក្នុងធមិករុណា
ឆ ឆាប់សម្លឹងក្នុងអង្គអាត្មា ជ ជែកតវ៉ាកុំហាឡើងស្តី ។
ឈ ឈប់សាងបាបឆ្អេះឆ្អាបក្នុងប្រាណ ញ ញឹមកល្យាណបានទេប្រុសស្រី
ដ ដឹងហើយធ្វើកុំឡើយហឺៗ ឋ ឋិតក្នុងអ្វីស្រដីតាមកាល ។
ឌ ឌឺដៀមដាមអាចនាំជម្លោះ ឍ វឌ្ឍនះរស់ឱ្យបានថ្កើនថ្កាន
ណ ណាយក្នុងបាបជាគ្រឿងសាមាន្យ ត តាំងសន្តានឱ្យបានមាំមួន ។
ថ ថៃសុខភាពឱ្យបានរស់យូរ ទ ទៅគិតគួរឱ្យដឹងពីខ្លួន
ធ ធំណាស់ហើយត្រូវខំថែថួន ន នាំបងប្អូនសាងតែសុចរិត ។
ប បើកបេះដូងឱ្យបានទូលាយ ផ ផលសម្ពាយឥតអ្វីបាំងបិទ
ព ពឹងខ្លួនឯងឱ្យបានស្នេហ៍ស្និទ្ធ ភ ភាំងគំនិតពិតជាវង្វេង ។
ម មនុស្សឥឡូវកុំសូវទុកចិត្ត យ យល់គំនិតកុំគិតអ្វីផ្សេង
រ រឿងច្រើនណាស់កុំផ្លាស់ទៅឆ្វេង ល លួចលាក់លេងអាចកើតទំនាស់ ។
វ វាំងភាំងចិត្តប្រឌិតរឿងខុស ស សល់កំហុសទៅជាទោមនស្ស

**ហ** ហិនខ្លួនឯងព្រោះតែចិត្តទាស់ **ឡ** ឡើងប្រឹងអស់បន្ទោសទោសា ។
**អ** អស់ប៉ុណ្ណឹងប្រឹងទាំងអស់គ្នា កវីសូមលាបងប្អូនយាយតា
តែងទៅមិនសមខុសច្បាប់អក្ខរា សូមចិត្តមេត្តាជួយកែឱ្យផង ។

# ៥-  សម្តីខុសការប្រហារអ្នកស្តាប់

បញ្ចេញវាចាប្រហារដួងចិត្ត ទ្រូងស្មើរបែកឆ្អិតព្រោះតែសម្តី
ចិត្តគ្មានករុណាមេត្តាប្រណី ឱ្យដួងហឫទ័យខ្ទេចខ្ទាំឱរ៉ា ។
អាមឹងឯងហងផ្តោះផ្តងច្រើនណាស់ សម្តីក្រឡាស់ឥតពិចារណា
ធ្វើឱ្យអ្នកស្តាប់កើតធមិហិង្សា អោ៎ះអោ៎ ! វាចាខ្លាំងក្លាអ៊ីម្ល៉េះ ។
ពោលពាក្យពីរោះគោះចិត្តអ្នកស្តាប់ ចិត្តបានកួចក្តាប់មិនហ៊ានប្រហែស
ខំប្រឹងសិក្សាស្វែងរកចំណេះ ពោលល្អយ៉ាងនេះសម្តីទឹកឃ្មុំ ។
អ្នកផ្សេងខ្លះទៀតពោលពាក្យចាក់ដោត ចិត្តឆេវច្រឡោតក្តៅឡើងអួលងំ
មនុស្សផងទាំងឡាយបាត់ភាពគួរសម បើពោលឱ្យចំសម្តីលាមក ។
ពោលមានប្រយោជន៍ហោចត្រូវតាមកាល រក្សាព្យាបាលកួចគិតនឹកភ្នក
ឱ្យអ្នកដទៃទទួលកាន់យក នេះហើយពន្លកនៃអ្នកចេះដឹង ។
កុំអាលឡើងខឹងកុំអាលឡើងស្តី គ្មានត្រាប្រណីដល់មនុស្សផងហ្នឹង

នាំឱ្យមានបាបក្លាយទៅជាខឹង សម្ដីអឺចឹងហៅផតគម្រប ។
ពោលពាក្យថ្លៃថ្លាវាចាបណ្ឌិត ខុសពីពាលពិតព្រោះចិត្តឃុំគ្រង
ពេលលោកវាចាត្រូវបែបទំនង មិនឱ្យអ្នកផងកើតបាបព្រោះលោក ។

# ៦. កូនសូមលាទោសដែលខុសលើម៉ែ

កូនសូមឱនកាយក្រាបថ្វាយបង្គំ អ្នកម្ដាយភិរម្យមានគុណពេកក្រៃ
ដែលខំបីបាច់រាល់ពេលយប់ថ្ងៃ កូនសូមលើកដៃស្នាលាទោសា ។
សែនស្ដាយកំហុសដែលខុសលើម៉ែ រាល់ថ្ងៃច្រើនខែម៉ែតែងវាចា
អប់រំបន្ទុំកូនក្នុងហត្ថា ទឹកសៀងវាចាម៉ែច្រៀងបំពេ ។
កូនបានជាខុសសន្ដោសប្រណី មេត្តាស្រដីអត់ទោសទាំងទ្វេ
ឃប់សាងកំហុសធ្វើទុក្ខលើគេ កូនមិនឯាករេធ្វើបុណ្យជូនព្រះ ។
ពាក្យពេចន៍ម៉ែពោលរំជួលចិត្តកូន ជាស្ពានជាក្បូនកូនក្រាបសំពះ
សម្ដីថ្លាថ្លៃមានជ័យជម្នះ កូនក្រាបសំពះបានបុណ្យណាស់ម៉ែ ។
ស្រីដែលយកចិត្តអាណិតរូបខ្ញុំ ដ៏ល្អិតសុខុមមើលថ្នាក់ថ្នមថៃ
ស្រីនោះមិនមែនជាស្រីផ្សេងទេ គឺជារូបម៉ែម្ចាស់ជីវិតកូន ។

ភ័ព្វព្រេងវាសនាចារជាប់ដួងចិត្ត បាននៅស្នេហ៍ស្និទ្ធឥតបាត់បង់សូន្យ
កើតចំម៉ែល្អទុកដាក់បងប្អូន ពោលរៀបរាប់ជូនជាពាក្យប្រដៅ ។
កូនមានសង្ឃឹមញញឹមក្នុងចិត្ត ម៉ែតែងអាណិតប្រាប់ប្រុងក្នុងក្រៅ
អត់ទោសឱ្យកូនជាមនុស្សល្ងង់ខ្លៅ ពាក្យម៉ែប្រដៅកូនចាំទាំងអស់ ។
សរុបអត្ថន័យដែលខ្ញុំរៀបរាប់ មានជាបន្ទាប់តែងជូនដោយស្មោះ
សូមអស់ប្រុសស្រីចិត្តកុំក្រៀមក្រោះ អ្វីណាទាំងនោះខ្ញុំតែងជូនហើយ ។
សូមសោយសុខសាន្តបានគ្រប់ៗគ្នា ទុក្ខសោកវេទនាកុំបៀតបៀនឡើយ
រស់ជុំគ្រួសារចុះណាត្រានត្រើយ កវីលាហើយសូមអនុមោទនា ! ។

# ៧~ ភ្លៀងធ្លាក់ត្រជាក់កាយ

វស្សារដូវត្រូវថ្ងៃអាទិត្យ ភ្លៀងច្រើនពេកពិតនៅកំពង់ឆ្នាំង
កាយខ្ញុំញ័រញាក់ត្រជាក់យ៉ាងខ្លាំង ភ្នែកក៏ស្រវាំងព្រោះអ័ព្ទរស្មី ។
តំណក់ទឹកភ្លៀងច្រៀងផ្តាំខ្ញុំហើយ ឱ្យផុតទុក្ខស្បើយដោយចិត្តភក្តី
ខ្ញុំត្រេកអរណាស់លើសពីពោលស្តី ដូចមានអ្វីៗនៅក្នុងជីវិត ។
ស្រោចស្រពពសុធានាខែវស្សា ក្មេងចាស់កុមារសប្បាយពេកពិត

ព្រោះអីថ្ងៃមិញមេឃក្ដៅជុំជិត ពេលនេះវរមិត្តត្រជាក់កាយហើយ ។
ទុក្ខខ្លាំងផ្លូវកាយតែសប្បាយចិត្ត ក្នុងមួយជីវិតសែនស្រស់ល្ហៃល្ហើយ
កុំបាច់តូចចិត្តនាំទុក្ខឥតស្បើយ ញាតិប្រុសស្រីអើយចូរចាំគ្រប់គ្នា ។
យប់ថ្ងៃផុតទៅនៅសល់អ្វីទៀត បើស្លាប់ព្រោងព្រាតគ្រប់រូបអង្គា
ទោះទៅទីណាក៏ត្រូវវេទនា ល្ហើយមឹងមាឈប់គិតច្រើនទៅ ។
ភ្លៀងធ្លាក់ជោកជាំរេរាំស្រូវស្រែ នឹកពុកនឹកម៉ែចិត្តដិតជាប់នៅ
ណាមួយគាត់ចាស់ជរារាងរៅ មិនអាចឋិតនៅរហូតនោះទេ ។
គាត់ខំរកប្រាក់ចិញ្ចឹមបុត្រភ្ញា ទោះបីវេទនាក៏មិនត្អូញដែរ
ចង់ឱ្យមាសម៉ុមបានរស់នៅក្បែរ គាត់ថ្នាក់ថ្នមថែអស់មួយជីវិត ។
ស៊ូទ្រាំព្យុះភ្លៀងរៀងរាល់វស្សា មានចិត្តករុណាមេត្តាអាណិត
ដល់កូនទាំងឡាយម៉ែស្នេហ៍ស្និទ្ធពិត ចង់នៅនែបនិត្យនឹងកូនពិសី ។

# ៨. ធ្វើបុណ្យ បុណ្យជួយ

បុណ្យអើយៗបុណ្យមានគុណក្រៃក្រាស់ ខ្ញុំកោតអ្នកណាស់ជួយអង្គអាត្មា
ផុតពីអន្លង់ជាភពខ្លោចផ្សា សូមក្តីប្រាថ្នាធ្វើបុណ្យគ្រប់គ្នា ។
ជាតិនេះជាតិមុខមិនត្រូវបណ្តោយ ចិត្តស្រែកដង្ហោយហៅគ្រប់អង្គា
ប្រញាប់រូតរះទាន់រូបជានា ប្រយ័ត្នវេទនាធ្វើបុណ្យលែងកើត ។
ធ្វើបុណ្យបុណ្យជួយឱ្យផុតក្តីទុក្ខ បញ្ញាស្វាញស្មុគតែងមានកំណើត
ដុះចេញពីចិត្តឃើញភាពល្អឆើត ភ្លេចកោតញញើតបាបអកុសល ។
ប្រឹងទាន់នៅក្មេងរែងនៅចាំល្អ ច្រើនជាតិតំណបុណ្យតែងជួយផ្តល់
កើតក្នុងត្រកូលសុភមង្គល រៀងរហូតដល់ថ្ងៃក្ស័យសង្ខារ ។
ដំណើរសង្ខារចារជាប់ជានិច្ច រស់គ្មានថ្ងៃភ្លេចពីក្តីមរណា
ធ្វើបុណ្យបុណ្យជួយគ្រប់អង្គអាត្មា សូមចិត្តសច្ចាធ្វើបុណ្យតទៅ !។

# ៩. ដើម្បីជីវិត

ថ្ងៃរះពីកើតឆើតស្រស់ពណ្ណរាយ ធ្វើឱ្យហឫទ័យស្ងប់ស្ងែងកន្លង
មានព្រះវាយោបក់ផាត់ឆ្លើយឆ្លង ស្លឹកឈើផ្ដោះផ្ដងបំណងសាយសព្វ ។
សំឡេងសារិកាចារពីចម្ងាយ ធ្វើឱ្យរូបកាយខ្ញុំសែនស្ងើចស្ងប់
អនិច្ចាជីវិតគ្មានទីបញ្ចប់ ស្លាប់កើតមានគ្រប់សព្វសត្តនិករ ។
ព្រឹកទល់ព្រលប់យប់គ្មានសម្រាក ធ្វើការតោកយ៉ាកខំរស់ត្រដរ
ដើម្បីជីវិតមិនគិតមានក្រ ទាបខ្ពស់ខ្មៅ.ស ក៏ជីវិតដែរ ។
រសជាតិជីវិតពិតបែបនេះឯង គ្មានការបែកផ្សេងទៅណាឆ្ងាយទេ
រស់មួយក្រពះគ្រប់អស់យើងគេ គួរខិតខំថែជីវិតខ្លីណាស់ ។
ថ្ងៃនេះជួបជុំថ្ងៃក្រោយប្រាស់ព្រាត់ គ្មានអ្នកពង្រាត់គួរដឹងឱ្យច្បាស់
អំណាចសង្ខារមានកើតប្តូរផ្លាស់ គ្រប់វ័យក្មេងចាស់មិនគិតឡើយណា ។
ដឹងថ្ងៃនេះហើយគួរធ្វើឱ្យឆាប់ រួតរះប្រញាប់ក្រែងខូចកិច្ចការ
ព្រោះអីជីវិតតែងប្តូរផ្កាប់ផ្ងារ គួរចិត្តម៉ឺម្នាពីពេលនេះទៅ ។
ធ្វើឃឹតបន្តិចច្បិចពេលឱកាស រព្វកតឿនដាស់ចិត្តផ្លាស់មិននៅ
ពិតឃ្លាតចាកបុណ្យដ៏ល្អពេកកូវ ឆាប់ស្រួតឥឡូវទាន់មានជីវិត ។
ស្លាប់កើតៗកំណើតគ្រប់ជាតិ មានអ្វីមិនឃ្លាតខុសពីការពិត

ដំបូងសម្គាល់ថាល្អប្រណិត ថ្ងៃក្រោយនោះពិតឃ្លាតឆ្ងាយសែនឆ្ងាយ ។
ដើម្បីជីវិតគិតគ្រប់នាទី ត្រូវខំសម្ដីមិនត្រូវក្អាកក្អាយ
សន្សំកុសលធ្វើបុណ្យទាំងឡាយ ដើម្បីជិនណាយក្នុងភពងងឹត ។

# ១០~ សភាវៈពិតនៃរូបកាយ

រូបកាយមានកម្មចាំតែពង្រាត់ ធ្វើម្ដេចនឹងឃាត់ឱ្យឋិតថេរបាន
រាងកាយទ្រុឌទ្រោមត្រូវឃ្លាតចាកឋាន ចង់ឱ្យខ្លួនប្រាណរស់យូរម្ដេចទៅ ។
ពីតូចដល់ធំផ្ដុំរោគគ្រប់មុខ គ្មានទេក្ដីសុខចាស់អស់រាងរៅ
ដំបូងសក់ខ្មៅឥឡូវសក់ស្កូវ ចង់ឱ្យតាំងនៅយឺនយូរម្ដេចបាន ។
ផ្លាស់ប្ដូររាល់ថ្ងៃឥតនរណាដឹង ពិតតែខំប្រឹងឥតមានស្រាកស្រាន្ដ
វិវត់វង្វេងគ្រប់រូបគ្រប់ប្រាណ ចង់បានក្មេងក្សាន្ដតែមិនខំធ្វើ ។
ធ្មេញបាក់សក់ស្កូវតាំងនៅមិនយូរ ឥតបានគិតគួរចាស់គ្រប់អន្លើ
ព្រះធម៌មានហើយមិននាំគ្នាជឿ រុះរោយរង្កើរហួតចាស់ស្លាប់ ។
រូបកាយឥតខ្លឹមចិញ្ចឹមឥតគុណ មានតែទារុណនរកចាក់កាប់
បើចិត្តមានធម៌ល្អមួយសម្រាប់ ដង្ហោយប្រាយប្រាប់ឱ្យដឹងគ្រប់គ្នា ។

ចាស់ៗស្លាប់ដោយជរារូបកាយ ឯក្មេងទាំងឡាយប្រឹងប្រែងម្ទឹម្ទា
រស់នៅសព្វថ្ងៃសាងបាបគ្រប់គ្រា មិនព្រោះជរាតែព្រោះភ្លើតភ្លើន ។
គួចគិតសម្បថកំណត់ឱ្យយល់ រស់នៅអំពល់នាំធ្លាក់ភ្លុកភ្លើង
រស់មានមេត្តាវាសនាពួកយើង អនាគតរុងរឿងព្រោះតែចិត្តល្អ ។
ចេះជួយសង្គ្រោះសាច់ញាតិភូមិផង មានញាតិប្អូនបងឱ្យបានបវរ
ទើបអាចសម្រេចទៅជាញាតិធម៌ ថ្លៃថ្លាបន្តអ្នកភូមិខ្លួនឯង ។
ទឹកចិត្តសប្បុរសផ្សព្វផ្សាយទូទៅ ប្រៀបដំណើរផ្លូវគួរដឹងជាក់ស្ដែង
មគ្គអង្គប្រាំបីដ៏ល្អក្រៃលែង គោរពកោតក្រែងឋានសួគ៌រងចាំ ។

## ១១. អាសូរពួកប្រេត !

ព្រឹកព្រាងរៀងរះជះចាំងរស្មី អរុណោទ័យថ្ងៃថ្មីមកដល់
ពន្លឺចាំងចែងថ្លែងមិនចេះខ្វល់ រសាប់រសល់នៅមិនសុខទេ ។
ព្រលឹមបាត់ទៅនៅសល់ពន្លឺ ម៉ោង៥ទៀបភ្លឺព្ទស្នូរតែគេ
រហូតថ្ងៃរះចាំងចែងឡើងទ្វេ នៅមិនសុខទេដើររកចំណី ។
អាសូរពួកប្រេតគ្មានឆ្អែតមួយថ្ងៃ ព្រោះតែនិស្ស័យកើតមកអត់ឆី

ស៊ូទ្រាំលំបាកមិនអាចហាស្តី ដូច្នេះប្រុសស្រីមិនអាចដឹងទេ ។
ប្រេតខ្លះមួយជាតិស៊ូឃ្លាតភូមិឋាន ឱ្យតែរកបានបាយទឹកនឹងគេ
ពេលខ្លះសុខចិត្តអត់ខ្លួនឯងដែរ ព្រោះថ្នាក់ថ្នមថៃឱ្យកូនខ្លួនវិញ ។
ច្រក់ៗតាមជ្រាំទម្រាំពេញពោះ គ្មានថ្ងៃណាលស់រស់យ៉ាងទោម្ទេញ
វេទនាលំបាកគ្មានផលចំណេញ នេះហើយប្រដេញនឹងកម្មវាសនា ។
កំណើតជាមនុស្សដ៏ល្អប្រពៃ គួរយើងលកលៃឱ្យគ្រប់កិច្ចការ
បុណ្យទានក៏ធ្វើសីលក៏រក្សា ទើបឱ្យឈ្មោះថាមនុស្សមានកំណើត ។
រស់នៅឥតធមិបង្កជម្លោះ នាំភ័យរងគ្រោះដល់ជាតិដែលកើត
វិវក់វង្វេងភ្លេចគិតស្លេតស្លើត អនាគតល្អឆើតបានកើតប្រេតហើយ ។

## ១២~ ប្រកបកិច្ចការដូចខ្មសន្សាហ៍រៀន

ថ្ងៃថ្មីមកដល់វិលវល់រងទុក្ខ បញ្ហាច្រើនមុខត្រូវធ្វើបន្ត
មិនដូចបក្សាលីលាត្រាច់ចរ ទៅតាមលម្ហអាកាសវេហាស៍ ។
កិច្ចការច្រើនមុខទុកចោលមិនបាន ក្រែងលោខកខានមិនបានធ្វើវា
នាំហិនប្រយោជន៏ខូចគ្រប់ការងារ ត្រូវខំពុះពារធ្វើឱ្យហើយទៅ ។

អ្វីណាទុកបានក៏អាចទុកសិន តែចិត្តត្រូវប៉ិនធ្វើដឹងរាក់ជ្រៅ
កុំចេះតែហ៊ានពានពាក្យប្រដៅ ធ្វើទាំងល្ងង់ខ្លៅមិនចេះគិតសោះ ។
ភារៈធ្ងន់ស្រាលជាកិច្ចចាំបាច់ ផលល្អសម្រេចធ្វើមិនចេះទាស់
ចុងក្រោយផលនោះសម្រេចទាំងអស់ ព្រោះតែស្មគ្រស្មោះនិងកិច្ចការងារ ។
បញ្ហាច្រើនណាស់ច្បាស់ដោះស្រាយបាន តិចច្រើនកុំខានរួមបានជាគ្នា
ទោះបីតិចច្រើនគង់ផលល្អជា ផុតកម្មវេរាលាកាមលោកិយ ។
យ៉ាងណាព្រះធម៌ក៏ដូច្នោះដែរ គួរខិតខំថែឱ្យបានប្រពៃ
ប្រឹងរៀនប្រឹងស្តាប់រាល់ពេលយប់ថ្ងៃ សន្សំនិស្ស័យជួបព្រះជាតិក្រោយ ។
រៀនពីឥឡូវមិនសូវខាតពេល បង់ប្រាក់ច្រើនរៀលកុំធ្វេសបណ្តោយ
ទាន់ខ្លួននៅក្មេងបញ្ញាមិនខ្សោយ ចំណេះដង្ហោយហៅរកយើងហើយ ។
ប្រយ័ត្នដល់ចាស់ច្បាស់ជាវង្វេង បញ្ញាបែកឆ្វេងជរាឥតស្បើយ
ភ្នែកក៏ងងឹតគ្មានឃើញកោះត្រើយ ដូចបានពោលហើយនៅក្មេងខំរៀន ។

# ១៣. គុណលោកឪពុក

គុណលោកឪពុកទុកជាគំរូ លះបង់តស៊ូដើម្បីបុត្រថ្លៃ
ស៊ូនឿយខ្លួនឯងឱ្យតែចរណៃ ពីព្រឹកទល់ថ្ងៃឪពុកនឿយណាស់ ។
ធ្វើការរាល់ថ្ងៃដើម្បីបុត្រស្ងួន តែរូបកូនៗមិនដឹងគុណច្បាស់
ពិតតែមើលងាយបន្ទោកឱ្យព្រះ យកចិត្តចង់ឈ្នះឪពុកខ្លួនឯង ។
ឪពុកស្ដីថាវាចាឱ្យល្អ ឱ្យមានគុណធមិក្នុងចិត្តជាក់ស្ដែង
ចេះថ្វាយបង្គំគោរពកោតក្រែង ឪពោលក្ដែងៗដើម្បីកូនថ្លៃ ។
ស្ដាប់ឱវាទឪជាផ្លូវបានសុខ កាត់ភាពស្នាញស្មុគដែលមានរាល់ថ្ងៃ
គោរពពាក្យពេចន៍ប្រៀបបានម្កុដថ្មៃ កូនមាននិស្ស័យបានឪទូន្មាន ។
មើលកូនគេខ្លះឪឥតរាប់រក រស់នៅទៅមកព្រោះភាពអត់ឃ្លាន
ធ្វើការខ្លួនឯងយកប្រាក់គ្រាន់រៀន វិជ្ជាកើតមានដល់អ្នកឧស្សាហ៍ ។
ចុះយើងរាល់ថ្ងៃលុយក៏មានចាយ ហ៊ឺហាសប្បាយទៅតាមទីផ្សារ
ដេកសុទ្ធតែពូកមានសុទ្ធវីឡា គ្មានដែលគិតថាភាពក្រលំបាក ។
ខំប្រឹងរៀនសូត្រដើម្បីចំណេះ យកភាពដឹងចេះកាត់ការតោកយ៉ាក
ដែលធ្លាប់នឿយហត់ពីមុនឥតស្រាក ឥឡូវសម្រាកព្រោះការងារល្អ ។
វិជ្ជាប៉ុន្មានដែលកូនមានហើយ កូនកុំភ្លេចឡើយភាពស្អាតបវរ

សម្បត្តិទាំងនេះព្រោះឱមានធមិ ដោយចិត្តស្មោះសរទូន្មានប្រាប់កូន ។
គុណឪមានច្រើនកើតកើនខ្លាំងណាស់ កូនក្រាបសំពះទៅណាកូនស្ងួន
បុណ្យច្រើនខ្លាំងណាស់កើតឡើងផ្ទួនៗ ព្រោះអីរូបកូនចេះដឹងគុណលោក ។
មិនថានៅមុខឬក៏នៅក្រោយ កូនកុំបណ្តោយតែងមានជ័យជោគ
សត្រូវទាំងឡាយមិនហ៊ានចូលមក មានតែទឹកភ្នែកគោរពកូនវិញ ។
មិនថាជាតិនេះឬក៏ជាតិក្រោយ ឱ ! មាសស្ងួនអើយកូនកុំទោម្នេញ
បុណ្យតាមជាប់កូនគ្រប់ពេលនោះមិញ កូនត្រូវទន្ទេញថាគុណឪពុក ។
សម្បត្តិសុខស្ងួតកូនពិតជាបាន មិនឱ្យខកខានហើយមិនបាត់មុខ
ទោះកើតទេវតាក៏កូនបានសុខ ព្រោះតែគុណពុកជួយកូនគ្រប់ពេល ។
ពន្លឺចាំងជះរះពេញវិមាន មិនអន្តរធានអ្នកផ្សេងរាបរៀល
ចាញ់តេជះកូនព្រោះកូនខំរៀន គុណលោកជាស្ពានរៀនគ្រប់ៗជាតិ ។
អ្នកផ្សេងមានតែខ្លបខ្លាចមកលើ ព្រោះតែកូនធ្វើសព្វគ្រប់មារយាទ
កូនពុកល្អណាស់ពុកមិនចង់ឃ្លាត បានកូនគ្រប់ជាតិក៏ពុកព្រមដែរ ។
រៀបរាប់មកនេះឪគ្រាន់តែប្រាប់ និយាយរាយរ៉ាប់ប្រាប់កូនមាសមេ
អំពីសម្បត្តិដែលអស់យើងគេ រមែងតែងតែបានព្រោះដឹងគុណ ។
ជាទីបញ្ចប់ឪសូមលាកូន លាលុះថ្ងៃសូន្យកូនអស់ទារុណ
ឪប្រាប់ហើយប្រាប់ថាខំធ្វើបុណ្យ ជាតិក្រោយឬមុនកូនអស់កម្មពៀរ ។

គុណលោកឪពុកធំធេងក្រៃក្រាស់ ព្រោះលោកបានត្រាស់អស់កម្មវេរា
ជាទីបញ្ចប់សូមញាតិគ្រប់គ្នា ត្រូវពោលពាក្យថាគុណលោកឪពុក ។

# ១៤_ បណ្ឌិត

សុភាពរាបសាវាចាពីរោះ មានកេរ្តិ៍មានឈ្មោះនៅក្នុងសង្គម
ពាក្យពេចន៍ថ្លាថ្លៃងបទបែបសមរម្យ សាកសមរម្យទុំប្រពៃខ្លាំងណាស់ ។
ឫកពាគួរគាប់ជាប់ដួងហឫទ័យ ពាក្យពេចន៍វែងខ្លីមានន័យហើយច្បាស់
គួរកត់ចំណាំគ្រប់វ័យក្មេងចាស់ ដើម្បីតឿនដាស់សតិគ្រប់កាល ។
អាកប្បកិរិយាវាចាសុភាព រាក់ទាក់រាប់រៀបរឿងរ៉ាវដំណាល
ទេសនាច្បងច្បាស់មានន័យធ្ងន់ស្រាល គ្រប់ពេលគ្រប់កាលលោកតែងអប់រំ ។
សម្ដែងតាមធម៌បវរមានន័យ មានអត្ថសេចក្ដីជ្រាលជ្រៅយ៉ាងធំ
ធ្វើឱ្យអ្នកស្ដាប់ទូន្មានបន្ទុំ មានន័យទូលំសម្រាប់បដិបត្តិ ។
អ្នកនោះឈ្មោះថាជាប្រាជ្ញបណ្ឌិត ករីជុំជិតតែងមកប្រតិបត្តិ
គោរពបូជាតាមធម៌បរិយត្តិ កិលេសខ្ចាយខ្ចាត់ព្រោះសេពសប្បុរស ។
នៅជិតអ្នកប្រាជ្ញគួរអប់រំចិត្ត បណ្ដុះគំនិតដោយចិត្តស្ម័គ្រស្មោះ

ក្រេបរសព្រះធម៌ដោយល្អឥតខ្ចោះ ចិត្តឥតអាឡោះក្នុងកាមគុណ៥ ។
សិក្សាចងចាំចំណាំកត់ត្រា ក្នុងត្រៃសិក្ខាដែលលោកផ្ដែផ្ដាំ
យកមកសញ្ជឹងរំពឹងចងចាំ គ្រប់ពាក្យបណ្ដាំកត់ត្រាក្នុងចិត្ត ។
ពេលកើតជាតិក្រោយពិតបានឋានសួគ៌ កំណើតថ្លៃថ្នូរឥតមានវិប្បរិត
អវសាន្តនៃជាតិមិនភ្លាត់គំនិត បាននៅក្បែរជិតនឹងព្រះនិព្វាន ។

# ១៥~ ពាល

សម្ដីឥតជាតិមារយាទទាបថោក ដំណើរទៅមកមិនសមនឹងប្រាណ
ធ្វើឫករឹងខែងចិត្តគ្មានស្រាកស្រាន្ត ប្រៀបប្រដូចបាននឹងមនុស្សឥតធម៌ ។
ដឹកនាំធ្វើបាបឆ្មេះឆ្មោបក្នុងចិត្ត ភ្លាំងភ្លាត់គំនិតចិត្តឥតថ្លាល្អ
សាងតែវេរារស់គ្មានបវរ ដំណើរត្រាច់ចរក៏អាក្រក់ដែរ ។
ចិត្តជោកដោយកាមតាមជាប់ជានិច្ច រស់នៅបើកធ្មេចមិនគួរឱ្យក្បែរ
វិតក្កៈទាំង៣កើតជាប់ហូរហែ មិនងាយកែប្រែអាក្រក់គ្រប់ជាតិ ។
បើបានរស់ជិតពិតកើតហ្មងសៅ រួមរស់និត្យនៅគួរចង់ឱ្យឃ្លាត
បើមោយយ៉ាងហ្នឹងត្រូវធ្វើម្ដេចទៀត ចិត្តសែនគ្រោតគ្រាតជាងអ្វីទាំងអស់ ។

អ្នកនោះឈ្មោះថាជាពាលឃោរឃៅ ចៀសឱ្យផុតទៅកុំសេពឱ្យសោះ
អាចនាំទុក្ខព្រួយព្រោះចិត្តមិនស្មោះ ចិត្តតែងក្រៀមក្រោះព្រោះនៅកៀកក្បែរ ។
ពេលអស់ជីវិតគង់កើតនរក ជាឋានគម្រក់មិនគួរជាប់ស្នេហ៍
អាចនាំទុក្ខព្រួយគ្រប់ជាតិហូរហែ មិនគួររស់ក្បែរអាចចូលអបាយ ។
បើបានដឹងហើយគួរគេចឱ្យផុត លុះថ្ងៃរលត់វាចាចិត្តកាយ
កុំប្រហែលទុក្ខដោយសើចក្អាកក្អាយ លេងសើចសប្បាយគ្រោះថ្នាក់ជីវិត ។
កវីផ្ដែផ្ដាំចាំក្នុងចិត្តទៅ រស់បានជាផ្លូវសម្រាប់គំនិត
សូមអស់ប្រុសស្រីព្យាយាមរិះគិត ឈ្វេងយល់ការពិតកុំសេពគប់ពាល ។

# ១៦~ រាល់ថ្ងៃល្ងាចព្រឹកនឹកម៉ែគ្មានស្បើយ

រាត្រីសែនស្ងាត់សព្វសត្វនិទ្រា ក្រោមស្បៃសន្ធ្យាសែនសុខមនោរម្យ
ឮសូរគ្រាប់ភ្លៀងចិត្តណែនអួលឆ្អំ ដូចជាចង់យំនឹកផ្ទះសំបែង ។
នឹកភូមិនឹកស្រុកនឹកពុកនឹកម៉ែ ដែលធ្លាប់ថ្នមថៃបីបមប្រលែង
ធ្លាប់ច្រៀងបំពេពីរោះក្រៃលែង នឹកសព្ទសូរសៀងស្រណោះខ្លួនណាស់ ។
ឃ្លាតមកស្រុកឆ្ងាយម្ដាយនឹកកូនទេ ពេលនេះមាសមេកូនដឹងខ្លួនច្បាស់

ថាម៉ែនឹកកូនឥតប្រែក្រឡាស់ ម៉ែកាន់តែចាស់ខ្វះភាពកក់ក្ដៅ ។
កូននៅឆ្ងាយម៉ែតែកូនមិនភ្លេច នឹកឃើញជានិច្ចពាក្យម៉ែប្រដៅ
ដែលម៉ែជួយប្រាប់ដាស់តឿនកូនចៅ កូនសែនកក់ក្ដៅព្រោះពាក្យពេចន៍ម៉ែ ។
ធ្វើការរាល់ថ្ងៃកូនសែនរវូក រាល់ថ្ងៃល្ងាចព្រឹកកូនចង់នៅក្បែរ
បម្រើដោយផ្ទាល់ថ្នាក់ថ្នមមើលថែ ចិត្តឥតកែប្រែចោលអ្នកម៉ែឡើយ ។
អុំាះអុំា ! អនិច្ចាវាសនាបុព្វេ នឹករីតឡើងទ្វេចិត្តឥតស្រាកស្បើយ
ឃើញម៉ែញញឹមនៅក្បែកបង្អើយ រូបកូននេះហើយជាដួងចិត្តម៉ែ ។
ម៉ែស៊ូលះបង់ដើម្បីកូនថ្លៃ រាល់ពេលយប់ថ្ងៃម៉ែនឿយហត់ទេ
ម៉ែចិញ្ចឹមកូនព្រោះតែម៉ែស្នេហ៍ នឹងបុត្រមាសមេជាកែវនេត្រា ។
ស៊ូអត់មាត់ឯងឱ្យតែកូនរស់ ឃ្លានបាយដាច់ពោះក៏មិនវាចា
ព្រោះតែស្នេហ៍បុត្រថ្លៃកនិដ្ឋា រូបកូនជីវ៉ាម៉ែស្នេហ៍លុះក្ស័យ ។
ឱ្យម៉ែកាត់ចិត្តធ្វើម្ដេចបានទៅ ព្រោះអីពាលពៅកូនមានតម្លៃ
ស្នងជាតិត្រកូលចងភ្ជាប់និស្ស័យ ដែលម៉ែស្រមៃពេលបានកូនមក ។
ពេលអត់ពីម៉ែនែ៎កូនប្រុសស្រី ! ពាក្យពេចន៍វែងខ្លីកុំស្ដីលាមក
ត្រូវពោលវាចាទឹកថ្លាជាងភក់ សម្ដីនរកត្រូវចៀសឱ្យឆ្ងាយ ។
បានស្ដាប់វាចាថ្លៃថ្លាជាងពេជ្រ កូនចាំមិនភ្លេចពាក្យពេចន៍ទាំងឡាយ
សែនពីរោះក្រៃហួសពីបរិយាយ ទោះកូនឃ្លាតឆ្ងាយក៏កូនចងចាំ ។

គ្រប់បណ្ដាំម៉ែកូនថែទាំងអស់ មិនឱ្យបាត់សោះពាក្យម៉ែផ្ដែផ្ដាំ
ធ្លាក់ក្នុងបេះដូងអក្ខរាត្រាត្រាំ កូននឹងចងចាំអស់មួយជីវិត ។

## ១៧- ជួបជាគូនិងព្រាត់

សំឡេងក្អកក្អាត់រងំពេញស្រែ ភ្លៀងធ្លាក់ចុងខែដូចពុំសូវជួន
ស្រូវស្រែចំការខ្លះស្លាប់ផ្ទួនៗ បាត់ភាពមាំមួនដែលមានរាល់ឆ្នាំ ។
ដើមឈើដើមព្រៃលៃតាមធម្មជាតិ ជ្រុះស្លឹកព្រោងព្រាតឃើញតាមចំណាំ
ខ្លះស្លាប់ទាំងដើមមានជាប្រចាំ ស្រូវស្រែដំណាំក៏ស្លាប់ដូចគ្នា ។
ស្រណោះបក្សាស្វែងរកសំបុក កាត់ព្រៃស្មាញស្មុគក្រោមស្បៃសន្ធិយា
សត្វខ្លះព្រាត់កូនរស់នៅរងា ឯកាកំព្រាវេទនាខ្លោចផ្សា ។
ធ្លាប់រស់ជួបជុំសុខដុមរមនា ឥឡូវបែកគ្នារងាយ៉ាងណា?
រស់មេជុំកូនតាមក្ដីប្រាថ្នា បាត់បង់ម្ដេចម្ដាគង់បានជួបគ្នា ។
ជីវិតសត្វលោកក៏ដូច្នោះដែរ ព្រាត់ស្លាប់ហូរហែមានគ្រប់វេលា
ខ្លះនៅស្រុកឆ្ងាយតាមទីនានា ខ្លះក៏បាត់គ្នារហូតថ្ងៃស្លាប់ ។
មានជួបមានព្រាត់តើឃាត់ម្ដេចបាន ប្រុសស្រីគ្រប់ប្រាណរស់ទាំងឈឺចាប់

ធ្លាប់រស់ជួបជុំពេលនេះព្រាត់ស្លាប់ រស់ទាំងស្អុះស្អាប់ព្រោះបែកសែនឆ្ងាយ ។
ជួបគូនិងព្រាត់ជារឿងធម្មតា ក្មេងចាស់កុមារព្រាត់ឪពុកម្ដាយ
ប្រពន្ធព្រាត់ប្ដីខ្លះព្រាត់សហាយ បាត់បង់រូបកាយមានជាប្រចាំ ។

# ១៨~ ជីវិតកូនកំព្រា

ស្រណោះខ្លួនណាស់ប្ដូរផ្លាស់តាមឆ្នាំ ចិត្តនៅតែចាំរាល់ថ្ងៃល្ងាចព្រឹក
សង្វេគខ្លួនឯងព្រឺព្រួចកួចទឹក រាល់ពេលរឭកខ្ញុំសែនអាល័យ ។
គេមានបងប្អូនជួបជុំគ្រួសារ សប្បាយហ៊ឹហាគ្រប់ពេលយប់ថ្ងៃ
សាច់ញាតិភូមិផងគេមាននិស្ស័យ ជីវិតថ្លាថ្លៃបាត់បង់ក្ដីទុក្ខ ។
ទៅណាមកណាជាពួកជាកង មានមុខត្រសងដូចមានក្ដីសុខ
រីករាយរាក់ទាក់ផ្ដល់ភាពស្រណុក បញ្ហាស្មាញស្មុគរលត់ទៅឆ្ងាយ ។
ចំណែករូបខ្ញុំកំព្រាឯកា ជួបទុក្ខខ្លោចផ្សាច្រើនវែងអន្លាយ
ឥតញាតិបងប្អូនភូមិផងទាំងឡាយ កម្សត់រូបកាយតែចិត្តតស៊ូ ។
ពីតូចដល់ធំគ្មានភាពកក់ក្ដៅ ទុក្ខសោកហ្មងសៅដៅជាប់ជាយូរ
ប្រឡាក់ដិតដាមដូចស្នាមគំនូរ បិទមាត់រអ៊ូដើម្បីជីវិត ។
អ្នកផ្សេងមើលងាយពេបជ្រាយយ៉ាងណា នៅតែស្នេហាតាមផ្ចិតគំនិត

ធ្លាប់ដេកនឹកផ្សងរាល់ថ្ងៃល្ងាចព្រឹក សង្ឃឹមរលឹកជួបសុខថ្ងៃក្រោយ ។
ធ្វើម្តេចជាតិនេះកើតមកម្នាក់ឯង កណ្តោចកណ្តែងតែមិនបណ្តោយ
ព្យាយាមរៀនសូត្រមិនឱ្យថ្លោះធ្លោយពីថ្នាក់ទី១ដល់ទីបញ្ចប់ ។
ប្រឹងប្រែងថ្ងៃនេះគង់បានជោគជ័យ ជីវិតមានន័យឥតប្រែត្រលប់
ចិត្តព្រមទទួលរីករាយសាយសព្វ មិនអាចបញ្ចប់ដោយគ្មានសង្ឃឹម ។
អាសូរជីវិតនៃកូនកំព្រា រស់រងរងាតែខំញញឹម
ផ្តល់ភាពកក់ក្តៅចិត្តស្រស់ពព្រឹម ព្រឹកថ្ងៃព្រលឹមញញឹមជានិច្ច ។
សេចក្តីទុក្ខសោកបោកបក់ជីវិត ឃ្លាតកាយណាយចិត្តតែមួយពព្រិច
កួចបោកបក់យកខំស្កាត់ខំធ្មេច រស្មីរំលេចដូចដួងតារា ។
យ៉ាងណាជីវិតនៃកូនកំព្រា រស់នៅវេទនារងាឯកា
សាច់ញាតិបងប្អូនពុកម៉ែយាយតា ឆ្ងាយដូចវេហាសីហៅលែងវិលវិញ ។
ទឹកភ្នែកជន់ជោរហូររៀងរាល់ថ្ងៃ ព្រោះតែនិស្ស័យកម្មខ្ញុំនេះមិញ
រស់នៅទៅមកតាមជាប់ប្រដេញ យប់ថ្ងៃចូលចេញតាមទ្វារទាំងឡាយ ។
កំព្រាខ្លួនឯងថ្លែងប្រាប់នរណា? ក្នុងវដ្តសង្សារគួរតែនឿយណាយ
កើតស្លាប់ៗកើតលះបង់មិនស្តាយ គួរតែជិនណាយក្នុងជាតិកំណើត ។
កម្សត់ពេលនេះមេរៀនជីវិត ពោលឥតប្រឌិតដែលខ្ញុំបានកើត
ទោះបីកំព្រាតែមានកំណើត ពុកម៉ែបង្កើតខ្ញុំសែនអរគុណ ។

រូបគាត់ស្លាប់ទៅជាយូរឆ្នាំហើយ សូមដល់កោះត្រើយខ្ញុំសូមជូនបុណ្យ
ឱ្យរួចទុក្ខទោសដែលជាប់ទារុណ ដោយអំណាចបុណ្យដែលខ្ញុំជូនទៅ ។
រៀបរាប់រឿងរ៉ាវជីវិតកំព្រា កក់ក្ដៅរងាជារឿងខាងក្រៅ
ទទួលចិត្តស្ងប់ទើបភាពកក់ក្ដៅ ប្រឡាក់ជិតនៅតាមខ្សែជីវិត ។
ប្រវត្តិរឿងខ្ញុំដូចរឿងអ្នកដែរ មានទេពុកម៉ែដែលនៅឆ្ងាយជិត
សរសេរនិទ្ទាសុខទុក្ខមានពិត នេះហើយជីវិតនៃកូនកំព្រា ។

# ១៩~ ទឹកចិត្តមាតាស្នេហាកូនបួស

ពីតូចដល់ធំខ្ញុំនៅនឹងម៉ែ ជាច្រើនថ្ងៃខែខ្ញុំសែនសប្បាយ
ធ្លាប់ពោលសាសងនៃបនិត្យជិតកាយ ឥឡូវរូបម្ដាយត្រូវឃ្លាតកូនហើយ ។
កូនសូមបង្គំប្រណម្យព្រះរស់ ដ៏ល្អខ្ពង់ខ្ពស់ប្រៀបបានកោះត្រើយ
ពេលនេះរូបកូននឹកម៉ែគ្មានស្បើយ រូបកូនត្រានត្រើយជាដួងចិត្តម៉ែ ។
ឃ្លាតឆ្ងាយភូមិស្រុកចេញទៅសាងផ្នួស មួយរយៈបួសមិនបាននៅក្បែរ
ឥតបានថ្នាក់ថ្នមបីបាច់មើលថែ បេះដូងនៅតែស្នេហ៍ម៉ែជានិច្ច ។
ពុកម៉ែត្រេកអររំភើបចិត្តក្រៃ ទោះឃ្លាតច្រើនថ្ងៃក៏ម៉ែមិនភ្លេច

នៅតែនឹកកូនគ្រប់ពេលបើកធ្មេច ចាំកូនជានិច្ចលុះសូន្យសង្ខារ ។
ពុកហើយនិងម៉ែនឹកកូនខ្លាំងពេក ច្រើនជាអនេកមិនអាចគណនា
ស្រក់ទឹកនេត្រាធ្លាក់លើពសុធា ចិត្តសែនគ្រាំគ្រាព្រោះកូនឃ្លាតឆ្ងាយ ។
នឹកឃើញទាំងអស់រាល់អនុស្សាវរីយ៍ ពេលដែលជីវ៉ានៅក្បែរជិតម្ដាយ
ម៉ែធ្លាប់ប្រលែងសព្វគ្រប់រាងកាយ សើចលេងសប្បាយជួបជុំគ្រួសារ ។
ដៃម៉ែទាំងទ្វេថែកូនរាល់ថ្ងៃ បបោសថ្នមបីកូនបានសុខា
ញញឹមថ្ពាល់ខួចលើផ្ទៃភក្ត្រា នឹកឃើញកាលណាទឹកភ្នែកកាលហ្នឹង ។
ពេលខ្លះកូនយំរងំពេញផ្ទះ ម៉ែក្រាបសំពះព្រោះតែព្រលឹង
បន់អស់ទេវតាឱ្យកូនបាត់ឈឺង ម៉ែធ្វើអ៊ីចឹងព្រោះតែរូបកូន ។
ទោះលួងយ៉ាងណាក៏កូនមិនបាត់ ចិត្តម៉ែខំកាត់ឱ្យកូនមាសស្ងួន
សុខចិត្តស៊ូទ្រាំអត់ងងុយខ្លួន ឱ្យតែនឹមនួនផុតគ្រោះចង្រៃ ។
ឥឡូវកូនធំហើយបានបួសទៀត ក៏ម៉ែមិនឃ្លាតពីកូនចរណៃ
នៅតែស្រលាញ់គ្រប់ពេលយប់ថ្ងៃ រហូតម៉ែក្ស័យលាចាកលោកា ។
ចំណែកកូនវិញរស់នៅក្នុងវត្ត ក៏មិនអាចឃាត់ចិត្តនឹកមាតា
សម្រក់ទឹកភ្នែកជោកលើភក្ត្រា នឹកឃើញហត្ថាម៉ែធ្លាប់ថ្នមបី ។
ពេលខ្លះនឹកខ្លាំងកូននៅមិនសុខ ចិត្តកូនស្ងាញស្ងុគគ្មានពាក្យពោលស្ដី
ទឹកភ្នែកហូរឯងដូចឥតដឹងអ្វី នឹកពាក្យវែងខ្លីម៉ែធ្លាប់អប់រំ ។

កូនខំព្យាយាមសិក្សាវិជ្ជា ទោះក្តៅរងាក៏កូនខិតខំ
ពាក្យម៉ែប្រដៅកូនឥតច្រឡំ ដាស់តឿនចំៗឱ្យកូនខំរៀន ។
កូនមិនភ្លេចទេពាក្យម៉ែទាំងអស់ រក្សាដោយស្មោះអប់រំទូន្មាន
បង្កប់អត្ថន័យរាប់ម៉ឺនសែនលាន តិចច្រើនប៉ុន្មានក៏កូននៅចាំ ។
បញ្ចប់អត្ថន័យប៉ុណ្ណឹងចុះណា៎ គ្រប់បុត្រធីតាគួរតែចំណាំ
ទឹកចិត្តមាតាស្នេហាផ្តែផ្តាំ កូនប្អូសយូរឆ្នាំនឹកឃើញម៉ែផង ។

## ២០~ កឋិនវត្តយើង

កឋិនវត្តយើងកៀកជិតណាស់ហើយ ឱ ! ប្រុសស្រីអើយរួតរះម្ទីម្ទា
រៀបចំប្រដាប់ស្បង់ស្បៃនានា គោរពបូជាថ្វាយចំពោះសង្ឃ ។
ធ្វើទានតាមកាលបានបុណ្យច្រើនណាស់ កុំប្រែប្រក្រឡាស់ធ្វើដោយផ្ចិតផ្ចង់
ដាក់ចិត្តធ្វើបុណ្យកុំស្ដាយរឿងបង់ ផលល្អផ្ទួរផង់ធ្លាក់មកលើខ្លួន ។
សម្រេចអានិសង្ស ៥ ប្រការ ទី១នោះណារូបល្អគាប់ជួន
ដៃជើងភ្នែកមាត់មានគ្រប់ចំនួន ស្រស់ថ្លាផ្ទួនៗគាប់ចិត្តអ្នកផង ។
ផលបុណ្យទី២សណ្ឋានទ្រង់ទ្រាយ គួរគាប់ពណ្ណរាយសែនល្អម៉ត់ហ្មង

មិនជឿមិនទាបសមតាមបំណង អ្នកផ្សេងគួចប៉ងចាប់ចិត្តស្រលាញ់ ។
ចំណែកទីពាសំឡេងពីរោះ ឮច្បាស់ៗនោះមុខគួរឱ្យខ្លាញ់
និយាយពេលណាអ្នកផ្សេងសុំចាញ់ ព្រោះតែអង្គអញបានធ្វើកឋិន ។
ទី៤នោះមិញបានស្តេចចក្រពត្តិ រិជ្ជាឥតភ្លាត់បញ្ញាវៃប៉ិន
គ្រប់គ្រងផែនដីទសពិធមាសឆ្អិន ព្រោះតែកឋិនទើបសោយសុខា ។
ឯទីបញ្ចប់ឯហិភិក្ខុ កាប់ឆ្ការស្នាញស្មុគឆ្លងវដ្តសង្សារ
គ្រាន់តែសម្ពុទ្ធលើកព្រះហត្ថា ពោលព្រះវាចាចូរជាភិក្ខុ ។
ស្បង់ស្បៃចីវរមានគ្រប់ប្រដាប់ មិនបាច់យ៉ាកយ៉ាប់ស្វែងរកតត្រុក
សង្រួមកាយាដូចវស្សាហុក លះកាត់ក្តីទុក្ខដល់ព្រះនិព្វាន ។

## ២១~ កឋិនឆ្នាំនេះញាតិទៅវត្តណា?

សួស្តីឆ្នាំថ្មីសិរីមង្គល ចូរកើតមានដល់ញាតិទាំងប្រុសស្រី
ដែលមានជីវិតរស់លើផែនដី រដូវឆ្នាំថ្មីសូមបានសុខា ។
រកស៊ីមានបានច្រើនថ្កានវាលគុម្ព រស់នៅសុខដុមគ្រប់ក្រុមគ្រួសារ
ដំណើរលើគោកផ្លូវទឹកយ៉ាងណា បានក្តីសុខាទាំងទៅទាំងមក ។

១រោចអស្សុជចូលដល់កឋិន ឱ ! ញាតិមាសឆ្អិនត្រូវប៉ិនរាប់រក
រីករាយរាក់ទាក់ប្រុសស្រីចូលជ្រក ផ្តើមជាពន្លកនាំគ្នាធ្វើបុណ្យ ។
កឋិនឆ្នាំនេះញាតិទៅវត្តណា ? ឆ្លើយប្រាប់មកវ៉ាខ្ញុំសូមអរគុណ
ទៅទាំងអស់គ្នាទាំងប្តីប្រពន្ធ ញាតិមិត្តរាប់ពាន់ក៏គេទៅដែរ ។
វត្តមានច្រើនណាស់ផ្លាស់មួយទៅមួយ ចិត្តញ៉ូវរំជួយព្រោះបានដង្ហែ
ធ្វើរួមបងប្អូនយាយតាពុកម៉ែ រហូតទាល់តែគ្រប់សាមសិបថ្ងៃ ។
ញាតិមិត្តប្រុសស្រីក្មេងក្តីយ៉ាងណា សុទ្ធមានវាសនាធ្វើជានិស្ស័យ
ដល់ទៅជាតិក្រោយរុងរឿងពេកក្រៃ ជាប់ជានិស្ស័យធ្វើបុណ្យកឋិន ។
ទៅធ្វើទីណាកុំភ្លេចហៅផង ណាញាតិប្អូនបងបង្អង់ចាំសិន
យើងធ្វើរួមគ្នាមិនថាខ្មែរចិន កុំឆ្លើយថាមិនទៅទាំងអស់គ្នា ។

# ២២~ ទំនួញកូនពេលម៉ែស្លាប់

ស្រណោះវ័យក្មេងកើតទុក្ខា យំយែកខ្លោចផ្សាទាំងយប់ថ្ងៃ
ឃ្លាតពីអ្នកម្តាយធ្លាប់ថ្នមបី ធ្លាប់តែប្រណីមើលថែកូន ។
បបោសអង្អែលសព្វរាងកាយ ឥឡូវប្រែក្លាយជាបាត់សូន្យ

បាត់ទាំងស្រមោលផ្គុំប្រមូល ដង្ហើមចេញចូលក៏បាត់ដែរ ។
ធ្វើឱ្យរូបកូនវែងក្ដីទុក្ខ ចិត្តឥតបានសុខរាល់ថ្ងៃខែ
ព្រោះតែរូបកូននៅនឹកម៉ែ ធ្លាប់បីបាច់ថែកូនពីតូច ។
ម៉ែស្លាប់តែកាយក៏ពិតមែន តែទ្រព្យធនធានមានស្ដើងស្ដួច
ម៉ែប្រឹងធ្វើការឥតលបលួច ដើម្បីកូនតូចរបស់ម៉ែ ។
កូនពិតជាស្ដាយៗខ្លាំងណាស់ ស្ដាយព្រះជាម្ចាស់លែងបានក្បែរ
ស្ដាយជាប់រហូតឥតវិលទេ សូមវិញ្ញាណម៉ែសោយសុខា ។
សូមម៉ែបានសោយសុខសួគ៌ា ផុតក្ដីវេទនាទុក្ខខ្លោចផ្សា
ដោយអំណាចចិត្តកូនសទ្ធា ទុក្ខសោកយ៉ាងណាសូមផុតទៅ ។
កូននឹងឧទ្ទិសកងកុសល គោរពជូនដល់ចំទិសដៅ
សូមម៉ែទទួលហើយបិតនៅ ថែទាំកូនចៅលុះអវសាន្ត ។
កូនខំធ្វើបុណ្យទោះកូនក្រ ដោយចិត្តស្មោះសរទាំងប៉ុន្មាន
កូននឹងពូតផ្ដុំទុកក្នុងប្រាណ រួចហើយកូនបានឧទ្ទិសជូន ។
បងប្អូនសាច់ញាតិកូនមើលថែ មិនឱ្យបាត់ទេណាម៉ែស្ងួន
ពាក្យពេចន៍ម៉ែផ្ដាំចាំជាប់ជួន ដូចមានសំនួនយ៉ាងនេះថា ។
នែ៎ ! កូនប្រុសស្រីទាំងឡាយអើយ កូនកុំកន្ដើយខំឧស្សាហ៍
ព្យាយាមឱ្យកើតធម៌កុសលា តាំងចិត្តយ៉ាងណាធ្វើយ៉ាងហ្នឹង ។

ចេះគោរពចាស់ឱនលំទោន មានះដាក់ខ្លួនកូនត្រូវប្រឹង
ព្យាយាមយប់ថ្ងៃគិតជញ្ជឹង រំពៃសម្លឹងចិត្តខ្លួនឯង ។
ចម្រើនធមិព្រះឈ្នះផ្លូវមារ សិក្សាធម្មាព្រះសម្ដែង
ចងចាំទន្ទេញចិត្តកោតក្រែង កុំឱ្យបែកផ្សែងវិតក្កៈ ។
ស្រលាញ់បងប្អូនស្ងួនពិសី មានក្រលក្ខ័តឥតយសស័ក្តិ
កូនកុំឈ្លោះទាស់អាងកាប់ចាក់ ប្រយ័ត្នប្រឡាក់ដោយកម្មពៀរ ។
ក្នុងសង្សារវដ្តច្រើនមកហើយ ឱ ! មាសកូនអើយមានដឹងទេ
បុគ្គលណាមួយទោះយើងគេ ទាំងអស់សុទ្ធតែជាសាច់ញាតិ ។
បើដឹងថាញាតិមិនគួរខឹង ព្យាយាមសម្លឹងកុំឃ្លៀងឃ្លាត
នាំខូចកិច្ចការបាត់មារយាទ នៅមានច្រើនទៀតដែលត្រូវប្រាប់ ។
ពេលអត់ពីម៉ែកូនត្រូវចាំ ធ្វើតាមចំណាំម៉ែរ៉ាយរ៉ាប់
ឧទ្ទិសកុសលដល់អ្នកស្លាប់ កុំធ្វើប្រញាប់ភ្លេចឧទ្ទិស ។
ពេលម៉ែបានកូនម៉ែគិតថា រូបកូននេះណាទុកជាគ្រឹះ
តបស្នងសងគុណចិត្តមិនទ្រើស អ្វីដែលត្រូវជ្រើសគឺកុសល ។
ធ្វើបុណ្យជូនម៉ែពេលម៉ែសូន្យ ដឹងទេកូនៗម៉ែចាំផល
រងចាំទទួលដែលកូនផ្ដល់ ឧទ្ទិសជូនដល់ម៉ែផងណា ។
បុគ្គលស្លាប់ទៅឥតមានអ្វី ក្រៅពីប្រុសស្រីគ្រប់រូបា

ធ្វើបុណ្យដាក់ទានជូនផលា ដល់ញាតិកាដែលស្លាប់ទៅ ។
សង្ឃឹមទាំងស្រុងនូវទង្វើ ដែលកូនៗធ្វើជូនញាតិផៅ
ឃើញច្បាស់ក្រឡែតជិតក្រឡៅ ដឹងទេពាលពៅមាសពិសី ។
បញ្ចប់ពាក្យពេចន៍ម៉ែប៉ុណ្ណឹង កូននឹងខំប្រឹងទាំងប្រុសស្រី
ធ្វើខ្លួនឱ្យល្អដូចម៉ែស្តី ពាក្យពេចន៍វែងខ្លីម៉ែប្រដៅ ។
កវីវ័យក្មេងសៅចាន់ណា បានបើកឱកាចារចែងទៅ
ខុសត្រូវយ៉ាងណាសូមញាតិផៅ ឆ្ងាយជិតក្នុងក្រៅសូមសន្តោស ។
ជួយប្រាប់ជួយកែដោយមេត្តា ដល់ខ្ញុំផងណាចារទៅខុស
រីករាយទទួលនឹងកំហុស ដើម្បីប្រាណប្រោសយកភាពត្រូវ ។
កងកាកុសលទាំងប៉ុន្មាន ជូនញាតិសន្តានបានជាផ្លូវ
ដើរតាមអង្គមគ្គល្អពេកកូវ ដូចខ្ញុំជូនទៅនេះឯងហោង ។

# ២៣. ឈ្លក់នឹងសំឡេងវង្វេងផ្លូវចិត្ត

ថ្ងៃយប់ៗព្រលប់ខ្វាយខ្វល់ ចិត្តជ្រួលច្របល់ទៅតាមបទភ្លេង
ទាក់ទាញដួងចិត្តជីវិតនៅក្មេង វីវក់វង្វេងទៅតាមអារម្មណ៍ ។
ឥតបានអប់រំរងំផ្លូវចិត្ត ឃ្លាតពីការពិតមិនបានខិតខំ
ទប់ស្កាត់កិលេសដោយមិនច្រឡំ ព្យាយាមសន្សំគង់បានសម្រេច ។
បណ្ដោយស្មារតីវង្វេងខ្លីតិចច្រើន គង់ផលចម្រើនទៅតាមក្បួរក្បាច់
ឈ្លក់នឹងរូបាស្នេហាកាយកាច់ រហូតស្រេចបាច់បានជាផលកម្ម ។
ទុក្ខសោកហ្មងសៅក្នុងទីមិនល្អ ព្រោះតែដាច់ធម៌នៅមិនព្រមចាំ
រូបសំឡេងក្លិនគួរតែចំណាំ ភ្លេចព្រះផ្ដែផ្ដាំតែងជួបទុក្ខសោក ។
សន្សំតិចៗរិចៗតែងពេញ រហូតផលចេញដូចខ្យល់បក់បោក
ប៉ុន្មែងទាំងជីវិតកំពុងងុយងោក ជីវិតវិយោគចូលដល់អបាយ ។
ស្រេកឃ្លានខ្លាំងណាស់ច្បាស់ទប់មិនបាន ដឹងចុះកល្យាណភិតភ័យអន្តរាយ
គ្មានទេក្ដីសុខជួបទុក្ខវែងឆ្ងាយ គ្រោះមហន្តរាយក្នុងអបាយភូមិ ។
ឈ្លក់នឹងសំឡេងវែងកើតចិត្តបាប ចេញផលដរាបជីវិតរលំ
លាឋានសុខសួគ៌ជាទីមនោរម្យ ផលល្អិតសុខុមចាត់ចែងតាមកម្ម ។

# ២៤. សំណាងស្រីណាស់ប៉ះប្ដីចិត្តធម៌

សំណាងខ្ញុំណាស់បានចំប្ដីល្អ ប្ដីមានចិត្តធម៌សង្គ្រោះភរិយា
ស្រីស្រាកែវពែងប្ដីខ្ញុំសូមលា ប្រកបការងារក្នុងធម៌សុចរិត ។
ជួយធ្វើកិច្ចការស្នេហាស្មោះត្រង់ ទុកដាក់ផ្ចិតផ្ចង់ឥតធ្លោយគំនិត
ការងារតូចធំនូវទីឆ្ងាយជិត ធ្វើល្អពេកពិតឥតរាថយឡើយ ។
មើលថែប្រពន្ធកូនចៅនានា គោរពមុខងារជាប្ដីល្អហើយ
ថែមទាំងយកចិត្តឥតសោះកន្តើយ លោកប្ដីខ្ញុំអើយល្អអ្វីម្ល៉េះទេ ។
បើមានជាតិក្រោយសូមប៉ងប្រាថ្នា ធ្វើចិត្តសច្ចាជាមួយមាសមេ
សុំជួបម្ដងទៀតមិនអាចងាករេ ចិត្តស្មោះមានស្នេហ៍ស្រីតែងប្រាថ្នា ។
ទឹកចិត្តស្ត្រីមានប្ដីយ៉ាងនេះ គួរគិតត្រិះរិះឱ្យគ្រប់កិច្ចការ
នាងតែងសប្បាយហួសនឹងវាចា បើប្ដីសាវ៉ាតែងគ្រាំគ្រាចិត្ត ។
ប្ដីខ្លះធ្វើបាបវាយដំច្រំធាក់ ទាត់ខ្លួនទម្លាក់ខ្វះញាណរិះគិត
រស់នៅប៉ោឡៃបាត់បង់គំនិត ឃ្លាតពីការពិតចូលប្ដីអប្រិយ ។
សង្គមគ្រួសារខ្វះភាពស្មោះត្រង់ កូនចៅរហង់អត់ឃ្លានមានធី
សិក្សារៀនសូត្រត្រិះរិះវែងខ្លី ក្មេងៗប្រុសស្រីខូចអនាគត ។
ធ្វើមេគ្រួសារព្យាយាមខ្លះទៅ រឿងខ្លះតម្រូវបែរជារលត់

ប្រុសចិត្តអប្រិយថែទាំមិនគត់ ប្រៀបអស្តង្គតជីវិតគ្រួសារ ។
សំណាងរូបស្រីបានប្តីចិត្តល្អ ប្តីចិត្តស្មោះសរជីវិតថ្លៃថ្លា
ថែងចាំងរស្មីដូចដួងតារា វិថីស្នេហាប្តីនិងប្រពន្ធ ។

# ២៥- សត្វខុសមនុស្ស

ព្រៃភ្នំច្រើនក្តាត់សព្វសត្វអឹងកង សំឡេងឆ្លើយឆ្លងផ្តោះផ្តងវាចា
តាមជ្រោះជ្រលងដងបព្វតា អារម្មណ៍ស្រស់ថ្លាព្រោះវាចាសត្វ ។
រីករាយស្រស់ស្រាយសប្បាយហិចហើរ តូចធំបណ្តើរមិនខ្លាចបង់បាត់
ស្វែងរកចំណីបែកខ្វែកខ្វាយខ្វាត់ ហោះហើរច្រវាត់តាមនភាល័យ ។
ជីវិតបែបនេះសប្បាយម្យ៉ាងដែរ ស្បើយទុក្ខហួរហែជាប់ជានិស្ស័យ
កំណើតសត្វសោះតែចិត្តប្រពៃ ល្អលើសអ្វីៗជាជាងមនុស្សខ្លះ ។
ព្រះពុទ្ធគ្រប់អង្គត្រាស់ដឹងក្នុងលោក មានជ័យមានជោគបញ្ញាឥតខ្ចះ
អប់រំទូន្មានគ្រប់វ័យក្មេងចាស់ ប្រឹងប្រែងឱ្យណាស់កុំអន់ជាងសត្វ ។
មនុស្សដឹងខុសត្រូវប្រព្រឹត្តធម្មា ធម៌ព្រះភគវាក្នុងព្រះបរិយត្តិ
បដិវេធៈនិងបដិបត្តិ កិលេសបង់បាត់រលត់ទុក្ខា ។

ចំណែកសត្វវិញឥតដូចមនុស្សទេ ប្រព្រឹត្តតែងតែខាំចឹកប្រហារ
យកជាចំណើឥតក្តីមេត្តា សម្លាប់ប្រហារតែសត្វដូចគ្នា ។
ជាតិនេះកើតសត្វជាតិក្រោយសត្វទៀត ព្រោះតែឃ្លៀងឃ្លាតប្រព្រឹត្តពានពារ
ឥតមានកាន់សីលដូចមនុស្សជានា ដូច្នេះគ្រប់គ្នាគួរសាងកុសល ។

# ២៦. តាតាចាស់ហើយនៅវត្តខ្លះផង !

ជីវិតគឺជានាវាផ្លូវឆ្ងាយ ផ្លូវវែងអន្លាយឥតមានទិសដៅ
រង្វេងភ្លាំងភ្លាត់ទុក្ខសោកហ្មងសៅ ជិតដាមក្រឡៅឃើញនៅនឹងភ្នែក ។
វដ្តសង្សារមហាសាគរ វិលវល់វិវរសណ្ឋានច្រើនផ្នែក
មិនរួចភពបីចែកដាច់ដោយឡែក ដង្ហោយហៅស្រែកមិនពួសោះឡើយ ។
ស្លាប់កើតៗឥតរើសនរណា ក្មេងចាស់កុមារខ្លះធ្វើព្រងើយ
មិនខំស្វែងរកក្តីសុខជាត្រើយ ដូចមានច្រើនហើយពេលបច្ចុប្បន្ន ។
សប្បាយហ៊ឺហាស្រីស្រាអូនបង សម្តីឆ្លើយឆ្លងផ្តោះផ្តងអនន្ត
ភ្លេចខ្លួនពេកទៅអន្តរាយទាន់ហន្ត បួងសួងបន់ស្រន់ក៏មិនរួចដែរ ។
ថាក្មេងៗទៅសប្បាយហ៊ឺហា ចុះអ៊ំតាតាស្រីក្មេងនៅក្បែរ

ចូលធមិបរាឈឺផ្សាឥតល្ហែ ចិត្តលោតប្រួលប្រែភ្លេចឯងវ័យចាស់ ។
ទៅវត្តទៅវ៉ាស្ដាប់ធមិខ្លះទៅ ប្រឹងគិតឱ្យជ្រៅកុំប្រែក្រឡាស់
អាយុ៧០ប្លាយកុំនៅតែណាស់ ប្រយ័ត្នព្រាត់ប្រាស់និរាសចាកឋាន ។
បច្ឆិមវ័យកុំលៃរឿងកាម ស្នេហាស្និទ្ធស្នាមតាមជាប់ក្នុងប្រាណ
នាំខូចផ្លូវចិត្តព្រោះគិតខកខាន ចូរប្រឹងឱ្យបានចិត្តកុំប្រមាទ ។
ចម្រើនកុសលផ្ដល់ឋានសុខស្ងប់ វ័យទីបញ្ចប់ខិតខំសង្វាត
មិនក្មេងវិញឡើយប្រែប្រួលខុសខ្នាត លាងចិត្តស្អាតបាតទទួលធមិថ្លៃ ។
ព្រះធមិមានហើយពេញចិត្តមួយណា ចាប់យកសិក្សារាល់ពេលយប់ថ្ងៃ
ដើម្បីចម្រើនសីលជានិស្ស័យ គុណរតនៈត្រៃផ្ដល់ផលសុខា ។
ការពារជីវិតកុំចូលអបាយ ជាទុក្ខវែងឆ្ងាយក្នុងវដ្តសង្សារ
ព្រះពុទ្ធត្រាស់ដឹងរស្មីភ្លឺថ្លា សព្វសត្វលោកាទទួលពន្លឺ ។
ចុះបើភ្លាត់ធ្លាក់ក្នុងភពសាមាន្យ សត្វលោកគ្រប់ប្រាណមានតែទុក្ខឈឺ
ឥតបានទទួលរស្មីពន្លឺ ម្ល៉ោះហើយជំងឺកិលេសដុតរោល ។
សត្វខ្លះអត់ឃ្លានសឹងតែគ្រប់ជាតិ ផលបុណ្យឃ្លៀងឃ្លាតរូបកាយប្រែប្រួល
ស្រណោះថ្ងូចថ្ងូរអាសូរដេកដួល ព្រោះតែកំសួលផលកម្មហុចឱ្យ ។
គិតវែងឆ្ងាយទៅស្រណោះខ្លួនណាស់ ពីក្មេងដល់ចាស់ពីមុខទល់ក្រោយ
មានតែសាងបាបខ្លួនក៏បណ្ដោយ មិនដឹងដង្ហោយហៅអ្នកណាជួយ ។

ខ្លួនទីពឹងខ្លួនកុំពឹងលើអ្វី ចូរជនប្រុសស្រីបំបាត់ទុក្ខព្រួយ
រៀនដឹងខ្លួនឯងរៀនគិតម្នាក់មួយ ផលបានផ្កាត្រួយរហូតចេញផ្លែ ។
រំលឹកតាតាប៉ុណ្ណឹងទៅចុះ បើមានកំហុសអត់ទោសផងដែរ
កវីវ័យក្មេងមិនសូវឈ្លាសទេ សូមចិត្តត្រឹមតែទៅវត្តខ្លះផង ។

# ២៧. សប្បាយថ្ងៃនេះគង់ទុក្ខថ្ងៃក្រោយ

អនិច្ចារូបកាយប្រែក្លាយមិនទៀង កើតឡើងហើយល្បៀងបាត់បង់ទៅវិញ
ទុក្ខខ្លាំងក្នុងចិត្តទុក្ខធំពោរពេញ ដោយក្តីទោម្នេញសោកស្តាយស្រណោះ ។
ធ្លាប់តែមើលថៃដុសលាងសម្អាត លាងជ្រះស្អាតបាតគ្មានសល់អ្វីសោះ
ផាត់ក្រែមលាបប្រេងគ្មានត្រង់ណាទាស់ អ្វីនោះទាំងអស់ត្រូវឃ្លាតឆ្ងាយហើយ ។
លែងបានថ្នាក់ថ្នមបីបមប្រលែង ឃ្លាតឆ្ងាយក្រៃលែងគ្មានវិលវិញឡើយ
ឆ្ងាយទៅៗលែងឃើញកោះត្រើយ ទុក្ខធំឥតស្បើយនៅក្នុងជីវិត ។
កើតហើយប្រាស់ព្រាត់គ្មានអ្វីឃាត់បាន ដឹងចុះកល្យាណវាជារឿងពិត
ឥតក្លែងបន្លំឥតមានប្រឌិត ពោលតាមតែចិត្តដែលធ្លាប់សិក្សា ។
សប្បាយថ្ងៃនេះគង់ទុក្ខថ្ងៃក្រោយ មិនគួរបណ្តោយច្រណែនឫស្យា

គួរតែដើរតាមព្រះពុទ្ធដីកា ទ្រង់ត្រាស់ទេសនាឱ្យលះធម៌ហ្នឹង ។
ធម៌អកុសលផ្តល់តែក្តីទុក្ខ វ៉ាសវ៉ាងចាកសុខដែលធ្លាប់រំពឹង
ថាកើតមកហើយមានគោលពុំហ្នឹង ឥឡូវស្វាត់ឈឹងព្រោះអកុសល ។
នាំសត្វវង្វេងភ្លេចជាតិកំណើត ភ្លេចពេលដែលកើតរងទុក្ខច្របល់
ឥឡូវសប្បាយភ្លេចចលាចល ថ្ងៃមួយបាបផ្តល់គង់ដឹងខ្លួនទេ ។
ទម្លាប់មនុស្សយើងឱ្យតែបានសុខ ជួបភាពស្រណុកគ្រប់អស់យើងគេ
ភ្លេចភាពក្រីក្រទុក្ខគ្មានទំនេរ ពេលនេះមាសមេភ្លេចភពខ្លួនឯង ។
ជួបជុំសប្បាយក្អាកក្អាយថ្ងៃនេះ ឃើញភាពដូច្នេះកុំអស់ចំបែង
ដល់ថ្ងៃក្រោយទៅទុក្ខធំបែកផ្សែង សប្បាយក្រៃលែងប្រែក្លាយជាទុក្ខ ។
មានតែអប់រំបន្ទុំសន្តាន ឱ្យបានថ្កើនថ្កានទៅជាតិខាងមុខ
ដើម្បីខ្លួនឯងព្រមទាំងម៉ែពុក បានជួបក្តីសុខដល់ព្រះនិព្វាន ។

# ២៨. កំណាជីវិត

កំណាជីវិតពិតមិនទៀង ជួនរាំងជួនភ្លៀងជាធម្មតា
មិនអាចហាមឃាត់ជោគវាសនា ឱ្យប្រែផ្កាប់ផ្ងារពីនេះឡើយ ។
ព្រាត់ប្រាស់ជួបជុំមានគ្រប់គ្នា ទុក្ខសោកគ្រាំគ្រាទុក្ខឥតស្បើយ
រឿងជីវិតនេះទុក្ខណាស់ហើយ ចុះម្តេចតោះតើយធ្វើមិនដឹង ។
មានប្រុសស្រីខ្លះព្រាត់គ្រួសារ មួយជាតិនេះណាទុក្ខម្ល៉ឹងៗ
រស់បៀមសោកសៅដៅក្រឡឹង ទុក្ខខ្លាំងយ៉ាងហ្នឹងព្រោះហេតុអ្វី ។
ដើមហេតុមកពីពង្រាត់គេ តាំងពីបុព្វេដល់ភពថ្មី
ជារឿងមួយហួសនឹងពោលស្តី ព្រោះតែអ្វីៗកន្លងហួស ។
មានតែផ្តើមសាងជីវិតថ្មី លើភពផែនដីនេះទៅចុះ
កុំសាងកម្មពៀរនាំរងគ្រោះ អ្វីណាជ្រុលជ្រួសជាមេរៀន ។
រឿងបាត់រឿងបង់នៃសង្ខារ សឹងគ្រប់រូបាតែងកើតមាន
មិនអាចគេចរួចពីរបៀន មានក្រអត់ឃ្លានជាសង្ខារ ។
ប្រឹងប្រែងឱ្យណាស់ច្បាស់ជួបសុខ សូន្យទៅកងទុក្ខកុំមកវ៉ា
ស្លាប់កើតៗស្លាប់ជាធម្មតា មិនអាចប្រែផ្ងារក្រៅនេះឡើយ ។
រឿងព្រាត់ប្រាស់គ្នាណាមិនស្តាយ ចង់រស់ជុំកាយបានល្ហែល្ហើយ

សុខខ្លះទុក្ខខ្លះតែងមានហើយ　　មិនគួររូបអើយព្រាត់គ្នាសោះ ។
អ្នកមានទ្រព្យធនស៊ុនធ្វើទាន　　កុំឱ្យអត់ឃ្លានរូបក្រៀមក្រោះ
ទានជាទេវធមិល្អស្ម័គ្រស្មោះ　　គួរចិត្តសន្តោសធ្វើឱ្យច្រើន ។
បានផលកម្រៃពីការធ្វើ　　ទ្រព្យច្រើនអន្លើតែងកើតកើន
សម្បត្តិទាំងនេះគួរបង្កើន　　ធ្វើទានឱ្យច្រើនទើបបានផល ។
មិនគួរបណ្តោយរឿងនេះទេ　　គួរខិតខំថែទើបបុណ្យផ្តល់
ទៅកើតឋានសួគិដោយកុសល　　ឋានសុខរៀងដល់លុះអវសាន្ត ។
កំណើតទេវតាថ្លៃថ្លាណាស់　　ដេកស៊ីបុណ្យចាស់ដោយស្រោកស្រាន្ត
បើដេកភ្លេចខ្លួនរមែងបាន　　ធ្លាក់ចុះពីឋានជួបទុក្ខា ។
កុំភ្លើតកុំភ្លើននឹងសម្បត្តិ　　ប្រយ័ត្នខ្វាយខ្វាត់ដូចខ្ញុំថា
គួរសាងបន្ថែមថែរក្សា　　បុណ្យច្រើនកាលណាល្អកាលនោះ ។
ទោះបីចុតិពីទេវតា　　ក៏គ្រប់រូបាមិនរងគ្រោះ
ព្រោះចិត្តយើងថែមិនរង្គោះ　　គួរដឹងទៅចុះខិតខំធ្វើ ។
កំណាជីវិតចារមកហើយ　　រូតរះកាត់ត្រើយគ្រប់សារពើ
កំណើតជាមនុស្សថ្លៃមែនតើ　　ត្រូវតែសរសើរកំណើតខ្លួន ។
សីលទានភាវនាជាទ្វារសុខ　　ទ្វារឃ្លាតចាកទុក្ខទីរុនរួន
ខំសាងខំធ្វើឱ្យមាំមួន　　ទើបសម្រេចផ្ទួនបានសុខា ។

បើមិនអើពើសីលជាដើម ពិតតែចាប់ផ្តើមនឹងកាមា
ជាទុក្ខវែងឆ្ងាយឈឺខ្លោចផ្សា ដឹងចុះដីវ៉ាគួរខំប្រឹង ។
ចាប់ធ្វើពីនេះផ្តើមឥឡូវ ត្រួសត្រាយវែកផ្លូវហើយសម្លឹង
ដើរក្នុងអង្គមគ្គហើយជញ្ជឹង រិះគិតថ្លែងថ្លឹងឱ្យបានល្អ ។
រៀបរាប់រឿងរ៉ាវខាងលើនេះ សូមអ្នកត្រិះរិះក្នុងសាច់ធម៌
បានជាកុសលផ្តល់បវរ រួចហើយបន្តប្រតិបត្តិ ។
តែងជាគតិគ្រាន់ពិចារណា លះតួអត្តាឱ្យចេញបាត់
ចាប់យកហេតុផលចិត្តស្ងប់ស្ងាត់ ដើម្បីកម្ចាត់តួកិលេស ។

# ២៩. ផល៥ប្រការជ្រះថ្លាស្តាប់ធម៌

សព្វសាធុការថ្លាសទ្ធា សូមអារាធនាព្រះធម៌ថ្លៃ
ដែលព្រះសម្ពុទ្ធជាជិនស្រី ទ្រង់បានពោលស្តីត្រាស់ទេសនា ។
ព្រះធម៌វិន័យជាមរតក មានក្នុងបិដកពុទ្ធសាសនា
គួរតែបើកមើលដោយជ្រះថ្លា ទើបបានផលាអានិសង្ស ។
បើមិនបានមើលដោយខ្លួនឯង គួរស្តាប់ការស្តែងដោយព្រះសង្ឃ ។

យកចិត្តទុកដាក់ដោយផ្ចិតផ្ចង់ ព្យាយាមតម្រង់ចិត្តខ្លួនឯង ។
ស្តាប់ដោយគោរពបានបញ្ញា តម្រង់សោតាឆ្ពោះគម្ពែង
ដែលលោកខំប្រាប់ខំសម្តែង ឱ្យជនចាស់ក្មេងបានយល់អត្ថ ។
វិស័យសាវ័កសាវិកា ក្នុងព្រះសាសនាបរិស័ទ
ត្រូវតែស្តាប់ធម៌ទើបកម្ចាត់ កិលេសបង់បាត់ចិត្តថ្លាស្អាត ។
ជនណាស្តាប់ធម៌ដោយគោរព ព្យាយាមថ្ងៃយប់ខំសង្វាត
កន្លះគាថាឬមួយបាទ បញ្ញាវៃឆ្លាតផល៥យ៉ាង ។
ទី១ស្តាប់ធម៌ដែលថ្មោងថ្មី មានព្រះជិនស្រីជាតំណាង
លើកយកបុគ្គលជាភស្តុតាង ហើយសម្តែងអាងប្រៀបនឹងធម៌ ។
ទី២ស្តាប់ហើយរឹតតែច្បាស់ ឥតប្រែក្រឡាស់ចិត្តស្មោះសរ
សិក្សាអប់រំយ៉ាងអំណរ ផលមានបន្តជាបន្ទាប់ ។
ទី៣លះបង់ចិត្តសង្ស័យ ដែលមានរាល់ថ្ងៃមិនគួរគាប់
ផលស្តាប់ទេសនាជាកំណប់ វាអាចតាមជាប់យើងគ្រប់ជាតិ ។
ទី៤យល់ត្រូវក្នុងទេសនា កើតចិត្តជ្រះថ្លាឥតឃ្លៀងឃ្លាត
លះភាពសៅហ្មងគ្រប់មារយាទ ផលបន្តទៀតមានដូចជា ។
ទី៥ស្តាប់ហើយកើតជ្រះថ្លា កើតមានបញ្ញាលះទ្រព្យា
លះបង់សម្បត្តិបរិច្ចាគា ក្នុងព្រះភគវាមានជាអាទិ៍ ។

សូមសាធុជនស្តាប់ឱ្យចំ កុំឱ្យច្រឡំក្នុងឱវាទ
សង្កេតផលផដោយវៃឆ្លាត ចិត្តថ្លាល្អស្អាតកើតឋានសួគ៌ ។

## ៣០~ អស្សុជផរោចកឋិនវត្តស្នាច់

អស្សុជផរោចត្រូវថ្ងៃជ័យ ថ្ងៃមានសិរីយ៉ាងបវរ
ត្រូវថ្ងៃកឋិនចិត្តស្មោះសរ រីករាយត្រេកអរយ៉ាងសប្បាយ ។
ជួបជុំបរិស័ទទីឆ្ងាយជិត ប្រមូលមូលមិត្តយ៉ាងរីករាយ
ថ្ងៃបុណ្យចូលរោងមានតាយាយ រៀបចំសម្ភាយត្រៀមធ្វើបុណ្យ ។
ក្មេងចាស់ប្រុសស្រីយ៉ាងកុះករ រៀបចំបបរឥតស័យស៊ុន
ទទួលរាក់ទាក់ភ្ញៀវក្រោយមុន សប្បាយពេកពន់ជួបជុំគ្នា ។
ស្តាប់ព្រះបរិត្តយកផលា ដោយក្តីជ្រះថ្លាឥតថយរា
ស្ងប់ស្ងៀមផ្ចង់ចិត្តដោយសទ្ធា សូត្រចប់វន្ទាខមាទោស ។
ក្រោយមកត្រងត្រាប់ស្តាប់ទេសនា ដែលព្រះថេរាទ្រង់សន្តោស
លើកយកព្រះធម៌ឥតឃ្លាតខុស ទឹកចិត្តជួយប្រោសត្រាស់សម្តែង ។
វែកញែកបទបាទយ៉ាងច្បងច្បាស់ ឥតប្រែក្រឡាស់ទៅឆ្ងាយផ្សេង

ស្តាប់ដោយជ្រះថ្លាល្អក្រៃលែង ព្រោះតែគម្ពែងឆ្លាតវាងវៃ ។
រៀបរាប់អានិសង្សកឋិន ធ្វើឱ្យមាសឆ្អិនយល់សេចក្តី
អស់ការសង្ស័យរាប់រយន័យ ព្រោះតែម្ចាស់ថ្លៃត្រាស់ទេសនា ។
លុះព្រឹកស្អែកឡើងញាតិមូលមី រួតរះសម្តីគួចប្រាថ្នា
ប្រញាប់មកវត្តចិត្តគិតថា ចង់ថ្វាយភត្តាដល់ព្រះសង្ឃ ។
ដើម្បីយកបុណ្យយកកុសល សម្រេចមគ្គផលទានគ្រប់អង្គ
មុនឱ្យពេលឱ្យដោយផ្ចិតផ្ចង់ ឱ្យហើយតម្រង់ជ្រះថ្លាទៀត ។
សាវ័កសាស្តាអស្ចារ្យណាស់ ទាំងក្មេងទាំងចាស់ខំខ្ចីឃ្លាត
សន្សំកុសលផលគ្រប់ជាតិ ថ្ងៃក្រោយមិនឃ្លៀតជាប់និស្ស័យ ។
នាទីបន្តចូលថ្ងៃត្រង់ ញាតិមិត្តរហង់ផ្ចង់ចិត្តថ្លៃ
ថ្វាយទានដល់សង្ឃត្រេកអរក្រៃ ស្ងួត្រធមិផងនៃរីករាយណាស់ ។
ក្រោយពេលព្រះសង្ឃឆាន់ភត្តា រួចរាល់កាលណាមនុស្សក្មេងចាស់
ទទួលក្រោយសង្ឃឥតប្រែផ្លាស់ ដោយក្តីសោមនស្សគ្រប់ៗគ្នា ។
ម៉ោង១រសៀលហែស្បង់ស្បៃ សាដកល្បៀងត្រៃច្រើនមហិមា
ដង្ហែពាជុំព្រះវិហារ រួចហើយគ្នីគ្នារៀបតរិយា ។
រងចាំទទួលគ្រូបណ្ឌិត អគ្គៈពេកពិតដោយជ្រះថ្លា
ដើម្បីត្រងត្រាប់ស្តាប់ទេសនា សន្សំបញ្ញាទៅជាតិមុខ ។

ក្រេបរសព្រះធម៌ដោយសទ្ធា ញាតិមិត្តគ្រប់គ្នាឃ្លាតចាកទុក្ខ
កើនដោយបញ្ញាបានក្ដីសុខ ទន្ទេញចាំទុកប្រតិបត្តិ ។
ចិត្តបុណ្យកើតហើយត្រូវរក្សា កុំឱ្យខូចការឆ្ងាយបង់បាត់
តែហ៊ានទុកយូរពិតរសាត់ មិនអាចកម្ចាត់បាបបានឡើយ ។
ក្រោយស្ដាប់ទេសនាថ្លាសទ្ធា លោកគ្រូមានងាររវេរឱ្យហើយ
សម្រេចផលឪចិត្តស្រាកស្បើយ បានឃើញកោះត្រើយព្រោះធ្វើទាន ។
សូមសាធុជនគ្រប់ទិសទី ជ្រះថ្លាសម្ដីសូមកើតមាន
ចាក់ធ្លុះសច្ចះដល់និព្វាន អស់ការស្រេកឃ្លានតរៀងទៅ ។

# ៣១- សិក្សា

ខំប្រឹងសិក្សាយកចំណេះ ពីគ្រូដែលចេះដឹងជាងយើង
កុំប្រើមានះចិត្តទំនើង ត្រូវបម្រើភ្លើងដោយគោរព ។
មើលអានទន្ទេញដោយប្រពៃ ចាប់យកសេចក្ដីរាល់ថ្ងៃយប់
បំបាត់ងងឿងឆ្ងល់យ៉ាងសព្វគ្រប់ ទើបអាចបញ្ឈប់ភាពល្ងង់ខ្លៅ ។
ចំណេះវិជ្ជាមិនងាយរក គួរតែឆាប់ក្រោកលះហ្មងសៅ

វិជ្ជាសស្អាតមិនមែនខ្មៅ ខិតខំប្រដៅចិត្តខ្លួនឯង ។
កុំចាំតែគេប្រាប់ទើបរៀន ស្មារតីកើតមានគោរពក្រែង
អប់រំព្យាយាមតាមជាក់ស្តែង ខំប្រឹងខ្លួនឯងទើបចេះដឹង ។
សុ ចិ បុ លិ ទាំងបួននេះ គួរខំត្រិះរិះគិតជញ្ជឹង
ឈ្វេងយល់ឱ្យច្បាស់ល្អយ៉ាងហ្នឹង ទើបបានទីពឹងក្នុងសិក្ខា ។
សិក្សារៀនសូត្រជាទ្វារមួយ ផ្តល់ជាជំនួយឱ្យចាស់ក្លា
ហើយចូលទៅដល់ទើបដឹងថា ទ្វារនៃសិក្ខាធំក្រៃលែង ។
ចេះគិតចេះស្តាប់ចេះពិចារណ៍ គួរដឹងចុះណាទាំងនេះឯង
ព្រោះតែការរៀនអស់ចំបែង ត្រូវចៀសពីល្បែងខុសទាំងឡាយ ។
គួរដឹងចុះណាសិក្សាល្អ សិក្សាក្នុងធម៌ចិត្តសប្បាយ
អង្គមគ្គជាផ្លូវត្រូវត្រួសត្រាយ ដូចខ្ញុំបរិយាយលើនេះហោង ។

# ៣២. អន្លង់ជីវិត

នេះនឹងបរិយាយស្រាយក្នុងជីវិត  បងប្អូនឆ្ងាយជិតគ្រប់ទីកន្លែង
មិនថាប្រុសស្រីតូចធំចាស់ក្មេង  ចូរស្ដាប់ប្រិតប្រៀងបានកើតបញ្ញា ។
ខ្ញុំនឹងរៀបរាប់អន្លង់ជីវិត  ធ្លាក់ជ្រៅពេកពិតក្នុងភពកាមា
ព្រោះតែភ្លាំងភ្លាត់ឥតស្គាល់សាសនា ដែលព្រះសម្មាទ្រង់បានត្រាស់ដឹង ។
សប្បាយភ្លេចខ្លួនជូនធ្លាក់ជ្រៅទៅ  លុបដំណើរផ្លូវដែលធ្លាប់ខំប្រឹង
បែរមកជួបទុក្ខស្រែកថ្ងូរម្លឹងៗ  រឿងទាំងអស់ហ្នឹងកើតមកពីណា? ។
ព្រោះតែវង្វេងភ្លេចគិតពីខ្លួន  ធ្លាប់តែមាំមួនឥឡូវឫស្យា
ធ្លាក់កាន់តែជ្រៅក្នុងភពអន្ធកា  លែងដឹងកិច្ចការសព្វគ្រប់សារពើ ។
ចិត្តកាន់តែងប់ជ្រប់ក្នុងកាមគុណ  ភ្លេចកូនប្រពន្ធស្ដីថាលែងជឿ
មានតែវាយដំច្រំគ្រប់ទង្វើ  នេះហើយចូលមើលបាបអកុសល ។
ទោសនៃកាមាចារក្នុងពុទ្ធសាសន៍  ច្បាស់ប្រាកដណាស់សូមញាតិកុំឆ្ងល់
ឥតឱ្យសុខស្ងប់មានតែខ្វាយខ្វល់  រងទុក្ខច្របល់ព្រោះតែរឿងហ្នឹង ។
ឈ្លោះទាស់ទែងគ្នាប្ដីប្រពន្ធឯង  ឈ្លក់ស្រីស្រាល្បែងឈានដល់កំហឹង
កាប់ចាក់បាញ់ចោះព្រោះតែក្រោធខឹង រឿងទាំងប៉ុណ្ណឹងចូរដឹងគ្រប់គ្នា ។
ប្ដីលួចមានស្រីលបលាក់គ្រួសារ  ធ្វើឱ្យមរណាដួងចិត្តភរិយា

ប្ដឹងផ្ដល់ចូលក្ដីផ្អើលអស់មីងមា　　ព្រោះតែកាមាប្រហារចិត្តស្មោះ ។
ធ្លាប់តែជួបជុំស្នេហាភក្ដី　　ឥឡូវអស់ន័យប្រែជាក្រៀមក្រោះ
អន្លង់ជីវិតរៀបរាប់មិនអស់　　ភក្ដីស្នេហ៍ស្មោះប្រួលប្រែសាវ៉ា ។
សូមឱ្យស្វាមីប្រណីភរិយា　　កុំឱ្យគ្រាំគ្រាព្រោះតែកាមា
គួរតែស្រណោះពេលផ្ដើមរៀបការ　　ញាតិមិត្តបាចផ្កាអបអរសាទរ ។
បានគ្នាជាគូមេត្តាប្រណី　　ដល់ដួងហឫទ័យកុំនាំវឹកវរ
ចេះស្រលាញ់គ្នាថ្នាក់ថ្នមបីពរ　　កុំឱ្យវឹកវរនាំកើតទោសា ។
រៀបរាប់ខ្លីៗគ្រាន់គិតពិចារណា　　ដឹងទោសកាមាចូរគេចគ្រប់គ្នា
ហ៊ានតែនៃបនិត្យរងទុក្ខវេទនា　　គ្រប់ជាតិនានាក្នុងសង្សារវដ្ដ ។
អន្លង់ជីវិតរឿងពិតមនុស្សា　　ខ្ញុំតែងកាព្យារៀបជាប្រវត្តិ
សូមអស់ប្រុសស្រីដឹងហើយកុំភ្លាត់　　រឿងពិតជូរចត់អន្លង់ជីវិត ។

# ៣៣~ ជីវិតមានកម្ម

រលកបោកបក់រសាត់ទៅឆ្ងាយ   រសាត់ប៉ាត់ប៉ាយឥតមានទិសដៅ
លះបង់នាមដើមដែលធ្លាប់ឋិតនៅ   ធ្វើដំណើរទៅតាមខ្សែទឹកហូរ ។
ជួនលិចអណ្តែតតាមទីផ្សេងៗ   ប៉ើងឆ្ងាយក្រៃលែងគួរឱ្យអាសូរ
ពេលខ្លះគេរើសតាមជ្រោះដងអូរ   ពេលខ្លះថ្ងូចថ្ងូរគ្មានទីបំផុត ។
ប្រៀបនឹងមនុស្សក្រាកម្មាគាក់តែង   ទួញសោកសង្រេងរំភើបតក់ស្លុត
កំព្រាមាតាឯការទ្ធត់   គួរឱ្យស្រយុតជាប់ដួងហឫទ័យ ។
អត់ឃ្លានមានក្រត្រដរខំរស់   រកបាយដាក់ពោះហេតុតែនិស្ស័យ
កើតមកខ្វះទ្រព្យរស់ដូចឥតន័យ   បែកឆ្ងាយទីទៃពីញាតិបងប្អូន ។
ឥតមានគេដឹងប្រឹងដោយខ្លួនឯង   ជួបទុក្ខចំបែងខំបិទមាត់ស្ងួន
ហេតុតែខ្លួនក្រគ្មានញាតិពាក់ពួន   រសាត់ដូចក្បូនទៅតាមខ្សែទឹក ។
បើមិនស្វែងរកបានអ្វីដាក់ពោះ   ជាតិនេះរងគ្រោះមិនគួររឮក
នឹកឃើញកាលណាចិន្តាវរវើក   ឱ្យតែរឮកទឹកភ្នែកហូរឯង ។
ឱ ! កម្មឬស្សាវាសនាខ្ញុំអើយ   ខ្ញុំយល់ច្បាស់ហើយពីទុក្ខចំបែង
ទឹកភ្នែកទួញសោកបក់បោកក្រៃលែង   តាំងពីខ្លួនក្មេងរហូតខ្លួនចាស់ ។
តើជាតិណាទៅខ្ញុំរួចផុតទុក្ខ   បានជួបក្តីសុខឥតប្រែប្រួលឡាស់

ខ្ញុំសូមសច្ចាឱ្យបានឃើញច្បាស់ ជាតិនេះកម្មក្រាស់ជាតិក្រោយសុខសាន្ត ។

# ៣៤~ អារម្មណ៍បាត់មិត្រពិតជាឯកា

មើលផ្ទៃអាកាសស្រទន់ចិន្តា ឃើញហ្វូងតារាពាសពេញមេឃា
ធ្វើឱ្យចិត្តខ្ញុំស្ងប់ទុក្ខមួយគ្រា យកព្រះធម្មាជាឧបមា ។
សម្លឹងមើលសត្វបំបាត់ទុក្ខសោក ធ្លាប់មានរាគរោគវិយោគតណ្ហា
ឥឡូវស្ងប់ស្ងាត់ដោយកុសលា គុណព្រះសាស្តាទ្រង់ត្រាស់សម្តែង ។
ចំណែករូបខ្ញុំកំព្រាឯកា នឹកឃើញកាលណាចិន្តាចំបែង
ធ្លាប់រស់ជួបជុំឥឡូវប្រែផ្សេង ដេកដើរម្នាក់ឯងវែងអផ្សុកណាស់ ។
ធ្លាប់មានគ្នីគ្នាសន្ទនាឆ្លងឆ្លើយ ពេលនេះចប់ហើយចិត្តប្រែក្រឡាស់
មិត្រភក្តិស្និទ្ធស្នាលវ័យក្មេងចំណាស់ ឥឡូវព្រាត់ប្រាស់បែកគ្នាអស់ហើយ ។
ពេលរស់ជុំគ្នាសប្បាយដោយធមិ មានចិត្តស្មោះសរឥតប្រែតោះតើយ
មាននំចំណីឥតភ្លេចគ្នាឡើយ មួយម៉ាត់ក៏ដោយតែងបែងចែកគ្នា ។
មកដល់ពេលនេះនឹកអនុស្សាវរីយ៍ នឹកគ្រាសិក្សានឹកពេលសន្ទនា
តែដល់ពេលនេះទ្រូងសែនគ្រាំគ្រា រស់នៅរងានឹងភាពឯកា ។

តើថ្ងៃណាទៅខ្ញុំបានជួបមិត្រ? ទោះទីឆ្ងាយជិតក៏ខ្ញុំមិនថា
ឱ្យតែឃើញភក្ត្រក៏អស់ចិន្ដា ព្រោះភាពឯកាមិនងាយស្រួលទេ ។
មានមិត្រល្អមួយជួយឱ្យចិត្តស្ងប់ ស្និទ្ធស្នាលគួគាប់រីងរឹតតែទ្វេ
ចេះជឿទុកចិត្តមិនក្បត់យើងគេ មុខក្រោយរិះរេចេះគិតចេះគួរ ។

## ៣៥~ យប់ស្ងាត់បាត់ម៉ែ

យប់អើយយប់ស្ងាត់ យប់មានវិបត្តិ ចិត្តតែងប្រួលប្រែ
យប់នេះខ្ញុំយំ រងំឥតល្ហែ ព្រោះហេតុបាត់ម៉ែ
ខ្ញុំសែនសោកស្ដាយ ។
ធ្លាប់តែជួបជុំ រស់នៅសុខដុម សើចលេងសប្បាយ
ឥឡូវឃ្លាតឃ្លា ឆ្ងាយអើយសែនឆ្ងាយ លោកទាំងពីរកាយ
កូនសែនរឭក ។
យប់កាន់តែជ្រៅ ចិត្តកូនដិតនៅ មិនថាយប់ព្រឹក
កូនតែងឯកា ឈឺផ្សារឭក រាល់ថ្ងៃវររឹក
តែងធ្វើបុណ្យផ្សង ។

កើតជាតិណា។ កូនសូមប្រាថ្នា ឱ្យដូចបំណង
ទោះបីបាត់ម៉ែ តែកូនចាំចង ចិត្តកួចនឹកប៉ង
ឱ្យបានជួបម៉ែ ។

កូននឹងធ្វើបុណ្យ មិនឱ្យស័យស៊ុន បីបាច់មើលថៃ
បម្រើថ្នាក់ថ្នម រាល់ថ្ងៃរាល់ខែ ឱ្យដូចអ្នកម៉ែ
មើលបីបាច់កូន ។

តែក្នុងជាតិនេះ កូនមានតម្រិះ តែងធ្វើបុណ្យជូន
ទោះបីម៉ែស្លាប់ បិទមាត់បាត់សូន្យ ក៏រូបកូន។
មិនចោលម៉ែដែរ ។

# ៣៦_ អាសូរពុកម៉ែ

ម៉ែអើយ។ម៉ែ ម៉ែមានគុណណាស់ គុណក្រៃគុណក្រាស់ធំជាងលោកា
គុណដោយទឹកចិត្តអាណិតមេត្តា បណ្តុះវាសនាឱ្យកូនប្រុសស្រី ។
តាំងពីកូនតូចរហូតកូនធំ ពេញរូបក្រមុំមក៏ម៉ែពោលស្តី
ដាស់តឿនទូន្មានរាល់ពេលយប់ថ្ងៃ ចងភ្ជាប់និស្ស័យឱ្យកូនផុតទុក្ខ ។

ទោះបីនឿយហត់ខ្សត់ទ្រព្យាក្តី ពុកម៉ែមិនថ្វីខំធ្វើសម្រុក
ធ្វើការស៊ីឈ្នួលយប់ថ្ងៃមិនសុខ ឃ្លាតពីស្រណុកក៏គាត់មិនថា ។
ឱ្យតែកូនរស់ឈ្មោះល្អប្រពៃ ដួលដេកម្តេចក្តីក៏មិនវាចា
អ្នកផ្សេងមើលងាយពេបជ្រាយយ៉ាងណា ក៏មិនឈឺផ្សាព្រោះតែរូបកូន ។
ពេលខ្លះដាច់បាយឃ្លាតឆ្ងាយពីទឹក ក៏មិនរឭកខំបិទមាត់ស្ងួន
ឱ្យតែរូបកូនជួបជុំបងប្អូន ពុកម៉ែស្លាប់ខ្លួនក៏គាត់មិនស្តាយ ។
កូនគួរអាសូរទឹកចិត្តពុកម៉ែ ចិត្តកុំកែប្រែឃ្លាតពីពុកម្តាយ
កុំសេពគ្រឿងញៀនជាផលអន្តរាយ រងទុក្ខវែងឆ្ងាយទៅជាតិខាងមុខ ។
ត្រូវតែខិតខំឱ្យគ្រប់ជ្រុងជ្រោយ តែកុំបណ្តោយកូនអើយចាំទុក
កូនមានលុយចាយសប្បាយផ្លូវសុខ ព្រោះតែម៉ែពុកជាអ្នកមើលថែ ។
បើគាត់មិនខ្វល់តាំងពីកំណើត ក៏កូនមិនកើតឃើញពន្លឺខែ
ឋានៈទ្រព្យធនកូនបានហូរហែ កូនមានដឹងទេបានមកពីណា? ។
អ្វីៗទាំងអស់ផ្តើមពីរូបគាត់ រហូតធំធាត់បានចូលសាលា
ចេះដឹងផ្លូវលោកនិងផ្លូវសាសនា ព្រោះតែករុណាគុណលោកទាំងពីរ ។
ទាន់នៅមានម៉ែកុំប្រែក្រឡាស់ ធ្វើឫកផ្តេសផ្តាសនាំចិត្តវក់វី
ទុកម៉ែឪចោលភ្លេចកិច្ចនាទី មិនខំសម្តីធ្វើបុណ្យឱ្យហើយ ។
ព្រះរស់នៅមានត្រូវប៉ិនសាងល្អ ធ្វើចិត្តស្មោះសរកូនកុំភ្លេចឡើយ

ប្រយ័ត្នគាត់ស្លាប់រងទុក្ខឥតស្បើយ ដឹងទេត្រានត្រើយកុំឡើយនៅយូរ ។
ពាក្យពេចន៍ផ្ដែផ្ដាំចាំកុំបំភ្លេច បើកបិទហើយធ្វេចធ្វើជាគំរូ
សាងល្អធ្វើល្អឆ្ពោះគុណទាំងគូ តិចច្រើនឆាប់យូរក៏បានបុណ្យដែរ ។

## ៣៧~ ស្រណោះម៉ែខ្ញុំ

រាត្រីស្ងប់ស្ងាត់សព្វសត្វនិទ្រា ក្រោមស្បៃសន្ធិយាសែនមានក្ដីសុខ
ឥតគិតពីកាយនឿយណាយកើតទុក្ខ ព្យាយាមសម្រុកមានតាំងពីថ្ងៃ ។
ដើម្បីជីវិតពិតជាតស៊ូ ចេះគិតចេះគូរសន្សំសំចៃ
បានប្រាក់យកមកទុកឱ្យកូនថ្លៃ ដើម្បីចរណៃចាយវាយសប្បាយ ។
តែខ្លួនគាត់វិញឥតហ៊ានហូបឆ្ងាញ់ រិះខាំកំណាញ់មិនហ៊ានខ្ជះខ្ជាយ
ព្រោះប្រាក់បានមកមិនមែនដោយងាយ ព្យាយាមច្រើនថ្ងៃទើបបានប៉ុណ្ណេះ ។
ឱះឱ ! ម៉ែខ្ញុំធ្វើកម្មធ្ងន់ណាស់ ទាំងខ្លួនគាត់ចាស់រូបកាយស្ទើរប្រេះ
ព្រោះតែជីវិតទើបធ្វើដូច្នេះ អ្វីៗទាំងនេះបានមកពីម៉ែ ។
គួរអាសូរចិត្តអាណិតរូបម្ដាយ តែកូនសប្បាយមិនដែលមើលថែ
ដល់ពេលគាត់ឈឺទើបកូនមកក្បែរ តើសមដែរទេកូនធ្វើអ៊ីចឹង? ។

ឱ ! កូនទាំងឡាយគួរគិតឱ្យច្បាស់ នឹកឃើញដល់ព្រះដែលគាត់ខំប្រឹង
កុំអាងខ្លួនចេះធ្វើឫករាងរឹង កូនធ្វើបែបហ្នឹងមិនបានអីទេ ។
គួរតែតបស្នងសងគុណឱ្យច្រើន នឹងលើកតម្កើនត្រកូលបិតថេរ
កុំធ្វើបែកបាក់នាំតែខ្មាសគេ ដឹងហើយមាសមេគួរធ្វើឱ្យបាន ។

# ៣៨- ព្រះធម៌ជួយបាន

សម្លឹងមើលផ្កាយរំសាយទុក្ខសោក ខ្យល់បក់វិយោគលើផ្ទៃវេហាស៍
ពពកខ្ពួលខ្មាញ់ដូចចង់វាចា ឥតបានសង្ខារសាត់ឆ្ងាយទៅ ។
ចំណែករូបខ្ញុំក៏ដូច្នោះដែរ កើតទុក្ខហួរហែក្បែររឿងរាក់ជ្រៅ
ជួបទុក្ខលំបាកជិតដាមហ្មងសៅ ប្រជិតក្រឡៅបៀមទុក្ខរាល់ថ្ងៃ ។
ហេតុអ្វីជាតិនេះកើតមកកម្សត់ ពីក្មេងដល់ចាស់ជាប់ក្នុងហប្ញទ័យ
ដេកដើរនឹកគិតដូចក្ដីស្រមៃ បេះដូងថ្លើមថ្លៃស្មើរមូលចូលគ្នា ។
តែទោះយ៉ាងណាក៏ខំបំភ្លេច ធ្មេចបើកដើរគេចទ្រាំទាំងវេទនា
បេះដូងឈឺផ្សាឯការងា ទុក្ខសោកគ្រាំគ្រាយប់ថ្ងៃល្ងាចព្រឹក ។
មានតែធម៌ព្រះជម្នះរឿងក្ដី អ្នកយល់អត្ថន័យគួរតែរឭក

សិក្សាចងចាំបុណ្យច្រើនសន្ធឹក កុំសូវវិវរឹកនឹងកាមកិលេស ។
អ្វីណាជាបុណ្យស៊ុនធ្វើឱ្យហើយ សូមកុំយូរឡើយទាន់ភ្នែកមើលច្បាស់
ដល់ពេលយូរទៅខ្លួនវ័យចំណាស់ ពិតប្រាកដណាស់ថារៀនលែងចាំ ។
ភ័ព្វព្រេងនិស្ស័យបច្ច័យផលល្អ កសាងស្មោះសរសន្សំរាប់ឆ្នាំ
ធ្វើបុណ្យស៊ុនទានចិត្តតែងចំណាំ បុណ្យជាផលកម្មជួយឱ្យបានសុខ ។
ព្រះធមិជួយបានក្សេមក្សាន្តផ្លូវចិត្ត ឃ្លាតពីវិប្បរិតធ្លាប់តែស្មាញស្មុគ
ឥឡូវស្រឡះភ្លឺច្បាស់ផុតទុក្ខ តទៅថ្ងៃមុខប្រាកដភ្លឺស្វាង ។

# ៣៩~ ជួយថែវប្បធម៌

វប្បធមិជាតិខ្មែរថែឱ្យបាន គ្រប់រូបគ្រប់ប្រាណគួរតែដឹង
ជាទង់ជាតិខ្មែរដួងព្រលឹង រឿងទាំងអស់ហ្នឹងគួរសិក្សា ។
កុំបំបាត់ចោលយករួចខ្លួន ដឹងទេមាសសួនគ្រប់រូបា
កេរមរតកខ្មែរពីដូនតា គួរតែរក្សាឱ្យគង់វង្ស ។
កើតមកកូនខ្មែរពិតសំណាង ឃើញជាភស្តុតាងគ្រប់ទម្រង់
មានខ្លុយមានស្នែងភ្លេងពេនពង្ស ល្អណាស់ឆោមយង់វប្បធមិជាតិ ។

ត្រូវជួយរក្សាឱ្យគ្រប់គ្នា សុទ្ធមានមុខងារកុំឃ្លេងឃ្លាត
តែហ៊ានបណ្ដោយប្រាកដទៀត សាសន៍ផ្សេងគេឆ្លៀតចូលរុករាន ។
សម័យឥឡូវពុំសូវគិត ឃើញច្បាស់ប្រឹត្តធ្វើបំពាន
សុខចិត្តលះបង់កេរខ្មែរមាន ឃើញទៅទន្ទ្រានយកសាសន៍គេ ។
ដល់ពេលយូរទៅខ្មែរបាត់ឈើង ភ្លេចដួងព្រលឹងហើយមាសមេ
វង្វេងជាតិខ្លួនចិត្តងាករេ តើសមឬទេធ្វើបែបនេះ? ។
ជួយថែចាប់ពីតិចទៅច្រើន នឹងលើកតម្កើនអ្នកដែលចេះ
មិនងាយរកទេផលចំណេះ គួរមានតម្រិះត្រង់នេះផង ។
កុំមើលងាយថោកអ្នកផ្សេងអី មនុស្សទាំងប្រុសស្រីច្រើនកន្លង
អ្នកខ្លះកូនក្មេងខ្លះជាបង ទាំងអស់នេះហោងសុទ្ធជាខ្មែរ ។
ខ្មែរស្រលាញ់ខ្មែរកុំងាករេ កុំឱ្យសាសន៍គេចូលមកក្បែរ
បំបាត់ឱ្យបានកុំកែប្រែ វប្បធម៌ជួយខ្មែរ ខ្មែររុងរឿង ។

# ៤០. ប្រាសាទអង្គរ

ប្រាសាទអង្គរល្អអស្ចារ្យ ក្បូរក្បាច់រចនាមានគ្រប់យ៉ាង
ព្រលឹងជាតិខ្មែរជាភស្តុតាង តម្កល់តំណាងសាសន៍ជាតិខ្មែរ ។
មិនងាយរកទេកេរដូនតា រុងរឿងភ្លឺថ្លាចារហូរហែ
រំលេចពណ៌មាសជះដួងខែ ល្អក្រៃម្ល៉េះទេកោតស្ញប់ស្ញែង ។
វីរៈបុរសស្លាប់អស់ទៅ តែបន្សល់នៅឃើញជាក់ស្តែង
បានទាំងទៅលេងគ្រប់កន្លែង តាមទីផ្សេងៗផ្ទៃប្រាសាទ ។
ជាតិសាសន៍ដទៃគេចម្លង ព្រោះតែម៉ត់ហ្មងខ្មែរសង្វាត
យូរលង់ឆ្នាំទៅខ្មែរភ្លាត់ផ្លាត ខ្មែរអើយត្រូវឆ្លាតថែឱ្យបាន ។
កុំឱ្យបរទេសលួចរចនា ក្បាច់ខ្មែរខេមរារក្សាប្រាណ
ខ្មែររួមសាមគ្គីពិតក្សេមក្សាន្ត ផលល្អតែងបានមិនបាត់ជាតិ ។
តែហ៊ានប្រហែសពិតក្សិណក្ស័យ ព្រោះអីរាល់ថ្ងៃមានខ្លះឆ្លៀត
ខ្មែរខ្លះភ្លេចពូជបង់មារយាទ ប្រព្រឹត្តឃ្លៀងឃ្លាតចូលសាសន៍គេ ។
គួរអនិច្ចាវាសនាណាស់ កេរតាំងពីចាស់មិនជួយថែ
មានតែទន្ទ្រានរាល់ថ្ងៃខែ ខ្ទេចខ្ទីហូរហែគង់តែបាត់ ។
តើពេលណាទៅខ្មែរភ្ញាក់ខ្លួន? រូតរះអង្រួនប្រុងប្រយ័ត្ន

រួបរួមសាមគ្គីជាតិសម្បត្តិ កុំឱ្យខ្ចាយខ្ចាត់ទៅសាសន៍គេ ។
គ្រាន់តែរំលឹកខ្មែរប៉ុណ្ណឹង ឱ្យជ្រួតជ្រាបដឹងកុំធ្វេសទ្វេ
បើមិនជួយប្រាប់ពិតបែកបែរ ព្រោះរាល់ថ្ងៃខែភ្លេចខ្លះហើយ ។
ខុសឆ្គងយ៉ាងណាសូមអភ័យ ដល់អស់ប្រុសស្រីទាំងឡាយអើយ
ឃ្លាចុងបញ្ចប់សូមត្រានត្រើយ ខ្មែរកុំភ្លេចឡើយប្រាសាទប្រាង្គ ។

# ៤១~ ទឹកចិត្តបងស្រី

មនុស្សគគោកមានក្នុងលោកា សន្ធឹកអស្ចារ្យតាមទីផ្សេងៗ
ក្នុងភូមិឃុំស្រុកនិគមនេះឯង ខ្លះគួរកោតក្រែងនិងគួរបូជា ។
តែមនុស្សសំខាន់មានត្រឹមមួយគត់ គួរយល់កំណត់ឱ្យបានគ្រប់គ្នា
បន្ទាប់ពីម៉ែពុកលោកជរា អ្នកនោះគឺជាបងស្រីដ៏ល្អ ។
បងស្រីមានគុណមកលើប្អូនៗ តែងរ៉ាប់យកខ្លួនដោយចិត្តស្មោះសរ
មើលថែបីបាច់ដោយវិហារធម៌ ល្អក្រៃបវរឥតអ្នកប្រៀបបាន ។
រាល់ថ្ងៃល្ងាចព្រឹករវូកជានិច្ច មិនដែលនឹកភ្លេចប្អូនៗគ្រប់ប្រាណ
តែងប្រោសប្រណីដោយកម្មកល្យាណ ឥតអ្នកណាមានទឹកចិត្តដូចបង ។

ព្រោះបងគិតថាពេលអត់ពីម៉ែ គ្មានអ្នកមើលថែឈើផ្សាកន្លង
ទឹកចិត្តបងស្រីស្រោចលើទងវង មិនឱ្យផ្កាំផ្កងទៅលើប្អូនឡើយ ។
ទោះក្តៅរងាឈើផ្សាយ៉ាងណា ក៏មិនវាចាទៅប្អូនត្រានត្រើយ
សុខចិត្តបៀមទុក្ខក្នុងខ្លួននឹងហើយ នេះជាចម្លើយរបស់បងស្រី ។
រៀបរាប់ពីទុក្ខលំបាកឈើផ្សា ទោះច្រើនប៉ុនណាក៏មិនជាថ្មី
រឿងដែលសំខាន់ខ្ញុំជាកវី មិនអាចពោលស្តីបានទាំងអស់ទេ ។
ព្រោះអីទឹកចិត្តមិនអាចវាស់បាន មានក្នុងតែប្រាណរបស់យើងគេ
ខ្លះច្រើនខ្លះតិចតាមចិត្តរិះរេ សូមត្រឹមមាសមេយល់ចិត្តបងស្រី ។

## ៤២. កំណាព្យឥតន័យ លៃសាយណ្ហះ

ស្នេហ៍គស្នាញដួងចិត្តត្បិតតែរឿងអ្វី? ឱរាហប្ញទ័យលៃតែងវីរក់
វង្វេងភ្លាំងភ្លាត់ព្រាត់ទាំងគម្រក់ ថ្លឹងថ្លែងខ្មេចខ្ជក់នរកទាំងរស់ ។
សូរសៀងសាសព្ទប្រាប់តាមដំណាល ចុកឆ្អល់បណ្តាលក្រោលលើរបស់
តម្កល់ចិត្តត្រូវផ្លូវឃើញទាំងអស់ បញ្ហាដំណោះដោះស្រាយពិតបាន ។
ខ្វះការអប់រំងំពេញដួងថៃ ធ្លាប់គិតស្រមៃមេន័យខុសចាកឋាន

ស្វែងរកពាលាជាការខកខាន អ្វីត្រូវក្សាន្តគ្រានបានត្រឹមសោកសៅ ។
សម្លឹងឱ្យឆ្ងាយប្រាយប្រាប់ឱ្យយល់ កុំងងឹងងល់ជ្រុលខុសប្រដៅ
ស្ដាយខ្លួននៅក្មេងវែងគិតរឿងឆៅ សិក្សាវិញទៅពៅមាសស្នេហ៍ស្នង ។
កំណាព្យកាព្យានាសាយណ្ហ៎ះ បញ្ចប់អស់អាក់ដាក់ពាក្យកម្រង
ខុសឆ្គងម្ដេចម្ដាមេត្តាប្អូនបង ដាច់ខាតកុំឆ្លងប៉ងជេរករិ ។

# ៤៣- កើត-ស្លាប់

រៀបរាប់រឿងទុក្ខស្មុគស្មាញឱរា ដួងចិត្តខ្លោចផ្សាឆាឆេះព្រៃផ្សៃ
ហួសនឹងថ្លាថ្លែងចែងចាប់អត្ថន័យ ទុក្ខក្នុងហឫទ័យលៃតាមលំដាប់ ។
កងទុក្ខទី១ព្រួយនឹងកំណើត ស្លាប់កើតៗឆើតឆាយរាយរ៉ាប់
ផ្លាស់ប្ដូរគ្រប់ជាតិឆ្លៀតកើតហើយស្លាប់ គួរតែប្រញាប់ឆាប់សាងកុសល ។
ជួនបានទេវតាថ្លាល្អពណ្ណរាយ ពេលខ្វះសម្ពាយលៃតាមកម្មផល
កើតក្នុងនរកវក់ចលាចល កម្មតាមជួយផ្ដល់ខ្វល់អស់មួយជាតិ ។
កងទុក្ខទី២វិក្ដីមរណា ទុក្ខសែនឈឺផ្សាណាអស់មិត្តញាតិ
គួរសាងបុណ្យទានមានផលកុំឃ្លាត សង្ឃឹមច្រើនទៀតញាតិអើយត្រូវចាំ ។

សេចក្តីស្លាប់នេះប្រេះបេះដូងថ្លើម ជាទុក្ខដ៏ឆ្អើមឆ្អើមមកពីកម្ម
ទួញសោកអាល័យក្រៃណាស់សូមផ្តាំ ទុក្ខសោករាប់ឆ្នាំចាំហើយគួរគិត ។
ទុក្ខទាំងពីរនេះរិះឱ្យមែនទែន យល់ន័យរាប់សែនបែនបត់ក្នុងចិត្ត
កើតស្លាប់ជាគូយូរមានកម្រិត ជួបទាំងគំហិតត្បិតតែកម្មា ។
សូមអស់ប្រុសស្រីថ្មីចាស់ទាំងឡាយ កុំសើចសប្បាយក្លាយមកប្រេះឆា
ប្រញាប់រូតរះជះរស្មីថ្លា កើតទាន់សាសនាថ្លាថ្លៃពិសេស ។

# ៤៤. រតនៈទាំង៣ លៃតាមកាព្យ

ជំនោររាត្រីស្តីពីកំណាព្យ ពាក្យពេចន៍ចុងចាបកាព្យតែងពីចិត្ត
ជូនញាតិប្រុសស្រីខ្ចីចាស់វរមិត្ត សូមតែកុំគិតត្បិតពាក្យមិនសម ។
រាត្រីស្មើណេះច្នេះសមលក់ស្រួល ឥតរវើប្រែប្រួលដួលតាមសំណុំ
យប់កាន់តែជ្រៅនៅតែប៉ះផ្សំ ថាមិនច្រឡំចំតែរឿងពិត ។
បន្ទាប់ពីឃ្លាងារដើមនេះទៅ សូមឱកាសផ្លូវត្រូវតាមគំនិត
លើកកាព្យអប់រំងំទាំងងងឹត ប្រុសស្រីឆ្ងាយជិតពិតជាយល់បាន ។
ព្រះរតនៈត្រៃក្រៃល្អពិសេស គួររៀនចាំចេះម្ល៉េះសមជាប់ប្រាណ

គោរពបូជានាកម្មកល្យាណ ស្ម័គ្រស្មោះកុំខានឋានសុខពេកក្រៃ ។
ទី១ព្រះពុទ្ធសុទ្ធវិសេសថ្លា គួរសាធុការថាពិតប្រពៃ
កើតឥតមានពីរឹងហឫទ័យ ដ៏ល្អថ្លាថ្លៃនៃគ្មានអ្នកប្រៀប ។
កើតឡើងសម្រាប់ចាប់យកឱកាស ជួយមនុស្សក្មេងចាស់ផ្លាស់ធមិគ្រប់បែប
ទេសន៍តាមនិស្ស័យថ្មៃចិត្តមានប្រៀប ឥតបុគ្គលធៀបប្រៀបនឹងព្រះឡើយ ។
និស្ស័យបុណ្យក្រាស់ច្បាស់ជាស្ដាប់យល់ មិនមានអំពល់វល់ទុក្ខឥតស្បើយ
ស្ដាប់យូរៗទៅផ្លូវជិតបង្កើយ និព្វានដង្ហោយហៅរកអ្នកស្ងប់ ។
ទី២ព្រះធមិល្អណាស់គួរសេព មានទាំងក្លិនក្លែបប្រៀបឋានគួរគាប់
អ្នកមានទុក្ខព្រួយជួយឱ្យជួបទ្រព្យ ជាតិនេះមានភ័ព្វជាប់ចិត្តសទ្ធា ។
ព្រះធមិជួយបានឋានសុខផុតទុក្ខ ធ្លាប់តែស្នាញស្មុគបុករុកចិន្ដា
បែរមកល្ហែល្ហើយស្បើយពីទុក្ខា ដោយគុណធម្មាជារោគផ្លូវចិត្ត ។
សិក្សាយូរទៅពៅពិតចេះដឹង ព្យាយាមសម្លឹងប្រឹងប្រើគំនិត
ចាក់ធ្លុះសច្ចៈបាក់មារឃុបឃិត ឆ្លងពីងងឹតពិតឃើញពន្លឺ ។
ទី៣ព្រះសង្ឃផ្ចង់ចិត្តជ្រះថ្លា គោរពបូជាជារោគបាត់ឈឺ
វិបត្តិផ្លូវចិត្តពិតជាជំងឺ រុករានរន្ធឹព្ធដល់កិលេស ។
ថ្វាយទានដល់សង្ឃផ្ចង់ចិត្តគោរព រាល់ថ្ងៃល្ងាចយប់ឈប់ធ្វើប្រហែស
តែបា៉នបណ្ដោយធ្លោយចិត្តធ្លាយប្រេះ យល់សង្ឃដូច្នេះម្ល៉េះកើតគ្រប់អង្គ ។

មិនងាយរកទេចិត្តដែលចង់បួស ចូលមកសាងផ្នួសឈ្មោះជាព្រះសង្ឃ
ទាល់តែនិស្ស័យលៃលកផ្ចិតផ្ចង់ ទើបអាចតម្រង់ចង់ចេញចាកកាម ។
នេះហើយរតនៈជាក់ជាព្រះគុណ ជ្រះថ្លាពេកពន់បុណ្យតែងជាប់តាម
រក្សាបុគ្គលរលក់កម្មកលប្បាណ រហូតជួបឋានបានព្រះនិព្វាន ។

# ៤៥_ ត្រជាក់នឹកម៉ែថែកូនពីតូច

ចូលខែត្រជាក់ញ័រញាក់កាយា រងាចិន្តាខ្លោចផ្សាម្ល៉េះទេ !
ធ្លាប់តែកក់ក្ដៅឥឡូវបែកបែរ មិគសិរដើមខែប្រែអ័ព្ទរស្មី ។
ព្រឹកទល់ព្រលប់យប់កាន់តែជ្រៅ ចិត្តដក់ជាប់នៅក្នុងដួងហប្ញទ័យ
ស្រងេះស្រងោចខ្លោចផ្សាដួងថៃ រឿងរ៉ាវអ្វីៗបានកន្លងហួស ។
ពីតូចដល់ធំខ្ញុំនៅនឹងម៉ែ ជាច្រើនថ្ងៃខែម៉ែតែងសន្តោស
បម្រើសព្វគ្រប់ឥតយកកំហុស ចិត្តផ្ដើមបណ្ដុះកូនឱ្យសិក្សា ។
ចូលថ្នាក់ទី១ព្រួយក្នុងហប្ញទ័យ ព្រោះអីរាល់ថ្ងៃម៉ែខំធ្វើការ
ដើម្បីបុត្រស្ងួនកូនកនិដ្ឋា លំបាកយ៉ាងណាមាតាបិទមាត់ ។
កូនសែនអាសូរហូរទឹកនេត្រា ព្រោះអីជីវ៉ារូបមិនទៀងទាត់

ជូនឈើជូនជាប្រុងនឹងប្រាស់ព្រាត់ ទោះបីខំឃាត់ក៏ឃាត់មិនបាន ។
រូបរាងកូនធំសមរម្យបន្តិច ចិត្តបែបរាងគេចពីពាក្យប្រោសប្រាណ
ម៉ែតែងអប់រំបន្ទុំសន្តាន ឱ្យកូនគ្រប់ប្រាណបានតែក្តីសុខ ។
កូនធំដឹងក្តីអ្វីៗត្រូវហួស ធ្វើឱ្យជ្រុលជ្រួសមិនស្គាល់ក្តីទុក្ខ
ធ្វើបាបចិត្តម៉ែព្រមទាំងលោកពុក កូនតែងរំអុករករឿងរាល់ថ្ងៃ ។
ព្រោះតែល្ងង់ខ្លៅប្រដៅមិនស្តាប់ ធ្វើឫកបែបយ៉ាប់ចិត្តគ្មានសំចៃ
មិនបាននឹកឃើញទឹកចិត្តម្តាយថ្លៃ ដែលក្នុងហឫទ័យម៉ែតែងអាសូរ ។
ព្រោះតែរងាកំព្រាឯកា ទើបកូនដឹងថាទឹកភ្នែកស្រក់ហូរ
ធ្លាក់ជោកភក្ត្រាចិត្តស្រែថ្ងួចថ្ងូរ ទឹកចិត្តម៉ែប្តូរហូរខ្លាំងជាងនេះ ។
ត្រជាក់នឹកម៉ែថៃកូនពីតូច កូនធ្លាប់តែងខូចគ្មានដែលត្រិះរិះ
ឥឡូវដឹងហើយទើបធ្វើដូច្នេះ កូនឈប់ប្រហែសនឹងម៉ែទៀតហើយ ។

# ៤៦. បានបុណ្យស័ក្តិខ្ពស់ព្រោះតែព្រះគុណ

នេះនឹងបរិយាយស្រាយក្នុងកំណាព្យ តែងជាពាក្យកាព្យប្រាប់ដល់ប្រុសស្រី
ដែលមានជីវិតរស់លើផែនដី ដូចមានសេចក្តីតទៅនេះថា ។
អត្តភាពជាមនុស្សប្រសើរពេកក្រៃ គួរតែលកលៃរិះគិតពិចារណ៍
គ្រប់ពាក្យនិយាយសម្តីចរចា ដំណើរយាត្រាសាសព្វក្នុងក្រៅ ។
តាំងពីកុមារចារជាកម្រង មានញាតិប្អូនបងត្រកូលញាតិផៅ
មានពុកមានម៉ែជួយស្តីប្រដៅ កុំប្រព្រឹត្តឆៅក្រោមបាតសង្គម ។
ខិតខំសិក្សាយកចំណេះដឹង រិះគិតថ្លែងថ្លឹងឱ្យបានគួរសម
រៀនក្នុងសាលាតាំងពីបឋម បានការអប់រំរហូតថ្នាក់ខ្ពស់ ។
មានលុយឡានល្អផ្ទះថ្មស្កឹមស្កៃ ទាំងអស់នេះនៃព្រោះចិត្តសង្គ្រោះ
អំពីលោកគ្រូអ្នកគ្រូដោយស្មោះ គ្រូសារវិញនោះក៏ជួយណាស់ដែរ ។
សូមអ្នកកុំភ្លេចអំពីព្រះគុណ ព្រះដ៏មានបុណ្យលោករស់នៅក្បែរ
ជួយស្តីប្រដៅអប់រំមើលថែ មានព្រះពុកម៉ែលោកគ្រូអ្នកគ្រូ ។
បើភ្លេចគុណហើយកុំឡើយបានសុខ រស់រងជួបទុក្ខរាប់ឆ្នាំជាយូរ ។
ត្រូវតែប្រយ័ត្នខំប្រឹងគិតគូរ បានជាគំរូដល់អ្នកជាន់ក្រោយ ។
គុណធំអស្ចារ្យមហាជលស័យ ប្រសើរពេកក្រៃអ្នកកុំបណ្តោយ

បើមានឱកាសតបស្នងកុំធ្លោយ ព្រោះលោកបានជួយឱ្យយើងចេះដឹង ។
រៀបរាប់អត្ថន័យខ្លីៗគួរយល់ ចិត្តកុំអំពល់ព្យាយាមជញ្ជឹង
ដេកដើរនឹកគិតគុណធំយ៉ាងហ្នឹង ខំប្រឹងសម្លឹងគិតរៀងរាល់ថ្ងៃ ។

## ៤៧~ ប្រវត្តិកម្រ្ទី ស្រីមានចិត្តស្មោះ

ខេត្តកំពង់ឆ្នាំងបាំងភ្នំកម្រើ ប្រវត្តិទឹកដីនៃជីវិតខ្ញុំ
រស់នៅសុខសាន្តពីតូចដល់ធំ សប្បាយជួបជុំនឹងក្រុមគ្រួសារ ។
រឿងរ៉ាវស្មោះស្នេហ៍នៃនាងកម្រើ ដិតក្នុងហឫទ័យនៃជនខេមរា
សិក្សាស្រាវជ្រាវកប់ក្នុងអក្ខរា ពិតឃើញច្បាស់ថាចារក្នុងប្រវត្តិសាសន៍ ។
ឱ ! អនិច្ចាវាសនាស្រីស្មោះ លង់នឹងកម្លោះកន្លង់រិទ្ធិសែន
ស្មានថាប្រុសស្នេហ៍ឥតប្រែសាមាន្យ ចិត្តស្រីខកខានបានតែទឹកភ្នែក ។
ហេតុអ្វីជាតិនេះកម្មក្រាស់អ្វីម្ល៉េះ ! បេះដូងស្ទើរប្រេះចុកឆ្អល់ពន់ពេក
សេចក្ដីសង្ឃឹមមានច្រើនអនេក ឥឡូវប្រែប្លែកសាបសូន្យអស់ហើយ ។
ជាតិជាប្រុសសោះហេតុអ្វីប្រួលប្រែ ក្រឡាស់ចិត្តស្នេហ៍ប្រែក្បត់គ្រានត្រើយ
ជាតិនេះជាតិមុខមិនចង់ជួបឡើយ ឱះឱ ! កម្មអើយម្ដេចមិនមេត្តា ។

ខ្ញុំនាងកង្រើកូនស្រីយក្ខទេ ប៉ុន្តែមាសមេចាប់ចិត្តស្នេហា
ចង់រួមមេត្រីក្នុងឋានសួគ៌ា បានប្រាណពុំងាងាកចិត្តពីស្រី ។
ស្រីណាមិនឈឺស្រីណាមិនយំ ទ្រូងណែនអួលងំព្រោះប្រុសអប្រិយ
អាក្រក់ជូរជាតិគ្មានគិតហឫទ័យ ធ្វើឱ្យរូបស្រីរងទុក្ខខ្លោចផ្សា ។
ខ្ញុំរៀបខ្ញុំរាប់ប្រវត្តិកង្រើ ទ្រូស៧សេចក្តីប៉ុណ្ណឹងចុះណា
ខុសឆ្គងមិនសមសូមអត់ទោសា ព្រោះរឿងស្នេហាតែងតែប៉ះពាល់ ។

# ៤៨~ តំណក់ទឹកភ្នែក កូនស្រែករកម៉ែ

តំណក់ទឹកភ្នែកជ្រែកលើវង់ភក្ត្រ ហូរចុះទម្លាក់ទ្រូងសែនខ្ទេចខ្ទាំ
ស្រក់មានហេតុផលចិត្តខ្វល់រេរាំ សើមសាចជោកជាំលើវង់ភក្ត្រា ។
តំណក់ទឹកភ្នែករំលែកការឈឺ ទ្រូងសែនរន្ធឹតតពាក្យសង្កា
មានតែសម្រក់ឱ្យអស់ចុះណា៎ ! រន្ធត់ខ្លោចផ្សាឥតនរណាដឹង ។
តំណក់ទឹកភ្នែកយំយែករៀបរាប់ ចិត្តអើយអភ័ព្វកម្សត់យ៉ាងហ្នឹង
លែងបានមើលថៃរាល់ខែស្វាត់ឈឹង មានតែរំពឹងជួបម៉ែជាតិក្រោយ ។
តំណក់ទឹកភ្នែកកូនហែកចិត្តថ្លើម ធ្វើការផ្តួចផ្តើមមិនហ៊ានបណ្តោយ

ខំប្រឹងរកប្រាក់មិនឱ្យថ្លោះធ្លោយ ព្រោះគ្មានអ្នកជួយដូចម៉ែនៅរស់ ។
តំណក់ទឹកភ្នែកឥតបែកជាពីរ ព្យាយាមសម្ដីមើលថែសង្គ្រោះ
ដល់រូបប្អូនៗខ្លាចឃ្លានដាច់ពោះ ឱ្យមានកេរ្តិ៍ឈ្មោះដូចគេដទៃ ។
តំណក់ទឹកភ្នែកថ្ងៃស្អែកឈប់គិត ដល់រឿងអតីតនាំឱ្យហប្ញទ័យ
ខ្វល់ខ្វាយវីវក់រស់ឥតប្រពៃ ខំប្រឹងលក់លៃប្រមូលទ្រព្យា ។
តំណក់ទឹកភ្នែកស្រែកប្រាប់លោកា អង្វរទេវតាក្នុងឋានសួគ៌ា
មើលមករូបខ្ញុំផ្ដុំគ្រប់អង្គា រស់រងវេទនាកំព្រាមាតា ។
តំណក់ទឹកភ្នែកជ្រែកពុះផែនដី ចង់ប្រាប់អត្ថន័យក្នុងចិត្តសោកា
ខ្ញុំសែនសោកស្ដាយថ្ងៃដែលមរណា ទ្រូងអើយខ្លោចផ្សាមាតាស្លាប់ចោល ។
តំណក់ទឹកភ្នែកអនេកអនគ្ឃ ហូរទាំងអួលអាក់ស្រក់ធ្លាក់តែលតោល
ឥតមានទិសដៅដូចសេះខំបោល រស់ទាំងកំរោលចិត្តបោលពីប្រាណ ។
តំណក់ទឹកភ្នែកពន់វែកព្រះគុណ គឺសែនមហាធ្ងន់កូនគ្រប់សន្ដាន
ជាតិនេះជាតិមុខសូមឱ្យខ្ញុំបាន កើតក្នុងទីឋានបានរស់ជុំម៉ែ ។

# ៤៩~ ពុក

**ពុក** ជាព្រះរស់មានឈ្មោះប្រពៃ **ពុក** មានភក្តីនឹងកូនគ្រប់គ្នា
**ពុក** តែងដាស់តឿនគ្រប់ពេលវេលា **ពុក** ឈឺគ្រាំគ្រាក៏ពុកមិនថា ។
**ពុក** ខំខ្លាំងណាស់ទោះថ្ងៃល្ងាចព្រឹក **ពុក** តែងរឭកកូនកនិដ្ឋា
**ពុក** ក្តៅរងាឈឺចាប់ខ្លោចផ្សា **ពុក** ឥតវាចាថាលំបាកឡើយ ។
**ពុក** ចិញ្ចឹមកូនឥតបានទាមទារ **ពុក** ឈឺរងាររងទុក្ខឥតស្បើយ
**ពុក** មិនប្រាប់កូនថ្លៃមាសត្រានត្រើយ **ពុក** ទ្រាំបានហើយខ្លាចកូនលំបាក ។
**ពុក** មានចំណីអាហារឆ្ងាញ់ៗ **ពុក** មិនកំណាញ់ទោះរកតោកយ៉ាក
**ពុក** ផ្តល់ឱ្យកូនមុនថ្ងៃសម្រាក **ពុក** ឃ្លានឥតស្រាកក៏ពុកមិនស្តី ។
**ពុក** ជាកម្មករធ្វើការឱ្យកូន **ពុក** លំបាកខ្លួនក៏ពុកមិនថ្វី
**ពុក** ចង់ឱ្យកូនរស់មានសួស្តី **ពុក** តែងលកលៃរកប្រាក់រាល់ថ្ងៃ ។
**ពុក** មានតែមួយនៅក្នុងលោកា **ពុក** ជាទេវតាថែកូនប្រុសស្រី
**ពុក** តែងអប់រំទូន្មានហប្ញទ័យ **ពុក** ធ្វើរាល់ថ្ងៃដោយក្តីពេញចិត្ត ។
**ពុក** កាន់តែចាស់ប្តូរផ្លាស់រាល់ថ្ងៃ **ពុក** នឿយដួងចៃក៏ពុកមិនគិត
**ពុក** ខំខ្លាំងណាស់ដើម្បីជីវិត **ពុក** ចាស់ពេកពិតតែពុកខំប្រឹង ។
**ពុក** កងការពារធានារ៉ាប់រង **ពុក** តែងអន្ទងរិះគិតថ្លែងថ្លឹង

**ពុក** ខំកែប្រែកូនមាសព្រលឹង **ពុក** ធ្វើអ៊ីចឹងដើម្បីតែកូន ។
**ពុក** ល្អខ្លាំងណាស់ឥតផ្លាស់ជាពីរ **ពុក** ខំសម្ដីដើម្បីមាសស្ងួន
**ពុក** ជួយរៀបចំឱ្យបានសមសួន **ពុក** គិតនឹមន្ទួនជាជាងខ្លួនពុក ។
**ពុក** ខំពីក្មេងរហូតដល់ចាស់ **ពុក** វ័យចំណាស់ចេះតែស្មាញស្មុគ
**ពុក** តែងគិតថាពីនេះទៅមុខ **ពុក** ពិតជាទុក្ខលែងបានថៃកូន ។

# ៥០~ ម៉ែ

**ម៉ែ** ខំធ្វើការដើម្បីបុត្រថ្លៃ **ម៉ែ** នឿយម្ដេចក្ដីខំបិទមាត់សូន្យ
**ម៉ែ** ត្រេកអរខ្លាំងពេលបានរូបកូន **ម៉ែ** លំបាកខ្លួនក៏ម៉ែមិនគិត ។
**ម៉ែ** ប្រឹងប្រែងខ្លាំងច្បាំងនឹងឧបសគ្គ **ម៉ែ** ធ្វើឥតដាក់ទោះទីឆ្ងាយជិត
**ម៉ែ** អើយម៉ែខ្ញុំម៉ែល្អពេកពិត **ម៉ែ** តែងនែបនិត្យនឹងកូនពិសី ។
**ម៉ែ** មានគុណណាស់ច្បាស់ជាព្រះរស់ **ម៉ែ** ខំពពោះទោះនឿយហប្ញទ័យ
**ម៉ែ** ឥតស្រែកថ្ងូរព្រោះតែចរណៃ **ម៉ែ** មានភក្ដីនឹងកូនស្រីប្រុស ។
**ម៉ែ** គឺជាស្រីដែលមានចិត្តធ្ងន់ **ម៉ែ** ខំពេកពន់ដោយចិត្តសន្ដោស
**ម៉ែ** ល្អខ្លាំងណាស់ឥតយកកំហុស **ម៉ែ** តែងអត់ទោសឱ្យកូនគ្រប់ប្រាណ ។

ម៉ែ ម៉ែម៉ែម៉ែកូនទឹកម៉ែណាស់ ម៉ែ គឺជាព្រះមានចិត្តក្សេមក្សាន្ត
ម៉ែ ជួយឱ្យកូនបានរស់សុខសាន្ត ម៉ែ ប្រដូចបាននឹងឋានសួគ៌ា ។
ម៉ែ ចង់ឱ្យកូនរស់មានកេរ្តិ៍ឈ្មោះ ម៉ែ ឥតរកឈ្លោះនឹងកូនគ្រប់គ្នា
ម៉ែ តែងអាណិតអប់រំបុត្រភ្ងា ម៉ែ ជួយការពារឱ្យផុតទុក្ខសៀយ ។
ម៉ែ មានតែមួយនៅក្នុងលោកា ម៉ែ ជាទេវតាចិត្តឥតកន្តើយ
ម៉ែ ចង់ឱ្យកូនរស់នៅល្ហែល្ហើយ ម៉ែ តែងប្រាប់ហើយប្រាប់ទៀតគ្រប់សព្វ។
ម៉ែ តែងបួងសួងដល់អស់ឥន្ទព្រហ្ម ម៉ែ ចង់ជួបជុំនឹងកូនសំណព្វ
ម៉ែ ខ្លាចបែកបាក់គ្មានថ្ងៃបញ្ចប់ ម៉ែ មិនដែលស្អប់កូនម្តងណាឡើយ ។
ម៉ែ ល្អយ៉ាងនេះឥតមានអ្នកប្រៀប ម៉ែ ផ្តល់គ្រប់បែបមិនដែលតោះតើយ
ម៉ែ លះបង់ណាស់ដើម្បីត្រានត្រើយ ម៉ែ ជាខ្នល់ខ្មើយកូនកើយរាល់ថ្ងៃ ។
ម៉ែ អើយកូនសូមរំលឹកព្រះគុណ ម៉ែ សែនមហាធ្ងន់ដល់កូនថ្លើមថ្លៃ
ម៉ែ រស់លំបាកក៏ម៉ែមិនស្តី ម៉ែ ជួយប្រុសស្រីលុះថ្ងៃមរណា ។

# ៥១~ ក្មួន

**ក្មួន** មាសថ្លើមថ្លៃប្រុសស្រីទាំងឡាយ **ក្មួន** គិតកុំណាយក្នុងគុណពុកម៉ែ

**ក្មួន** ត្រូវបម្រើបីបាច់មើលថែ **ក្មួន** គួរគ្នាន់គ្នេរធ្វើរៀងរាល់ថ្ងៃ ។

**ក្មួន** កុំសម្ដីវែងខ្លីតូចធំ **ក្មួន** គួរបង្គំផ្ចង់ចិត្តថ្លាថ្លៃ

**ក្មួន** គួរប្រយ័ត្នមុននឹងហាស្ដី **ក្មួន** ត្រូវលកលៃគ្រប់ពេលវេលា ។

**ក្មួន** ធ្វើដោយស្មោះឥតសោះកន្ដើយ **ក្មួន** ប្រុសស្រីអើយចូរដឹងគ្រប់គ្នា

**ក្មួន** បានផលានិសង្សនានា **ក្មួន** ផុតវេរាព្រោះតែព្រះគុណ ។

**ក្មួន** ធ្វើយ៉ាងណាកូនបានយ៉ាងនោះ **ក្មួន** កុំបន្ទោសត្រូវសាងផលបុណ្យ

**ក្មួន** កើតមកក្រត្រដរទារុណ **ក្មួន** ត្រូវដឹងមុនថាមកពីកម្ម ។

**ក្មួន** មិនត្រូវជេរប្ញស្ដីប្រមាទ **ក្មួន** មានក្បួនខ្នាតដែលគួរចងចាំ

**ក្មួន** ខ្វះបុណ្យទានទើបកូនប្រេះស្រាំ **ក្មួន** ត្រូវចំណាំកុំបន្ទោសព្រះ ។

**ក្មួន** ដឹងឱ្យច្បាស់កុំផ្លាស់ធ្វើខុស **ក្មួន** គួរអត់ទោសកុំចង់យកឈ្នះ

**ក្មួន** គិតរាល់ថ្ងៃដាក់ចិត្តមានះ **ក្មួន** មានជម្នះលើចិត្តខ្លួនឯង ។

**ក្មួន** គឺជាភ្នែករបស់ពុកម៉ែ **ក្មួន** សុខហូរហែគ្មានទុក្ខចំបែង

**ក្មួន** គួរដឹងចុះមិនមែនគេផ្សេង **ក្មួន** អើយនោះឯងគឺជាព្រះរស់ ។

**ក្មួន** កុំបំភ្លេចគុណលោកទាំងពីរ **ក្មួន** គួរសម្ដីឱ្យបានខ្ពង់ខ្ពស់

**ក្មួន** តបស្នងគុណកុំយកកេរ្តិ៍ឈ្មោះ **ក្មួន** គិតឱ្យអស់មុននឹងធ្វើអ្វី ។
**ក្មួន** បានដឹងហើយចូរស្បើយទុក្ខា **ក្មួន** គ្រប់រូបាណាទាំងប្រុសស្រី
**ក្មួន** គិតឱ្យល្អិតល្អិតពាក្យមានន័យ **ក្មួន** គួរប្រណើដល់ម៉ែនិងពុក ។
**ក្មួន** មានជីវិតពិតជាប្រពៃ **ក្មួន** គិតកុំខ្ជីវាយជាទំនុក
**ក្មួន** ប្រឹងឱ្យណាស់ច្បាស់ជាជួបសុខ **ក្មួន** អើយម៉ែពុកសូមលាសិនហើយ ។

# ៥២. ថ្ងៃបុណ្យឈូងអែល ប្រហែលខ្មែរភ្លេច !

ខ្ញុំសូមរៀបរាប់ភ្ជាប់ដោយអត្ថន័យ ជូនមិត្តប្រុសស្រីគ្រប់ៗអង្គា
ទុកពិចារណាកំណាព្យកាព្យា យល់ដឹងគ្រប់គ្នាមានដូច្នេះថា ។
ទិវា២៥ចងចាំជានិច្ច ខ្មែរមិនដែលភ្លេចថ្ងៃបុណ្យនេះណា
គឺបុណ្យណូអែលប្រហែលរូបា ភ្លេចខ្លួនយល់ការថាជាអ្វីផង ។
បុណ្យជាតិសាសនាមានសឹងរាល់ខែ គ្រប់រូបកូនខ្មែរមិនសូវនឹកប៉ង
ភ្លូកភ្លឹកកួចនឹកឱ្យច្រើនម៉ត់ហ្មង ទៅជាប៉ុនប៉ងចាំថ្ងៃនេះវិញ ។
បណ្តាញសង្គមនិយមប្រើណាស់ ទាំងក្មេងទាំងចាស់ឥតទុក្ខទោម្នេញ
ហ្វេសបុកផ្តាច់ចិត្តអាណិតនោះមិញ គ្រប់ផុសទន្ទេញចង់បានកាដូ ។

ខ្ញុំមិនថាថ្វីប្រុសស្រីទាំងឡាយ តែកុំសប្បាយយកខ្លួនទៅប្តូរ
អាណិតពុកម៉ែគាត់យំស្រែកថ្ងូរ ថៃទាំកូនយូរមកអស់ថ្ងៃហ្នឹង ។
សូមខ្មែរកុំភ្លេចបុណ្យជាតិសាសន៍ឯង ខិតខំប្រឹងប្រែងធ្វើចិត្តនឹងធឹង
តែខ្មែរភ្លេចខ្លួនខ្មែរពិតស្វាត់ឈឹង ធ្វើអ្វីត្រូវដឹងថាខ្លួនជាខ្មែរ ។
ខ្ញុំជួយដាស់តឿនក្រើនតែប៉ុណ្ណឹង ជាតិសាសន៏ព្រលឹងចូរខិតខំថែ
មួយទៀតសាសនាក៏គួរគិតដែរ ត្រូវចូលជិតក្បែរឱ្យបានគ្រប់គ្នា ។
ខ្មែរចេះរក្សាថ្លៃថ្លាបវរ ខ្មែរមានសីលធមិផុតទុក្ខវេទនា
ខ្មែរធ្លាប់តែល្បីក្បូរក្បាច់នានា ខ្មែរមានពូជធាជាអ្នកអង្គរ ។

# ៥៣~ កុំភ្លេចខោនដោន !

ជំនោររសាត់បក់ផាត់តាមខ្យល់ ខោនដោនមកដល់រៀមខ្ចល់ទៀតហើយ
គួរឱ្យស្រណោះរងទុក្ខឥតស្បើយ គ្មានបានអ្វីឡើយសល់តែសោកា ។
វ័យកាន់តែចាស់ផ្លាស់ប្តូររាល់ថ្ងៃ ធ្វើឱ្យហឫទ័យជួបក្តីមរណា
កុំសើចសប្បាយខោនដោននេះវ៉ា រាល់រូបសត្តាប្រែការតាមឆ្នាំ ។
គួរគិតឱ្យច្បាស់កុំណាស់តាមគ្នា ព្រោះពេលវេលា២០១៥

| | |
|---|---|
| បានឃ្លាតទៅឆ្ងាយគ្មានពាក្យផ្តែផ្តាំ | បេះដូងរងកម្មទទួលឆ្នាំថ្មី ។ |
| សែនអនិច្ចាវាសនាកម្សត់ | ជីវិតជូរចត់រួមចិត្តអប្រិយ |
| ឆ្នាំចាស់ផ្លាស់ទៅថាមានសិរី | តែដូចឥតន័យបានអ្វីមកសោះ ។ |
| ផ្លាស់ប្តូរកាយាវាចាដួងចិត្ត | កែប្រែគំនិតកុំគិតក្រៀមក្រោះ |
| គួរសាងកុសលផលល្អឥតខ្ចោះ | ទទួលសម្រស់២០១៦ ។ |
| មារយាទខុសឆ្គងទំនងមិនសម | គួរណាស់តែខំផ្សែផ្សំកុំព្រួយ |
| សាងជីវិតថ្មីអប្រិយជ្រោះជ្រោយ | សូមឱ្យរលួយតាមឆ្នាំចាស់ចុះ ។ |
| កិរិយារៀបរាប់តភ្ជាប់ធមិអាថិ | ឱ្យគិតពិចារណ៍ប្រែគំនិតខុស |
| ចំណងឆ្នាំចាស់ក្រឡាស់ទុយិស | ចង្រែរងគ្រោះបរវេសចៀសឆ្ងាយ ។ |
| កុំភ្លេចខោនដោនបង្អោនចិត្តថ្មី | ទទួលសិរីហប្ញទ័យចិត្តកាយ |
| ដេកដើរនឹកគិតពិតកុំរសាយ | ឆ្នាំថ្មីកុំណាយប្រាយប្រាប់ឱ្យដឹង ។ |
| គិតល្អធ្វើល្អបវរក្រៃក្រាស់ | កុំដូចឆ្នាំចាស់ណាស់មិនខំប្រឹង |
| បណ្តោយតាមចិត្តគំនិតយ៉ាងហ្នឹង | នរកពេញធឹងតើពឹងនរណា? ។ |
| សូមជូនពរជ័យសិរីបវរ | ដល់ញាតិធមិនៅក្នុងលោកា |
| សូមបានសម្រេចដូចក្តីប្រាថ្នា | អន្ទោលសង្សារសូមបានសុខហោង ។ |

# ៥៤~ ច្បាប់ប្រដៅកូនចៅប្រុសស្រី

លើកហត្ថបង្គំរតនៈត្រ័យ ប្រសើរពេកក្រៃក្នុងចិន្តា
ជួយផ្តល់សិរីដល់សត្តា នៅក្នុងរដ្ឋាទាំងមូលនេះ ។
ខ្ញុំសូមលើកច្បាប់ប្រាប់ប្រុសស្រី ក្មេងក្តីចាស់ក្តីគួរត្រិះរិះ
មិនត្រូវភ្លើតភ្លើនហួសចំណេះ ក្រែងលោទ្រូងប្រេះក្ស័យសង្ខារ ។
ប្រមាទពានពារក្នុងជីវិត ឥតមានទឹកគិតដល់គ្រួសារ
ដែលខំបីបាច់ដោយហត្ថា អប់រំបុត្រភ្ងាដោយទឹកចិត្ត ។
ក្មេងៗឥឡូវច្រើនហ៊ឺហា ប្រកបស្រីស្រាទីឆ្ងាយជិត
មិនស្តាប់ម៉ែឪផ្លូវគំនិត វិថីជីវិតសែនអាប់អួរ ។
ដើរលេងផ្តេសផ្តាស់ខ្វះសីលធម៌ ឫកពាមិនល្អគួរអាសូរ
អាណិតទឹកចិត្តម្តាយស្រែកថ្ងូរ ទឹកភ្នែកស្រក់ហូរព្រោះតែកូន ។
ចំណែកកូនវិញសើចសប្បាយ ផឹកស៊ីក្អាកក្អាយណាស់មាសស្ងួន
ភ្លេចទាំងម៉ែឪខំថែថ្នម យកឆ្អែតតែខ្លួននិងសង្សារ ។
លុយកាក់ម្តាយរកយប់ព្រឹកថ្ងៃ ខំប្រឹងសំចៃព្រោះអ្នកណា?
កូនជំរិតទារឥតមេត្តា ដល់ដួងនេត្រាមាតាសោះ ។
បើគាត់មិនឱ្យអាងសម្លាប់ ចាក់បាញ់វាយកាប់ចិត្តមិនស្មោះ

លោតទឹកចង.ក ដោយកំហុស ឯមាតានោះស្ទើរក្ស័យប្រាណ ។
ព្រោះតែមេត្តាការស្រលាញ់ ខាំចិត្តខ្ជួលខ្ជាញ់ក្នុងសន្ដាន
មិនឱ្យកូនស្លាប់ឃ្លាតចាកឋាន ប្រឹងប្រែងឱ្យបានផ្ដល់ជូនកូន ។
ទោះក្ដៅរងាជាឈឺក្ដី ក៏មិនជាថ្វីបិទមាត់ស្ងូន
ធ្វើការយប់ថ្ងៃស្ទើរស្លាប់ខ្លួន ព្រោះតែមាសស្ងួនកូនតឹងទារ ។
ជួនបុលបញ្ចាំទ្រព្យរបស់ អ្វីៗទាំងអស់ក្នុងទ្រព្យា
ឱ្យតែកូនរស់ទោះវេទនា ក៏មិនវាចាប្រាប់កូនឡើយ ។
នេះហើយទឹកចិត្តព្រះអរហន្ត មកលើតូចតន់ថ្លៃត្រានត្រើយ
សុខចិត្តស្លាប់ខ្លួនព្រោះកូនហើយ ម្ដេចនៅតោះតើយនឹងម្ដាយទៀត ។
គួរណាស់អាណិតដល់ចិត្តម៉ែ ដែលខំមើលថែទ្រូងឥតឃ្លាត
វវល់យ៉ាងណាមាតាឆ្អៀត គំនិតមារយាទថ្លៃថ្លាណាស់ ។
កូនអើយដឹងហើយគួរកោតក្រែង កុំវក់នឹងល្បែងក្រែងផ្ដេសផ្ដាស
នាំអស់ទ្រព្យធនប្រាកដច្បាស់ ស្ដាប់ពាក្យចាស់ៗប្រៀនប្រដៅ ។
ម៉ែប្រាប់ឱ្យល្អក្នុងសង្គម ដែលគេនិយមប្រាប់កូនចៅ
ឱ្យដើរផ្លូវត្រូវកុំល្ងង់ខ្លៅ មិនមានហ្មងសៅក្នុងចិន្ដា ។
បើកូនហ៊ានល្មើសនឹងច្បាប់ហើយ ធ្លាក់ជ្រោះឃ្លាតត្រើយដូចមរណា
ចូលកាន់តែជ្រៅភពអន្ធកា ឈឺចាប់ខ្លោចផ្សារាប់ខែឆ្នាំ ។

ទម្រាំឡើងមកក្នុងលោកា ពិតយូរណាស់ណាកូនត្រូវចាំ
ព្រោះតែភ្លេចគុណនិងបណ្តាំ គួរតែចំណាំឱ្យបានច្បាស់ ។
ទាន់មានជីវិតពិតប្រសើរ ខិតខំប្រឹងធ្វើកុំក្រឡាស់
ប្រយ័ត្នធ្លាក់ជ្រោះដូចពាក្យចាស់ ដែលបានតឿនដាស់កូនប្រុសស្រី ។
ច្បាប់ទាំងប៉ុន្មានដែលរៀបរាប់ សុទ្ធសឹងតែភ្ជាប់ដោយអត្ថន័យ
ដើម្បីអប់រំផ្លូវប្រពៃ គួរតែលកលៃយកពិចារណ៍ ។
ដើម្បីសុខសួគ៌ក្នុងត្រៃលោក លាចាករាគរោគរូបតណ្ហា
ដែលកប់ដេកត្រាំក្នុងចិន្តា ឱ្យបានភ្លឺថ្លាព្រោះប្រព្រឹត្ត ។
កវីវ័យក្មេងតែងប៉ុណ្ណេះ បានជាចំណេះចេះពេកពិត
សន្សំកសាងដោយសុចរិត ទើបអនាគតគាប់ឧត្តម ។
ខុសត្រូវម្តេចម្តាសូមខន្តី អត់ទោសកវីក្រែងមិនសម
មិនត្រូវទឹកចិត្តឬច្រឡំ សូមកែឱ្យចំផងចុះណា ! ។
នៅទីបញ្ចប់សូមជូនពរ អបអរសាទរឆ្នាំថ្មីវ៉ា
សូមបានសម្រេចដូចប្រាថ្នា ដោយពាក្យសច្ចានេះឯងហោង ។

ថ្ងៃសុក្រ ០៧រោច ខែមិគសិរ
ឆ្នាំមមែ សប្តស័ក ព.ស.២៥៥៩ (០១.០១.២០១៦)

# ៥៥‐ អ្វីៗសម្រេចលើចិត្ត

ខ្ញុំសូមសម្ដែងថ្លែងពីរឿងចិត្ត ផ្ដល់ជាគំនិតគិតគ្រប់មិត្តា
បានជាចំណេះចេះដឹងធម៌អាថ៌ ចេញផលផ្លែផ្កាសាសព្វប្រុសស្រី ។
នៅក្នុងរដ្ឋាចារជាកម្រង មានញាតិប្អូនបងសង្ឃរាស្ត្រមន្ត្រី
បើបានយល់ហើយស្បើយទុក្ខរឹងរៃ កប់ដោយអត្ថន័យលៃតាមហេតុផល ។
គិតពោលថ្លែងស្ដីអ្វីៗគ្រប់សព្វ ស្រលាញ់ឬស្អប់ចប់ជាប់ខ្វាយខ្វល់
នឿយកាយហត់ចិត្តត្បិតរឿងអំពល់ វឹវក់វិលវល់ងល់ទាំងយប់ថ្ងៃ ។
ទាំងអស់នេះឯងចែងពីមនោ លេចធ្លាយចេញធ្លោជោរតាមស្រមៃ
បើគិតផ្លូវត្រូវសូវផលកម្រៃ ទ្រព្យធនច្រើនក្រៃអ្វីៗក៏ល្អ ។
តែបើគិតខុសហួសពេលនឹងកែ ធ្លាក់ជ្រោះជ្រៅក្បែរកែលែងបវរ
ខូចទាំងកិត្តិយសឈ្មោះក៏សាយសរ ផ្សព្វផ្សាយត្រដរល្អលុបបាត់ហើយ ។
ដូច្នេះចិត្តនេះរិះគិតគ្រប់គ្នា កុំសេពពាលាវាទុក្ខឥតស្បើយ
នាំទាំងខ្លួនប្រាណខាននៅក្បែរកើយ គ្មានសង្ឃឹមឡើយត្រើយព្រះនិព្វាន ។

# ៥៦. អំណាចឫស្យាប្រហារចិត្តស្ងប់

វិបត្តិផ្លូវចិត្តពិតជាទារុណ លែងស្គាល់បាបបុណ្យគុណអ្វីទាំងអស់
អំណាចមោហៈបាក់ចិត្តទាំងស្រស់ មើលឃើញរបស់សោះឥតតម្លៃ។
សែនអនិច្ចាការដើរផ្លូវមារ ប្រព្រឹត្តពានពាលាលះរាល់ថ្ងៃ
ព្រោះតែមិនច្បាស់ណាស់ក្នុងហឫទ័យ ធ្វើឱ្យអ្វីៗលែមិនសមហេតុ។
ពីមុនបានព្នឈឺក្នុងចិត្តម្តង ឥឡូវផ្តោះផ្តងប៉ងច្បាស់ក្រឡែត
ព្រោះតែល្ងង់ខ្លៅខ្មៅចិត្តត្រសែត ធ្វើឱ្យអណ្តែតប្រេតពេញមេឃា។
គួរណាស់តែប្រាប់ឆាប់ឱ្យបានដឹង កុំយករឿងហ្នឹងប្តឹងដល់ពាលា
នាំហិនប្រយោជន៍ខូចគ្រប់ការងារ ព្រោះតែមារាងារមកសន្និត
សែនស្តាយកំហុសខុសលើរូបអ្នក អំណាចទោសៈបាក់គ្រប់កម្រិត
មើលមុខលែងចំផ្សំរឿងអតីត ធ្វើយ៉ាងកំហិតត្បិតតែអ្នកធំ។
ច្រណែននិន្ទាលាហើយជាតិនេះ កើតឡើងដូច្នេះប្រេះទ្រូងប៉ុនភ្នំ
ព្រោះតែបាក់មុខទុក្ខអ្នកឡើងធំ ធ្វើទុក្ខឱ្យខ្ញុំកុំសាងកម្មពៀរ។
ពីមុនស្និទ្ធស្នាលក្រាលដូចកន្ទេល ឃើញមុខរាបរៀលពេលគ្មានវេរា
ព្រោះតែច្រណែនបែនចិត្តគ្រប់គ្រា មិត្តរួមការងារជាជាប់អប្រិយ។
កំណាព្យរៀបរាប់ជាប់ដោយកង្វល់ ថ្ងៃនេះរកកលខ្វល់ក្នុងហឫទ័យ

ចិត្តនៅមិនសុខបុករុករាល់ថ្ងៃ រឿងរ៉ាវអ្វីៗលៃឱ្យអស់ហើយ ។
រៀបរាប់រឿងពិតត្បិតឆ្អល់ឱរា ឈឺចាប់ខ្លោចផ្សាក្លាខ្លាំងឥតស្បើយ
ជាតិនេះជាតិមុខទុក្ខកុំជួបឡើយ ឬស្បាគ្មានត្រើយកើតលុះថ្ងៃស្លាប់ ។

# ៥៧-  អនុស្សាវរីយ៍ពីអតីត

រឭករឿងចាស់ផ្លាស់ទីឋាន ធ្លាប់រស់សុខសាន្តបានបែកបាក់
ឃ្លាតកាន់តែឆ្ងាយចិត្តអល់អាក់ កើតគ្រប់ៗថ្នាក់រឿងអតីត ។
អនុស្សាវរីយ៍ទីគ្រប់សព្វ ឥឡូវបញ្ចប់ត្រឹមការគិត
គួរឱ្យស្រណោះខ្លួនពេកពិត ធ្លាប់ជួបនៃបនិត្យពោលផ្ដោះផ្ដង ។
រសាត់បាត់ឆ្ងាយកាយមិនសុខ រស់រងក្ដីទុក្ខសែនមួរហ្មង
កម្មផ្ដាច់និស្ស័យឃ្លាតចំណង ឃ្លាតឃ្លាកន្លងប៉ងលែងបាន ។
សែនអនិច្ចាវាសនាខ្ញុំ ពីមុនជួបជុំរស់សុខសាន្ត
សើចលេងសប្បាយគ្មានថ្ងៃខាន រីករាយស្រស់ស្រាន្តបានសុខា ។
ជួបជុំសប្បាយក្លាយជាទុក្ខ វិយោគស្នាញស្លុតគ្រប់កាយា
តែងជួបប្រទះគ្រប់សត្តា មិនអាចតវ៉ាកម្មបានឡើយ ។

ថ្ងៃនេះរីករាយក្រោយបែកបែរ រងទុក្ខឥតល្ហែគ្មានថ្ងៃស្បើយ
ព្រោះតែព្រាត់ប្រាស់រឿងនេះហើយ បានជាចម្លើយថាមិនសុខ ។
បញ្ចប់ចុងក្រោយគួរសាងល្អ ទើបរស់បវរឃ្លាតចាកទុក្ខ
ផុតពីអន្ទាក់នៃមច្ចុ លែងបានជួបមុខដល់សួគ៌ា ។
បើបានសុខហើយកុំភ្លេចខ្លួន គួរអប់រំស្ងួនផុតវេទនា
ប្រព្រឹត្តធម៌ព្រះឈ្នះផ្លូវមារ ផុតកម្មវេរាលោកិយ ។
អនុស្សាវរីយ៍ពីអតីត ខ្ញុំតែងបែបគិតប្រាប់ប្រុសស្រី
ឱ្យយល់រឿងរ៉ាវកើតសព្វថ្ងៃ កុំតូចហឫទ័យនៃព្រាត់ប្រាស់ ។
បញ្ចប់កាព្យាទី១២ មករាសម្ព័ទាំងក្មេងចាស់
ប្រឹងប្រែងកុំដាក់ទោះប្តូរផ្លាស់ វេលាច្រើនណាស់ខ្វះអ្នកធ្វើ ។

# ៥៨~ វាលវដ្តសង្សារមហាសាគរ

អំណាចទោសៈបង្វឹកសត្វលោក វិលវល់វិយោគក្នុងវដ្តសង្សារ
ព្រោះតែកម្មក្រាស់បម្រាស់ឫស្យា ធ្វើឱ្យខ្លោចផ្សាក្នុងទុក្ខដ៏ធំ ។
វាលវដ្តសង្សារមហាវេទនា ទុក្ខសោកគ្រាំគ្រារួមប្រមូលផ្តុំ

បង្កើតបានជាដង្ហោយស្រែកយំ ដ៏មហាសុខុមគ្មានថ្ងៃស្រាកស្រាន្ត ។
ព្រាត់ប្រាស់គ្រួសារយាយតាបងប្អូន វិនាសផ្ទួនៗគ្មានអ្វីឃាត់បាន
ជួនស្លាប់ពីក្មេងជាការខកខាន បុណ្យទានក្មេងមក្សាន្តមិនទាន់បានធ្វើ ។

## ៥៩- ឃ្លាតមាតុភូមិព្រោះខ្ញុំក្រ

ស្រុកខ្មែរដីកេរពីដូនតា យូរលង់ឆ្នាំរ៉ាខ្មែរថ្កើនថ្កាន
ព្រោះតែសាមគ្គីគ្រប់ៗប្រាណ ផលល្អតែងបានស្រស់ពណ្ណរាយ ។
ពីមុនរស់ជុំក្នុងគ្រួសារ សប្បាយហ៊ឹហាចិត្តរីករាយ
ជួបជុំបងប្អូនអ៊ំតាយាយ ដូចបានអ្វីៗក្នុងសួគ៌ា ។
ឥឡូវកម្សត់ចិត្តឯកា លែងបានចរចាទ្រូងគ្រាំគ្រា
យប់ព្រឹកល្ងាចថ្ងៃកាយរងា ព្រាត់ដោយវេទនាព្រោះខ្លួនក្រ ។
វាសនាខ្ញុំខ្សត់អត់ប្រាក់ចាយ កាលនៅជុំម្ដាយចិត្តស្មោះសរ
ខំរកណាស់ដែរតែមិនល្អ ឃើញនៅតែក្រខុសអ្នកមាន ។
រួចសម្រេចចិត្តឃ្លាតពីស្រុក លាម៉ែលាពុកទាំងអត់ឃ្លាន
ប្រឹងធ្វើកិច្ចការមិនបំពាន ក្រែងបានជាស្ថានមានសម្បត្តិ ។

តែពេលឥឡូវកូនទឹកណាស់ ទឹកព្រះជាម្ចាស់តែងប្រតិបត្តិ
អប់រំទូន្មានឱ្យប្រយ័ត្ន រវាងបង្កាត់អកុសល ។
ពាក្យពុកពាក្យម៉ែប្រៀបម្កុដថ្លៃ ទុកក្នុងហឫទ័យលៃជួយផ្តល់
ធ្វើឱ្យរូបកូនឥតខ្វាយខ្វល់ ចិត្តឥតច្របល់ព្រោះយល់ត្រូវ ។
ទោះនឹកយ៉ាងណាកូនខំប្រឹង ព្យាយាមសម្លឹងល្អពេកកូវ
ធ្វើខ្លួនឱ្យសមដើរត្រង់ផ្លូវ តាមពាក្យប្រដៅម៉ែទូន្មាន ។
កូននៅស្រុកគេតែងគិតថា លោកទាំងទ្វេហារស់សុខសាន្ត
មិនមានជំងឺឈឺក្នុងប្រាណ រុងរឿងក្សេមក្សាន្តព្រះសុខភាព ។
ឃ្លាតមាតុភូមិព្រោះខ្ញុំក្រ រាងកាយមិនល្អព្រោះខ្វះលាភ
មិនដូចអ្នកមានគេជ្រួតជ្រាប ថ្កុំថ្កើនរៀងរាបលាភសម្បត្តិ ។
កវីរៀបរាប់ភ្ជាប់ទឹកភ្នែក ទ្រូងសែនអល់អែកដូចខ្វាយខ្វាត់
ព្រោះមានបងប្អូនជួបវិបត្តិ រស់ឆ្ងាយពេកក្តាត់នៅស្រុកគេ ។
នេះហើយជីវិតនៃអ្នកក្រ ជួបផលមិនល្អជាប់ហូរហែ
ពេលខ្លះអ្នកផ្សេងរស់នៅក្បែរ មើលងាយស្តីជេរឥតមេត្តា ។
ទោះនឿយហឫទ័យក្តីមិនសុខ ដើម្បីម៉ែពុកប្រឹងឧស្សាហ៍
ប្រឹងឥតទំនេរទាំងឈឺផ្សា ក៏ឥតសង្កាបញ្ចេញឡើយ ។
រៀបរាប់ខ្លីៗប៉ុណ្ណឹងចុះ សូមមិត្រស្រីប្រុសផុតទុក្ខស្បើយ

ជូនពរឆ្នាំថ្មីបានល្ហែល្ហើយ　　　　រៀងដរាបអើយតរៀងទៅ ! ។

# ៦០~ មេឃភ្លេចដីហើយ !

វាលស្រែវាលស្រូវនៅតែចងចាំ　　ឃ្លាតឆ្ងាយច្រើនឆ្នាំចាំមិនភ្លេចឡើយ
ទីរស់សុខសាន្តបានផុតទុក្ខស្បើយ　　កន្លែងហ្នឹងហើយជំរំអ្នកស្រែ ។
គួរកុំក្រឡាស់ប្រវាស់ឋានសុខ　　ធ្លាប់ផ្ដល់ស្រណុកច្រើនឆ្នាំច្រើនខែ
រស់នៅសុខសាន្តបានជុំពុកម៉ែ　　បងប្អូនផងដែរតែងតែរីករាយ ។
ផ្ទះតូចចង្អៀតច្រៀតគ្នាពិតមែន　　ឯចិត្តវិញសែនកក់ក្ដៅសប្បាយ
មានសេរីភាពសើចលេងក្អាកក្អាយ　　រីករាយស្រស់ស្រាយកាយមិនស្ងួរស ។
មិនដូចអ្នកក្រុងសាច់ស្បែកភ្លឺថ្លា　　ដេកសុទ្ធវីឡារូបកាយក៏ល្អ
ទ្រទំនំខ្ពង់ខ្ពស់ស័ក្តិយសបវរ　　គួរឱ្យអំណរបុណ្យពីព្រេងនាយ ។
តែកុំសប្បាយក្លាយជាបំភ្លេច　　ឃើញស្រែរត់គេចព្រោះទ្រព្យសម្បទាយ
កុំបានអ្នកស្រែកខំរេចពុនស្ពាយ　　ម្ល៉េះសមរាយមាយអត់មានបាយឆី ។
មេឃខ្ពស់សែនឆ្ងាយៗដាច់វេហាស៍　　គួរអនិច្ចាគ្មានត្រាប្រណី
ភ្លេចជាតិកំណើរធ្លាប់រស់លើដី　　ធ្លាប់ផ្ដល់អ្វីៗលៃឱ្យសុខសាន្ត ។

ប្រៀបបានមនុស្សខ្លះក្រឡាស់តាមចិត្ត គ្មានទឹកអាណិតដល់ជាតិសាមាន្យ
មានកេរ្តិ៍ឈ្មោះល្អរួមរស់ក្សាន្តគ្រាន ភ្លេចដល់ទីឋានដែលរស់ពីមុន ។
មេឃអើយភ្លេចហើយដីធ្លាប់រស់នៅ! ច្រើនឆ្នាំពេកកូវកាលជាប់ទារុណ
លំបាកនឿយហត់ក្រខ្សត់ពេកពន់ ឥឡូវមានធនភ្លេចអនុស្សាវរីយ៍ ។

# ៦១~ ជំនោរជីវិត

រាត្រីពណ៌មាសជះលើមេឃា ក្រោមស្បៃសន្ធិយានាថ្ងៃអាទិត្យ
វាយោបក់បោករលកជីវិត ខ្ទល់ខ្មៃយកើយគិតនឹកអនុស្សាវរីយ៍ ។
ធម្មជាតិខៀវខ្ចីវែងខ្លីស្រស់ល្អ វេរាំលើថ្មតាមផ្ទៃវេហាស៍
ទទួលសម្រស់សន្សើមស្រស់ថ្លា ក្ដួចកៀងចិន្តានៃរូបខ្ញុំហើយ ។
ឱ ! រាត្រីស្ងាត់រសាត់តាមខ្យល់ ជំនោរមកដល់រៀមខ្វល់ឥតស្បើយ
ជីវិតបែកបាក់គ្មានភពកោះត្រើយ ម្ដេចជំនោរអើយអ្នកមិនមេត្តា! ។
ជំនោរជីវិតកម្រិតភពថ្មី បានយល់អ្វីៗជាអនត្តា
ចិត្តសេពសោយរសព្រោះតែតណ្ហា លាភពកាមាវាសនាចិត្តស្ងប់ ។

# ៦២_ តម្លៃជីវិត

តម្លៃមាសប្រាក់ជាប់ថ្នាក់លោកិយ    តម្លៃប្រុសស្រីអាស្រ័យប្រព្រឹត្ត
តម្លៃរបស់កើតពីគំនិត    តម្លៃជីវិតតើឋិតត្រង់ណា? ។
ជីវិតឧត្តមសមមានកេរ្តិ៍ឈ្មោះ    ជីវិតខ្ពង់ខ្ពស់រស់ដោយមេត្តា
ជីវិតមានធម៌ជួបតែសម្មា    ជីវិតថ្លៃថ្លារស់ដោយសុចរិត ។
តម្លៃជីវិតពិតជាល្អណាស់    ល្អឥតមានខ្ចោះល្អហួសកម្រិត
គួររស់ក្នុងធម៌ជីវិតប្រណិត    គ្មានផលវិប្បដិសារីមករំខានឡើយ ។
យល់ទេប្រុសស្រីតម្លៃជីវិត?    ល្អក្រៃពេកពិតចង់ហួសការឆ្លើយ
គួរសាងសុចរិតពេលនេះឱ្យហើយ    ទើបជាសះស្បើយពីកាមកិលេស ។

# ៦៣_ ជីវិតឥតន័យ

សំណាងសំណោកបន្ទោកជីវិត    សំណេរបែបគិតគំនិតខ្លួនឯង
សំណឹងលើគ្រែរារែកបែកផ្សេង    សំណៅផ្សេងៗសំណែងមិត្រញាតិ ។
ជីវិតប្រាស់ព្រាត់តើឃាត់ម្តេចបាន    ជីវិតចាកឋានប្រាណត្រូវឃ្លៀងឃ្លាត

ជីវិតធូរថ្លៃតម្លៃចោលម្សៀត ជីវិតគ្រោតគ្រាតញោតិលះបង់ចោល ។
ជីវិតមួយជាតិផ្លាស់ស្មៀតធ្វើបាប ជីវិតដុនដាបក្រាបរស់តែលតោល
ជីវិតឥតន័យតម្លៃប្រែប្រួល ជីវិតដេកដួលរោលរាបលើភព ។
ជីវិតបែបនេះពិតជាមរណា ជីវិតឥតការប្រាថ្នាឥតភ័ព្វ
ជីវិតខ្វះបុណ្យទារុណគួរគាប់ ជីវិតខុសទ្រព្យជាប់ឈ្មោះឥតន័យ ។

# ៦៤_ រលកជីវិត

រលកជីវិតពិតជាមិនយល់ រាល់ថ្ងៃអំពល់វល់នឹងទឹកភ្នែក
ដេកដើរកើតទុក្ខរុករានរារែក ឱ្យរាអល់អែកបែកចិត្តជាពីរ ។
សភាវៈចិត្តគិតយ៉ាងរហ័ស ដូរដោះឥតខ្វះផ្លាស់គ្រប់នាទី
បើមិនប្រយ័ត្នហាត់មិនសម្ដី អភ័ព្វជីវីទីទាល់ចិត្តបុណ្យ ។
សន្សំកសាងស្វាងចិត្តពីបាប ជាគ្រឿងឆ្អេះឆ្អាបឆាប់ចូលទារុណ
មានតែទុក្ខសោកបោកចិត្តពីគុណ គួរតែដឹងមុនទទន់ទោររកព្រះ ។
រលកខ្លួលខ្ទាញ់បាញ់ក្នុងជលសា បក់បោកកាយាក្លាខ្លាំងជម្នះ
រសាត់អណ្ដែតហេតុមិនប្រទះ រហូតលាលះជះពីនាមដើម ។

ជីវិតសត្វលោកសោកដូច្នោះដែរ វលកហូរហែក្បែរចុងដង្ហើម
ត្រូវស្លាប់ព្រាត់ប្រាស់ខ្វះកិច្ចចុងផ្តើម ទុក្ខខ្លាំងសម្បើមដើមហេតុពីបាប ។

# ៦៥~ សំនៀងឥតន័យ

សំនៀងសំណោកបោកចិត្តកវី ក្រឡាស់ចិត្តថ្មីសម្តីប្រឌិត
វិយោគបោកប្រាណរុញច្រានដួងចិត្ត ស្រណោះធ្លាប់ស្និទ្ធពិតគ្រាំឱ៉រ៉ា ។
សំណាបក្រាបក្រោលបំបោលចិត្តខ្ញុំ ឱ្យរងទុក្ខធំផ្តុំពេញកាយា
ស្រណោះសួរសៀងធ្លាប់ច្រៀងចរចា នឹកឡើងកាលណាចិន្តាចំបែង ។
ឱ ! កម្មលិខិតកម្រិតវាសនា មកផ្តាច់សង្ខារប្រហារក្រៃលែង
ទុក្ខធំក្នុងចិត្តទុក្ខតែម្នាក់ឯង វីវក់វង្វេងនឹងភ្លេងកិលេស ។
មិនបានអប់រំយំអស់មួយជាតិ ព្រោះតែឃ្លៀងឃ្លាតពីលោកអ្នកចេះ
ធមិព្រះសម្ពុទ្ធថ្លៃថ្លាពិសេស សូមកុំប្រហែសបណ្តោយតាមចិត្ត ។
បញ្ចកាមគុណកុំប្រសព្វ នាំចិត្តមិនស្ងប់ចប់បែកបាក់មិត្រ
សំនៀងឥតន័យប្រល័យមិនគិត ចូលភពងងឹតពិតជារងទុក្ខ ។
សំនៀងច្រៀងកាព្យកំណាព្យជួយផ្តាំ រស់នៅច្រើនឆ្នាំកងកម្មស្នាញស្នុក

ព្រោះចាញ់ខ្លួនឯងចំបែងឥតសុខ ពីនេះទៅមុខសូមផុតទុក្ខហោង! ។

# ៦៦- ស្នេហាយុវវ័យ

ពាក្យខ្មែរពីរម៉ាត់មិនបាត់ទៅណា គឺពាក្យស្នេហាយុវវ័យថ្មី
ខ្ញុំនឹងតែងកាព្យប្រាប់ដល់ប្រុសស្រី ដូចមានសេចក្ដីតទៅនេះថា ។
សម័យឥឡូវសម្បូរសប្បាយ លុយកាក់ប្រាក់ចាយឡូយឆាយទីផ្សារ
ខោអាវស្លៀកពាក់ទិញសុទ្ធដុល្លារ កាច់រាងហ៊ឺហាតាមទីផ្សេងៗ ។
បង្អួតទេសចរណ៍លម្អរូបកាយ ដើរយប់ដាច់ឆ្ងាយគ្មានគិតកោតក្រែង
អាសូរដល់ទ្រូងអ្នកម្ដាយខ្លួនឯង រងទុក្ខចំបែងដេកចាំមើលកូន ។
ចាំបាត់ៗចាំស្ងាត់សូន្យឈឹង មិនឃើញព្រលឹងវិលវិញមាសស្ងួន
ដឹងទេថាម្ដាយចាំមើលផ្លូនៗ ខំបិទមាត់សូន្យមិនហ៊ានស្ដីជេរ ។
ឯរូបកូនវិញសប្បាយអស់យ៉ាង ធ្វើឫកក្អេងក្អាងឥតគិតដល់ម៉ែ
ជួបជុំមិត្រភក្ដិទុកដាក់ចិត្តគេ សប្បាយរីតទ្វេស្រីញីអូនបង ។
ភ្លើតភ្លើនតាមផ្លូវសូវគិតដល់ខ្លួន គ្រោះថ្នាក់គាប់ជួនគ្មានអ្នកបន់ផ្សង
ស្លាប់រស់តែងតោលឆ្ងាយញាតិកន្លង អាសូរបំណងអ្នកម្ដាយធ្លាប់គិត ។

ម្យ៉ាងទៀតស្នេហាសម្រាប់ក្មេងវ័យ ដូចឃើញសព្វថ្ងៃតាមទីឆ្ងាយជិត
ស្រណោះខ្លួនណាស់មិននឹកអាណិត អ្នកម្ដាយធ្លាប់ស្និទ្ធត្រូវអាប់កិត្តិយស ។
បើកូនស្រីៗស្រដីហួសមាឌ មើលងាយប្រមាថគ្មានគិតទាបខ្ពស់
មិនស្ដាប់ម៉ែឪបងប្អូនផងសោះ ប្រព្រឹត្តឡេះឡោះនឹងប្រុសពាលា ។
លះបង់ខ្លួនប្រាណគ្មានខានលុះថ្ងៃ គួរអាសូរក្រៃក្មេងស្រីគ្រប់គ្នា
មិនទាំងអស់ទេក្មេងខ្លះល្អជា ប្រព្រឹត្តធម្មាសាងខ្លួនយ៉ាងល្អ ។
ខ្ញុំថាតែអ្នកដែលប្រព្រឹត្តខុស អ្នកជាវិញនោះខ្ញុំជួយត្រេកអរ
នឹងលើកតម្កើងរីករាយសាទរ ដែលប្រព្រឹត្តល្អក្នុងនាមជាស្រី ។
ចំណែកប្រុសវិញក៏ដូចគ្នាដែរ ឃើញសព្វហួរហែប្រុសសម័យថ្មី
សាងខ្លួនក្នុងល្បែងចូលជ្រោះអប្រិយ សែនអាសូរក្រៃក្នុងវ័យសិក្សា ។
ខ្លះសេពគ្រឿងញៀនជាល្បែងគ្រោះថ្នាក់ ចូលភពអប្បលក្ខណ៍អស់ពាក្យវាចា
ត្រូវជាប់ខ្នោះឃ្នាបក្នុងគុកឈើផ្សា អ្នកផ្សេងស្ដីថាដល់ម៉ែឪទៀត ។
កិត្តិយសគ្រួសារត្រូវខូចខ្ទេចខ្ទក់ ព្រោះតែក្មេងឈ្លក់និងក្មេងចោលម្សៀត
ខ្លួនឯងមួយសោះបង្កដល់ជាតិ រីករវរច្រើនទៀតដូចមានសព្វថ្ងៃ ។
ក្នុងនាមជាខ្មែរត្រូវថែវប្បធម៌ ឱ្យគង់វង្សល្អដូចពេជ្រចរណៃ
មិនបង្ករឿងនាំគ្រោះភិតភ័យ គួរណាស់ប្រុសស្រីគិតផងខ្លួនខ្មែរ ។
ស្នេហាយុវវ័យលៃប៉ុណ្ណឹង សូមមិត្រកុំខឹងរិះគិតគ្នាន់គ្នេរ

ខុសឆ្គងម្ដេចម្ដាកុំប៉ងចិត្តជេរ ចុងក្រោយមានតែជូនពរឆ្នាំថ្មី ។
អាយុវណ្ណៈសុខៈពលៈ កុសលគ្រប់ថ្នាក់ខ្ញុំជាករី
លើកជូនញាតិមិត្រមិនថាប្រុសស្រី សូមមានសិរីលុះក្ស័យសង្ខារ ។

# ៦៧. មាឃបុណ្ណមី

មាឃៈបុណ្ណមីជាថ្ងៃអស្ចារ្យ ពួកជនខេមរាជ្រះថ្លាវន្ទា
គោរពឱនកាយថ្វាត់ថ្វាយភគវា បង្គំបាទាបូជាភ្ញីផ្កា ។
ថ្ងៃ១៥កើតកំណើត៥ជាក់ ដែលអស់លោកអ្នកគោរពជ្រះថ្លា
នឹកដល់ព្រះគុណនៃអង្គសាស្តា ទ្រង់ត្រាស់ទេសនាប្រោសដល់សព្វសត្វ ។
កាលដែលព្រះពុទ្ធទ្រង់គង់លើភ្នំ ខ្ពស់ទាបតូចធំឥតមានវិបត្តិ
បរិព្វាជកនិស្ស័យមិនខ្វាត់ ចូលមកប្រតិបត្តិគោរពសាស្តា ។
ទីឃៈនខៈហេតុតែនិស្ស័យ ក្នុងរតនត្រៃនៃពុទ្ធសាសនា
ប្រគល់កាយចិត្តប្រណិតថ្លៃថ្លា ទ្រង់ស្តាប់ទេសនាដោយការស្ងប់ស្ងាត់ ។
ព្រះអង្គទ្រង់លើកត្រង់វេទនា៣ រង្គាយសេចក្តីដោយព្រះបរិយត្តិ
ធ្វើឱ្យអ្នកស្តាប់ដ៏ច្រើនពេកក្តាត់ ឃ្លាតចាកវិបត្តិបានយល់ត្រឹមត្រូវ ។
បរិព្វាជកទ្រង់ឈរជិតនោះ ក៏បានចាក់ធ្លុះសោតាភ្លាមទៅ

ដោយអំណាចធម៌បង្ហាញប្រាប់ផ្លូវ ដ៏ល្អពេកកូវគុណព្រះសម្ពុទ្ធ ។
ចំណែកលោកអ៊ំបង្គំជិតដែរ បង្អោនក្រសែចិត្តដ៏មុះមុត
ត្រងត្រាប់អត្ថន័យថ្លៃថ្លាបំផុត ក៏បានរលត់កិលេសតណ្ហា ។
ព្រះសារីបុត្រជាម្កុដក្នុងសង្ឃ ក្រោយបានផ្ចិតផ្ចង់ព្រះអរហន្តា
ព្រះពុទ្ធទ្រង់ឫទ្ធិក៏ប្រកាសថា ជាពុទ្ធដីកាសាវ័កសន្និបាត ។
ព្រះសារីបុត្រនិងព្រះមោគ្គល្លាន ជាក្បួនជាស្ពានកាយចិត្តត្រង់ស្អាត
ជាសាវ័កឆ្នើមឥតមានភ្លាត់ផ្លាត ទទួលឱវាទក្នុងជាតិចុងក្រោយ ។
ក្នុងថ្ងៃប្រជុំធំដោយសង្ឃា ដ៏ច្រើនមហិមាមិនណាត់ទុកឡើយ
ចូលរួមដោយស្មោះឥតសោះកន្តើយ ដូចបានពោលហើយមួយពាន់ជាងអង្គ ។
សុទ្ធតែអរហន្តឯហិភិក្ខុ លះបង់កងទុក្ខប្រព្រឹត្តផ្ចិតផ្ចង់
ព្រះចន្ទភ្លឺច្បាស់រួមផ្កាយផ្ទរផង់ រួមគ្នាជាកង់បង្កើតកងបុណ្យ ។
ក្នុងថ្ងៃនេះដែរមិនតែប៉ុណ្ណឹង ឱវាទថ្លៃថ្លឹងពោលឥតស័យស៊ុន
ប្រោសដល់សាវ័កព្រមដោយព្រះគុណ រួចចាកទារុណពីភពអបាយ ។
អ្នកបានយល់ហើយស្មើយក្នុងចិន្តា គោរពជ្រះថ្លាបូជាចិត្តកាយ
លះបង់ធ្វើទានដោយមិននឹកស្តាយ រីករាយសប្បាយនឹងបុណ្យកុសល ។
ពេលព្រឹកព្រលឹមទទឹមមុនភត្ត ជាពេលកំណត់ដែលត្រូវមកដល់
ស្តេចយាងបិណ្ឌបាតយកផលាផល ហើយមានបន្ទូលនឹងអានន្ទថា ។

ម្នាលអានន្ទអើយកុំឡើយបែកបែរ មកក្បៀកជិតក្បែរតថាគតវ៉ា
តោះ ! យើងនឹងទៅចេតិយបាវ៉ា ទទួលដីកាដោយចិត្តរីករាយ ។
ក្នុងពេលនោះឯងព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់បទបែបមានន័យ
ជាឱឡារិកឱ្យយល់សេចក្ដី តែអានន្ទថ្លៃមិនយល់អីសោះ ។
ព្រះអង្គត្រាស់ថាម្នាលអានន្ទអើយ អ្នកកុំនៅឡើយចូលចេញទៅចុះ
អានន្ទត្រាស់ថាបពិត្រទានប្រោស ទទួលពេលនោះក៏ចេញបាត់ទៅ ។
ចំណែកពួកមារពេលបានឱកាស ចូលមកជិតព្រះមិនរេរង់នៅ
ទូលអារាធនាតាមបែបឆៅៗ ក្នុងចិត្តហ្មងសៅឱ្យទ្រង់និព្វាន ។
ព្រះពុទ្ធត្រាស់ថាម្នាលមារចិត្តបាប អ្នកចូលមកក្រាបបង្គំរួមមាន
ឱ្យតថាគតស្ដេចចូលនិព្វាន មិនយូរប៉ុន្មានកន្លង៣ខែ ។
ទ្រង់ដាក់អាយុសង្ខារពេលនោះ ញ័ររកក្រើកអស់ផ្គរលាន់ហូរហែ
ធ្វើឱ្យអានន្ទចាប់ភ្លឹករឹតទ្វេ ព្រោះដោយសារតែសំឡេងនោះឯង ។
ថ្ងៃ១៥កើតមាឃៈបុណ្ណមី ពួកជនប្រុសស្រីជ្រះថ្លាក្រៃលែង
រឭកនឹកគុណដល់សង្ឃគម្ដែង ទាំងចាស់ទាំងក្មេងមិនអែលអលឡើយ ។
សាធុសាធុមាឃៈបូជា សូមញាតិគ្រប់គ្នាកុំធ្វើកន្តើយ
